អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម

ORIGINAL/ORIGINAL

ថ្ងៃ ខែ ឆ្នាំ (Date): 25-Aug-2015, 13:39

CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី៣១៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ័ង

កញ្ញា ម៉ាដេលេណា ហ្គេហ្ស៊ី
*(Ms. Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ស្រ៊ា រតនៈ

លោក សេង លាង

លោក ត្រាវីស ហ្វារ *(Mr. Travis FARR)*

លោក ចូសេហ្វ អេនឌ្រូ ប៊យលី
*(Mr. Joseph Andrew BOYLE)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកធួរ វែកគែន
*(Mr. Arthur VERCKEN)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក វ៉ែន ពៅ

លោក ឡោ ជុនធី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក សេង លាង | ខ្មែរ |
| លោក ត្រាវីស ហ្វារ | អង់គ្លេស |
| លោក ចូសេហ្វ អេនឌ្រូ បិយលី | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក តក់ ប៊ុយ (2-TCW-908) | ខ្មែរ |
| លោកស្រី យី ឡៃស្រូវ (2-TCW-841) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី:- លោក តក់ ប៊ុយ** (2-TCW-908)

សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី ....................ទំព័រ ២

សួរដោយចៅក្រម ក្លូឌា ហ្វេនស៍ ផ្តើមពី....................ទំព័រ ១៤

សួរដោយលោក គង់ សំអុន ផ្តើមពី ....................ទំព័រ ១៥

**ការសួរសំណួរទៅសាក្សី:- លោកស្រី យី ឡែស្សុទ** (2-TCW-841)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ២០

សួរដោយលោក សេង លាង ផ្តើមពី .................... ទំព័រ ២៣

សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី ផ្តើមពី.................... ទំព័រ ២៩

សួរដោយលោក ពេជ អង្គ ផ្តើមពី .................... ទំព័រ ៤៦

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី.................... ទំព័រ ៥៥

សួរដោយចៅក្រម ក្លូឌា ហ្វេនស៍ ផ្តើមពី.................... ទំព័រ ៥៨

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី.................... ទំព័រ ៥៩

សួរដោយលោក អាកឡូវ វែកគែន ផ្តើមពី.................... ទំព័រ ៦៥

សួរដោយលោក គង់ សំអុន ផ្តើមពី.................... ទំព័រ ៦៨

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:០៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសវនាការនៅថ្ងៃនេះ -- នៅព្រឹកនេះ អង្គជំនុំជម្រះបន្តស្តាប់សក្ខីកម្មសាក្សី តក់ ប៊ុយ បញ្ចប់ ហើយនិងអាចចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-841។

ក្រឡាបញ្ជីសវនាការលោក កញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះគឺ លោក តក់ ប៊ុយ។ លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ ហើយសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្ទាប់ទៀតមានរហស្សនាម 2-TCW-841។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិពន្ធ ឬញាតិលោហិតជាមួយនឹងជនជាប់ចោទទាំងពីររូបគឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីរូបនេះនឹងធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែកនៅព្រឹកនេះមុនពេលផ្តល់សក្ខីកម្ម។ សូមអរគុណលោកប្រធាន។

[០៩:០៣:០៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណកញ្ញា ជា ស៊ីវហ័ង។

ហើយជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។

អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ ដែលបញ្ជាក់ថា គាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃមុខខាងមុខឱ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា ថាមានអាការៈឈឺចង្កេះជាប្រចាំវិលមុខ ហើយនិងខ្សោយកម្លាំង និងបានផ្តល់អនុសាសន៍ថា សូមឱ្យអង្គជំនុំជម្រះអនុញ្ញាតឱ្យលោក នួន ជា ចូលរួម តាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ដោយផ្អែកលើមូលដ្ឋាននេះ និងបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឱ្យលោក នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការ ពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលពេញ -- សវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការនៅក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម មេធាវី សហការី។

[០៩:០៥:០០]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីៗ ខ្ញុំសូមចាប់ផ្តើមសួរលោកពីការ ពីដំណើរទស្សនកិច្ចដែលយើងបាន បាទ ពីអ្វីដែលយើងបាននិយាយកាលពីម្សិលមិញ។ ទាក់ទងទៅនឹងអ្វីដែលកើតឡើងចំពោះមនុស្ស ចំពោះអ្នក

ដែលធ្លាប់ធ្វើជាអតីតទាហានលន់ នល់។ ខ្ញុំសូមចូលទៅនិយាយអំពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកនៅក្នុងសំណុំរឿង០០៤។ ដំបូង ខ្ញុំសូមសួរលោកថាតើ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលខ្ញុំមាននៅក្នុងដៃនេះ តើលោកបំពេញទម្រង់នេះ សរសេរដោយផ្ទាល់ដៃខ្លួនឯង ឬក៏អត់ទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជាភាសាខ្មែរ ដើម្បីសាកសួរគាត់មើល៍ ថាតើគាត់សរសេរដោយផ្ទាល់ដៃឬយ៉ាងណា។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកបំពេញទម្រង់នេះ ដោយខ្លួនឯង ឬក៏មានអ្នកសរសេរឲ្យលោក?

**លោក តក់ ប៊ុយ៖**

**ឆ៖** បាទ ខ្ញុំបាទមិនបានសរសេរខ្លួនឯងទេបាទ គឺគេសរសេរខ្លួនគេ។

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន!

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញ!

**លោក ត្រាវីស ហ្វារ៖**

សុំទោស ខ្ញុំកត់សម្គាល់ថា នៅទម្រង់ថតចម្លងនេះ គឺថាមានគូស *ហាយឡាយ*នៅពីលើនេះ ប្រហែលជា -- ឃើញមាន *ហាយឡាយ* តើមេធាវីការពារក្តី *ហាយឡាយ*ពីបញ្ហាអ្វីដែរ សូមបញ្ជាក់ផង?

[០៩:០៨:១៦]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំគូសពណ៌នេះ *ហាយឡាយ*ខាងលើឯកសារនេះ នៅត្រង់ឃ្លាមួយ ហើយខ្ញុំសូមឲ្យអាន លោកអានជាមួយនឹងខ្ញុំ។ ខ្ញុំមានពាក្យសុំនេះ បកប្រែជាភាសាអង់គ្លេសហើយ។ លោកប្រធាន ខ្ញុំនិយាយអំពីឯកសារ E319/25.3.48។ ការបកប្រែជាភាសាអង់គ្លេសនៅក្នុងឃ្លាដែលខ្ញុំគូស

ហាយឡាយនេះ "ថាខ្ញុំគឺជាអតីត ជាអតីតនាយទាហានលន់ នល់ ហេតុនេះឯងបានជាគេចង់សម្លាប់ខ្ញុំ។ កូនទាហានតូចតាច ត្រូវបានអនុញ្ញាតឲ្យត្រឡប់ទៅវិញ។ ទាហានទាំងអស់នោះ ត្រូវបានគេចាត់តាំងឲ្យទៅកាប់ឆ្ការព្រៃ ហើយស្នាក់នៅទីនោះ"។ តើការបកប្រែ -- តើការបំពេញជាភាសាខ្មែរនេះ ក្រោយពេលខ្ញុំអានអង់គ្លេសហើយ មានអ្នកបកហើយ ថាតើវាៗដូចទេ ហើយជាអ្វីដែលលោកចង់និយាយហ្នឹង ឬក៏យ៉ាងណា?

**លោក តក់ ប៊ុយ៖**

**ឆ៖** បាទ ការណ៍ដែលនេះ គឺខ្ញុំបាទអត់បានសរសេរ ហើយអត់បានអីទេ គ្រាន់តែក្នុងនាមខ្ញុំជាពលទោទាហាន លន់ នល់ ម្នាក់ប៉ុណ្ណោះឯង។

[០៩:១០:០០]

**ស៖** ខ្ញុំយល់ហើយថាលោកមិនបានបំពេញទម្រង់នេះដោយខ្លួនឯងទេ ប៉ុន្តែខ្ញុំគិតថាលោកបានផ្តិតមេដៃដើម្បីបញ្ជាក់ថា លោកយល់ស្របថាពាក្យនេះត្រឹមត្រូវហើយ តែសំណួររបស់ខ្ញុំគឺចង់ដឹងអំពីភាពខុសគ្នានេះ ដែលលោកឡើងរវាងទាហានលន់ នល់ ដែលត្រូវបានគេយកទៅសម្លាប់ចោល និងអតីតទាហានលន់ នល់ ដែលត្រូវបានអនុញ្ញាតឲ្យត្រឡប់មកវិញ ហើយត្រូវបានចាត់តាំងឲ្យទៅកាប់ព្រៃ។ ដូច្នេះត្រង់នេះហាក់ដូចជាលោកញែកដាច់ពីគ្នារវាងប្រភេទ ទាហានពីរប្រភេទ បើខ្ញុំយល់យ៉ាងដូច្នេះ តើត្រឹមត្រូវដែរឬអត់ទេ?

**ឆ៖** បាទ កាលៗនោះ គឺគេបានបញ្ជូនខ្ញុំបាទឲ្យទៅពួកទាហាន ហើយនិងពួកនាយទុន គឺឲ្យទៅនៅមួយកន្លែង កាប់ឆ្ការព្រៃ គឺនៅខាងលិច ហៅថាភូមិណាំតៅ ក្នុងរយៈពេលប្រាំពីរខែ។ ដល់ឃើញថាធ្វើការទៅវាមមាញឹក មិនទម្រន់ស្នក់ ដូច្នេះគេក៏បានប្រជុំកោះហៅទាំងអស់ឲ្យត្រឡប់ចូលស្រុកកំណើតវិញបាទ។

**លោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ ឥឡូវនេះខ្ញុំយល់ហើយ។ ដូច្នេះនៅពេលដែលគេចាត់តាំងឲ្យលោកទៅកាប់ព្រៃ អ្នកដែលចាត់តាំងលោកនេះបានដឹងថា លោកគឺជាអតីតទាហានលន់ នល់ បានដឹងថាលោកពិតជាអតីតទាហានលន់ នល់។ តើត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

[០៩:១២:២៥]

**ស៖** បាទ ក្រោយពីស្ដាប់ឮយ៉ាងដូច្នេះ ខ្ញុំសូមទៅបង្ហាញលោកនូវអ្វីដែលលោកបានឆ្លើយជូនអ្នកស៊ើបអង្កេតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/7968, ERN ជាភាសាអង់គ្លេស 007264 144*(ស៊ីក)*, ជាភាសាខ្មែរ 00057741។ នៅក្នុងចម្លើយរបស់គាត់ -- របស់លោកនេះ គឺថាលោកបានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់សម្ដីលោក៖ "ពេលខ្លះពួកគេបានរកឃើញថា អ្នកខ្លះធ្លាប់ធ្វើជាទាហាន ហើយក៏ត្រូវគេយកទៅសម្លាប់ចោល"។ ក្រោយពីស្ដាប់សក្ខីកម្មរបស់លោករួចមក វាហាក់ដូចជាផ្ទុយគ្នាទៅនឹងអ្វីដែលលោកទើបតែនិយាយអម្បាញ់មិញនេះថា បើសិនណាគ្រាន់តែជាកូនទាហានធម្មតា គឺថា គឺគេរកឃើញមានអ្នកធ្វើទាហាន មានអ្នកមិនធ្វើទាហាន។ តើត្រឹមត្រូវអ៊ីចឹងអត់ទេលោក?

**ឆ៖** បាទ កាលនោះខ្ញុំសូមបកស្រាយបន្ដិចថា ថ្ងៃ១៧ មេសា ចូលមកដល់ គឺពួករំដោះ។ ដូច្នេះគេចែកញែកជាពីរគឺ ពលទាហានទៅផ្សេង នាយទាហានទៅផ្សេង។ ដូច្នេះនាយទាហានគេចាប់ចងអស់រលីង ដោយឡែកតែពួកខ្ញុំពលទោគេទុកនៅផ្ដុំ គេធ្វើការអប់រំ រួចក៏បញ្ជូនខ្លួនមកតាមផ្ទះសម្បែងវិញ។ ពេលមកដល់ផ្ទះសម្បែងវិញ គឺគេរៀបចំជាសហករណ៍ក៏បានប្រមូលពួកនាយទុន ហើយនិងពួកទាហានដែលកូនទាហាននោះ ទៅឱ្យនៅមួយកន្លែង ដាច់ឡែកពីប្រជាពលរដ្ឋ គឺនៅក្នុងព្រៃ។ ដូច្នេះគឺពេលនោះ ហើយដែលត្រូវកាប់ឆ្ការព្រៃដាំដុះ យកភោគផលនោះបរិភោគ។ ពេលនោះមិនទាន់មាន ហៅថា គេហៅថាប្រើអំណាចផ្ដាច់ការទេនៅឡើយ។ គេកំពុងតែតាមដាន តើសកម្មភាពយើងខ្ញុំដែលជាពួកកូនទាហាននោះគឺធ្វើការនោះ វាខ្លាំងក្លាឬអត់។ បាទ សូមអរគុណ។

[០៩:១៥:០០]

**ស៖** តើលោកធ្វើការជាមួយនឹងអតីតទាហានលន់ នល់ កាប់ឆ្ការព្រៃហ្នឹង មានចំនួនទាំងអស់ប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ គឺខ្ញុំសន្និដ្ឋានប្រហែលជា១៥នាក់ ទាហានពួកខ្ញុំ។

**ស៖** ហើយតើអតីតទាហានទាំង១៥នាក់នេះ ជាពលទាហាន ឬក៏ជានាយទាហាននៅក្នុងរបបលន់ នល់?

**ឆ៖** បាទ ខ្ញុំបញ្ជាក់ខាងដើមហើយថា សុទ្ធតែពលទាហាន។ នាយទាហាន គេយកទៅមួយកន្លែងអស់រលីងហើយ ដូច្នេះនៅតែពលទាហាន។ គេញែកចែកដាច់ដោយឡែកពីគ្នា។

**ស៖** សូមអរគុណលោកសាក្សី។ បាទ ឥឡូវខ្ញុំសូមចូលទៅចំណុចមួយថ្មីទៀត គឺនិយាយអំពីតួនាទីរបស់លោកនៅក្នុងកងចល័ត នៅពេលធ្វើការលើកទំនប់នោះ ប្រហែលជាខ្ញុំស្ដាប់ឮមិនច្បាស់ទេ

ប៉ុន្តែពីម្សិលមិញ ខ្ញុំបានស្តាប់ឮលោកនិយាយថា លោកគឺជាមេកងតូចនៅចំណុះឲ្យកងចល័ត។ នៅក្នុងប្រតិចារឹកស្តាប់ចម្លើយរបស់លោក ឯកសារ E319/19.3.3, ERN ជាភាសាអង់គ្លេស 00842062, បារាំង 00842069, ខ្មែរ 00801007។ លោកត្រូវបានគេសួរសំណួរដូចតទៅ “សួរ៖ តើលោកមានបុណ្យសក្តិអីទេនៅពេលលោកធ្វើទាហាន? ខ្ញុំគឺជាសមាជិកប៉ុណ្ណោះនៅក្នុងកងធំ ដែលមានមនុស្ស ១០០នាក់”។ ដូច្នេះសំណួររបស់ខ្ញុំ តើលោកជាសមាជិកធម្មតា ឬក៏លោកជាមេកងតូច?

**ឆ៖** បាទ កាលដែលលើកទំនប់អាងត្រពាំងថ្មនោះ ខ្ញុំបាទគឺមេកងតូច តួនាទីរបស់ខ្ញុំបាទ។

**ស៖** សូមអរគុណលោកសាក្សី ច្បាស់ហើយ។ ខ្ញុំសូមសួររឿងផ្សេងទៀត ពីម្សិលមិញលោកបានឆ្លើយថា គឺថាលោកធ្វើការងារហ្នឹងដូចកងទ័ពអ៊ីចឹង យើងដើរ -- នៅក្នុងប្រតិចារឹកស្តាប់ចម្លើយ -- កំណត់ហេតុស្តាប់ចម្លើយ លោកឆ្លើយថា៖ “យើងដើរដូចកងទ័ពអ៊ីចឹង”។ តើនៅក្នុងកងចល័តរបស់លោកនេះមានរចនាសម្ព័ន្ធដូចម្តេចដែរ? តើរចនាសម្ព័ន្ធនៅក្នុងកងចល័តរបស់លោក វាដូចគ្នាទៅនឹងរចនាសម្ព័ន្ធនៃទាហានរបបលន់ នល់ ដែរឬទេ?

**ឆ៖** បាទ ព្រោះបញ្ហាហ្នឹង គឺពេលដែលមេបញ្ជាការតំបន់ ឬក៏វរៈគេដាក់ទិសទៅកន្លែងណាមួយនោះ គឺយើងរៀបចំជាជួរៗ តម្រង់ជួរ។ ដូចខ្ញុំបានមានជម្រាបជូនថាជាជួរៗ ហើយផ្លាស់ពីកន្លែងមួយទៅកន្លែងមួយ គឺកងមេក្រុមទី១ចេញបណ្តើរៗ រួចដល់ក្រុមទី៣អស់ រួចបានចូលមេកងទី២បណ្តើរៗគ្នា ខ្ញុំប្រៀបបានដូចជាកងទ័ព។

[០៩:២០:០៧]

**ស៖** ហើយតាមបទពិសោធន៍របស់លោកវាដូចគ្នាទៅនឹងរចនាសម្ព័ន្ធក្នុងជួរទាហាន លន់ នល់ដែរទេ?

**ឆ៖** បាទ បើប្រៀបធៀបទៅនឹងខ្ញុំធ្វើទាហាន គឺដូចតែគ្នាណ៎ះ! មានក្រុម មានកង។ ពេលចេញទៅមិនបានដើរប្រសេចប្រសាច ច្របូកច្របល់គ្នាទេ គឺដងរែកនៅនឹងស្មា គឺអីវ៉ែអីវ៉ាន់នៅនឹងបង្គីចេញបណ្តើរៗគ្នាម្តងមួយៗទៅ លុះត្រាតែដល់គោលដៅ ដូចជាទាហានឡើងវ៉ៃ បាទ។

**ស៖** សូមអរគុណលោកសាក្សី។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក លោកបានឆ្លើយទៅនឹងសំណួរដូចខាងក្រោមនេះ ខ្ញុំសូមដកស្រង់សំណួរចម្លើយ ហើយសួរមើលថា តើលោកបានឆ្លើយដូច្នេះមែនទេ។ គឺសំណួរទី១២ “សំណួរ៖ នៅពេលដែលលោកកំពុងធ្វើការនៅទីនោះ តើមានអ្នកណាបានឃើញមនុស្សស្លាប់ ឬត្រូវបានគេយកទៅសម្លាប់ដែរឬទេ? តើមានអ្នកណានៅក្នុងកងរបស់

លោកមានគេសម្លាប់ដែរឬទេ? ឆ្លើយ៖ គឺមានការបញ្ជាពីថ្នាក់លើ គឺ តាវ៉ាល់ គឺគេមិនឱ្យយើងសម្លាប់ទាហានណាទេ។ ខ្ញុំមិនដែលបានឃើញអ្នកណាម្នាក់ត្រូវបានគេយកទៅសម្លាប់នោះទេ គឺមិនបានឃើញទេ”។ តើនេះជាចម្លើយរបស់លោកដែលលោកបានឆ្លើយប្រាប់ទៅមន្ទីរស៊ើបអង្កេតដែរមែនឬទេ?

**ឆ៖** បាទ ខ្ញុំបាទមិនបានឃើញនឹងភ្នែក ហើយមិនបានឃើញអ្វីទាំងអស់ គ្រាន់តែគេថាថាការសម្លាប់ការអីបាទ។

**ស៖** ដូច្នេះ នៅពេលដែលលោកឆ្លើយទៅប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាទំព័រអង់គ្លេស 00119-- ហើយខ្មែរ --

**អ្នកបកប្រែ៖**

សូមអធ្យាស្រ័យលោកប្រធាន គាត់មេធាវីអាន ERN ញាប់ពេកមិនអាចតាមទាន់។

**ប្រធានអង្គជំនុំ៖**

លោក វ៉ិចទ័រ កូប៉េ ធ្វើសាជាថ្មីម្តងទៀត លោកនិយាយញាប់អ្នកបកប្រែ បកប្រែមិនទាន់ទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន។

[០៩:២៣:២២]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្មែរ 00057739, អង់គ្លេស 00726119, បារាំង 00743249 គឺឯកសារ E3/7968។ លោកសាក្សី លោកថា មនុស្សមួយចំនួនស្លាប់នៅឯការដ្ឋានលើកទំនប់ ប៉ុន្តែយ៉ាងហោចណាស់ក៏ត្រូវយកគេយកមនុស្ស ១៥នាក់ យកទៅសម្លាប់ចោលក្នុងមួយយប់ៗ។ បាទ ដោយយកចម្លើយរបស់លោកឆ្លើយជូនអ្នកស៊ើបអង្កេត តើលោកពិតជាបានឃើញការចាប់ខ្លួនអ្នកទាំងអស់នេះ ហើយថាតើលោកពិតជាបានឃើញអ្នកទាំងអស់នេះ ត្រូវបានគេសម្លាប់ចោលមែនឬក៏អត់ទេ?

**លោក តក់ ប៊ុយ៖**

**ឆ៖** បាទ ដូចខ្ញុំបានជម្រាបមុនថា ខ្ញុំអត់បានឃើញទេណ៎ា គឺគេប្រាប់ខ្ញុំថា ក្នុងមួយយប់យ៉ាងតិច គឺ១៥នាក់យកទៅសម្លាប់។ អានេះគ្រាន់តែគេប្រាប់ខ្ញុំ។

**ស៖** ដូច្នេះលោកឮគេនិយាយ តើលោកឮអ្នកណាម្នាក់និយាយហ្នឹង គឺនៅពេលលោកធ្វើការលើកទំនប់ហ្នឹង ឬក៏លោកឮសួរថាមានការកាប់សម្លាប់នេះ ក្រោយឆ្នាំ១៩៧៩ទេ?

**ឆ៖** គឺនៅពេលដែលលើកទំនប់ ដែលគេនិយាយប្រាប់ កំពុងតែធ្វើការនៅការដ្ឋានអាងត្រពាំងថ្ម បាទ។

**លោក ត្រាវីស ហ្វារ៖**

ខ្ញុំគ្រាន់តែចង់ឲ្យមានការប្រតិចារឹកឲ្យបានត្រឹមត្រូវ។ គឺគាត់បានលើកឡើងផ្នែកតូចនៃចម្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា និងចម្លើយជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត សំណួរចម្លើយទី២៦ គាត់ថាគាត់ជាអនុប្រធានម្នាក់ប្រាប់គាត់ថា ត្រូវយកមនុស្សយ៉ាងតិច១៥នាក់ ទៅសម្លាប់ចោលរាល់យប់។

[០៩:២៥:៥៤]

**លោក វ៉ិចទ័រ កូប៉េ៖**

តាមការពិត អ្វីដែលលោកលើកឡើង គឺខ្ញុំនឹងសួរនៅពេលបន្ទាប់នេះទេ។ អ៊ីចឹងលោកតំណាងសហព្រះរាជអាជ្ញាម៉េចមិនចាំខ្ញុំសួរឲ្យបានចប់សព្វគ្រប់សិន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី អ្នកជាអ្នកដែលប្រាប់លោកថា យ៉ាងហោចណាស់ ក៏គេយកមនុស្ស១៥នាក់ទៅសម្លាប់ចោលរៀងរាល់យប់។ អ្នកណាជាអ្នកប្រាប់លោក?

**លោក តក់ ប៉ុយ៖**

**ឆ៖** បាទ គឺអនុប្រធានខ្ញុំដែលខ្ញុំប្រាប់។

**ស៖** តើគាត់ជាអនុប្រធានកងតូចរបស់លោកហ្នឹង ឬក៏ជាអនុប្រធានកងពីខាងណា?

**ឆ៖** បាទ សព្វថ្ងៃ គាត់អនុភូមិខ្ញុំ មិនមែនខាងកងចល័ត ឬកងអីទេ គឺនៅសម័យនេះ គាត់និយាយប្រាប់។

**ស៖** តើមនុស្សម្នាក់នេះ គឺនៅរស់រានមានជីវិតសព្វថ្ងៃ ហើយជាអនុប្រធានភូមិរបស់លោកហ្នឹង ឬក៏និយាយប្រាប់ ឬក៏ជាអនុប្រធានរបស់លោកកាលពីឆ្នាំ១៩៧៧?

**ឆ៖** អត់ទេ គឺនៅពេលបច្ចុប្បន្ននេះ ជាអនុភូមិ។ ព្រោះកាលនៅសម័យបីឆ្នាំ គឺគេនៅកងផ្សេងពីខ្ញុំ។ ដូច្នេះ គេប្រាប់ខ្ញុំ ប៉ុន្តែដល់បច្ចុប្បន្ន គាត់ជាអនុភូមិខ្ញុំ។

**ស៖** ហើយចុះកាលនៅក្នុងកងចល័តឆ្នាំ១៩៧៧ គាត់មានតួនាទីជាអ្វីដែរ?

**ឆ៖** ខ្ញុំមិនដឹងទេ គាត់ ព្រោះនៅកងផ្សេងគ្នា មិនដឹងគេតួនាទីស្អីយ៉ាងណានោះ គឺខ្ញុំអត់ដឹងទេ ព្រោះកងដាច់ដោយឡែកគ្នា មិនដែលបានទៅរកគ្នារកអីទេ។ អ្នកណាធ្វើការកន្លែងណា គឺនៅកន្លែងនោះ អត់មានសិទ្ធិដើរពាសណាពាសណីទេ។

**ស៖** ប៉ុន្តែនៅពេលនោះ ឬក៏ក្រោយមកនោះ លោកមានបានសួរទេ ថាហេតុអ្វីបានជាគាត់ដឹងថាមនុស្ស១៥នាក់ ត្រូវបានគេយកទៅសម្លាប់រាល់យប់។ ធ្វើម៉េចទើបគាត់ដឹងអំពីការកាប់សម្លាប់នេះ?

**ឆ៖** បាទ អានោះអត់ដឹងទេ កាលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទៅសម្ភាសខ្ញុំបាទ គាត់ក៏នៅនោះ គាត់ក៏បានប្រាប់ថា "សឹងថា ជារៀងរាល់យប់ណ៎ះ ប្រហែលជា១៥នាក់ គេយកទៅសម្លាប់"។ ដូច្នេះ ខាងមជ្ឈមណ្ឌលឯកសារកម្ពុជា គាត់ក៏បានចុះនៅក្នុងទំព័រនោះ។

**ស៖** នៅពេលដែលខ្ញុំអានពាក្យសម្តីរបស់លោកឆ្លើយប្រាប់ទៅមជ្ឈមណ្ឌលឯកសារកម្ពុជា តើត្រឹមត្រូវទេថាពាក្យសម្តីនេះ មិនមែនជាពាក្យសម្តីរបស់លោកទេ ជាពាក្យសម្តីដែលអនុប្រធានភូមិរបស់លោកសព្វថ្ងៃនេះ ប្រាប់លោកទេ។ អ៊ីចឹងត្រឹមត្រូវដែរទេ?

[០៩:២៩:៤៣]

**ឆ៖** បាទ ត្រឹមត្រូវ។ ព្រោះអនុភូមិប្រាប់ខ្ញុំថា "សឹងថាជារៀងរាល់យប់ គឺគេយកទៅសម្លាប់ប្រហែលជា១៥នាក់"។ ដែលខាងមជ្ឈមណ្ឌលឯកសារកម្ពុជា គាត់ក៏បានសរសេរចុះទុកនៅក្នុងនោះ។

**ស៖** ហើយនៅពេលគាត់ឆ្លើយយ៉ាងដូច្នេះ ដែលលោកមានវត្តមានជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា តើអនុប្រធានរបស់លោក គាត់ដឹងថាគាត់ទទួលបានព័ត៌មាននេះពីណាទេ ថាមានគេសម្លាប់មនុស្សចោល ១៥នាក់រាល់យប់? ឬថាតើ គាត់មានប្រាប់ទៅខាងមជ្ឈមណ្ឌលឯកសារកម្ពុជាថា គាត់បានដឹងដោយមូលហេតុអ្វីទេ?

**ឆ៖** បាទ ខ្ញុំមិនដឹងទេ អារឿងការដឹងម៉េចៗនោះគឺនៅលើគេ ខ្ញុំអត់បានដឹងអីសោះ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំសូមបន្តចូលទៅទីកន្លែងមួយជិតការដ្ឋានលើកទំនប់នោះដែរ ដែលលោកបានឆ្លើយថា លោកបានឃើញខ្មោចដែលគេសម្លាប់ចោលហើយ គេកប់ចោលនៅក្បែរទំនប់នោះ នៅកន្លែងនោះ បើខ្ញុំយល់មិនច្រឡំទេ តាមចម្លើយរបស់លោក ឆ្លើយកាលពីម្សិលមិញ គឺថាលោកមិនបានឃើញសាកសពទាំងនោះដោយផ្ទាល់ភ្នែកទេ។ លើកលែងតែគឺដោយសារតែក្លិន ឬដោយសារតែអីនោះទេ ដែលនាំឲ្យលោកនេះឆ្លើយថា មានគេសម្លាប់មនុស្សចោលនៅទំនប់នោះ។ តើអ៊ីចឹងឬក៏យ៉ាងណា?

**ឆ៖** បាទ គឺដូចខ្ញុំបានឆ្លើយម្សិលមិញគឺថា ខ្ញុំទៅបត់ជើងធំនៅខាងត្បូងអាងទឹក ដូច្នេះគឺឃើញរណ្ដៅហើម ហើយស្អុយ។ ដូច្នេះ ខ្ញុំសន្និដ្ឋានថា មានគេសម្លាប់ ព្រោះបើសិនជាមិនមានសម្លាប់គឺរឿងអីក៏ដីប្រេះ។ អានេះខ្ញុំឃើញហ្នឹងភ្នែក ប៉ុន្តែមិនបានឃើញគេយកទៅសម្លាប់ទេ គ្រាន់តែឃើញរណ្ដៅដែលហើម។ ក្រោយមកក៏ខ្ញុំឈប់ទៅបៀតបត់នៅកន្លែងនោះ ខ្ញុំបត់ដែបត់ជើងនៅកន្លែងបង្គន់នេះឯង។

[០៩:៣២:៤៦]

**ស៖** ខ្ញុំយល់ហើយថា នៅពេលនោះ ការដែលនាំឲ្យលោកសន្និដ្ឋានយ៉ាងដូច្នេះ គឺដោយសារតែមានរណ្ដៅ ហើយមានសាកសពនៅក្នុងរណ្ដៅនេះ។ ដូច្នេះ បើខ្ញុំយល់មិនច្រឡំ គឺតាមរយៈសក្ខីកម្មរបស់លោកកាលពីម្សិលមិញ គឺសាកសពទាំងនោះ គឺជាសាកសពសមាជិកកងចល័តដែលត្រូវបានគេកប់នៅទីនោះ។ ចុះការសន្និដ្ឋានបែបនេះ ដោយសារថាលោកមិនបានឃើញការសម្លាប់ មិនបានឃើញសាកសពនោះឲ្យពិតប្រាកដ ហេតុដូចម្ដេចបានជាលោកឈានមកធ្វើសេចក្ដីសន្និដ្ឋានមួយទៀតថា សាកសពទាំងនេះគឺជាសមាជិកកងចល័ត?

**ឆ៖** បាទ ព្រោះនៅកន្លែងនោះ គឺមានតែការដ្ឋានកងចល័តទេ អត់មានអ្នកភូមិអីនៅបៀតទេ បានជាខ្ញុំសន្និដ្ឋានថា ការដែលស្លាប់ គឺមានតែកងចល័តហ្នឹង។

**ស៖** តើលោកយល់ស្របជាមួយខ្ញុំទេថា សពទាំងអស់នេះ វាអាចជាសពអ្នកដែលស្លាប់នៅក្នុងពេលសង្គ្រាម ឬក៏អ្នកដទៃទៀតដែលមិនមែនជាសមាជិកកងចល័ត គ្រាន់តែគេយកមកកប់នៅឯទំនប់ហ្នឹង។ នេះបើខ្ញុំនិយាយថា អ៊ីចេះ លោកយល់ស្របជាមួយខ្ញុំទេ?

**ឆ៖** បាទ ខ្ញុំមិនយល់ស្របទេ ព្រោះកាលសម័យសង្គ្រាម លន់ នល់ គ្មានសាកសពនៅកន្លែងនោះទេ អានេះជាទឹកដីរបស់ខ្ញុំនៅកន្លែងនោះ វាអត់មាន មានតែប្រជាពលរដ្ឋធ្វើស្រែ។ ដល់ថ្ងៃ១៧ មេសារំដោះផុតមក គឺគ្មានសាកសពអីនៅហ្នឹងកន្លែងនោះទេ គឺស្អាតថែស។ ក្រោយពីថ្ងៃ៧ មករា មកដែលមានកងចល័តនៅក្នុងអាងទឹកនោះ គឺគ្មានរណ្ដៅគ្មានអីទេ។ ដូច្នេះ ខ្ញុំបញ្ជាក់ថា គឺស្លាប់ គឺពួកចល័តមិនមែនអ្នកណាទេបាទ។

[០៩:៣៥:០០]

**ស៖** ឥឡូវនេះ ខ្ញុំសូមត្រឡប់ទៅនិយាយអំពីពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោកក្នុងសំណុំរឿង០០៤ លោកមានទម្រង់នៅចំពោះមុខលោកហើយ។ នៅត្រង់ទំព័រទី១ ជាភាសាអង់គ្លេសបានសរសេរថា “នៅក្នុងឆ្នាំ១៩៧៦ ខ្ញុំបានឃើញឈ្លបនាំមនុស្សមួយក្រុមយកទៅសម្លាប់ចោល

នៅខាងត្បូងទំនប់ត្រពាំងថ្មនៅកន្លែងមួយឈ្មោះថា "វាលតាគុយ។" ទី១ លោកនិយាយថាឆ្នាំ១៩៧៦ ហើយលោកបានឃើញសាក្សីដោយផ្ទាល់ភ្នែកថានាំមនុស្សមួយក្រុមយកទៅសម្លាប់ចោលនៅទីនោះ។ នៅក្នុងពាក្យសុំរបស់លោកនេះ ទី១ លោកឆ្លើយថាលោកបានឃើញការនាំខ្លួនយកទៅសម្លាប់ ហើយមួយទៀតលោកឆ្លើយថា លោកគ្រាន់តែបានឃើញសាកសពក្នុងរណ្ដៅ។ តើចម្លើយមួយណាដែលត្រឹមត្រូវនោះ?

**ឆ៖** គឺចម្លើយដែលខ្ញុំឃើញរណ្ដៅ តែការដែលឃើញឈ្លបឃើញអីនាំយកទៅសម្លាប់ចោលនោះគឺមិនពិត មិនដឹង គ្រាន់តែឃើញដែលខ្ញុំជម្រាបជូនថាទៅបត់ជើង ឃើញរណ្ដៅប៉ុណ្ណោះឯង។

**ស៖** សូមអរគុណលោកសាក្សី ខ្ញុំនៅសល់ប្រធានបទពីរបីទៀតទេ។ នៅក្នុងចម្លើយឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា លោកមិនគ្រាន់តែនិយាយអំពីកម្មាភិបាល មិនត្រឹមតែនិយាយអំពីការមកដល់នៃកម្មាភិបាលភូមិភាគនិរតីទៅដល់ភូមិភាគពាយ័ព្យទេ ក៏ប៉ុន្តែក៏មានកម្មាភិបាលភូមិភាគបស្ចិមទៅដល់ភូមិភាគពាយ័ព្យដែរ ជាពិសេសទៅពីកំពង់ឆ្នាំងនេះឯង។ តើធ្វើម៉េចបានជាលោកដឹងថាមានកម្មា-ភិបាលមកពីភូមិភាគបស្ចិមត្រូវទៅ បញ្ជូនទៅភូមិភាគពាយ័ព្យដែរនោះ?

**ឆ៖** បាទ ការដឹងការអីនេះ គឺដឹងតាមប្រធានវរៈ គេប្រាប់ថាពួកកំពង់ឆ្នាំងគេចូលមកកាន់កាប់លើពាយ័ព្យ។

[០៩:៣៨:១១]

**ស៖** ហើយគាត់មានបានប្រាប់លោកទេថា គាត់បានដឹងរឿងហ្នឹងតាមរយៈអ្វីដែរ?

**ឆ៖** បាទ អាការដឹងការអីនេះ គឺខ្ញុំមិនបាននេះផ្ទាល់ទេ គ្រាន់ដូចខ្ញុំបានជម្រាបថាមេប្រធានវរៈនោះគេប្រជុំប្រាប់ថា គឺគេដកបញ្ជូនពួកបស្ចិមចូលមកក្នុងពាយ័ព្យ។

**ស៖** បាទ សូមអរគុណ។ សំណួរមួយទៀតពាក់ព័ន្ធនឹងការចោទប្រកាន់ថាមានការកាប់សម្លាប់ក្នុងចម្លើយរបស់លោកឆ្លើយមជ្ឈមណ្ឌលឯកសារកម្ពុជា អង់គ្លេស ERN 00726121, បារាំង 00743251 និងERN ជាភាសាខ្មែរ 00057741។ លោកមិនគ្រាន់តែនិយាយអំពីការចោទប្រកាន់ថាមានការកាប់សម្លាប់កម្មករដែលជាអតីតទាហាននោះទេ លោកក៏និយាយអំពីប្រជាជនធម្មតា។ សូមដកស្រង់៖ "ជាពិសេសអ្នកបញ្ញាជន និងអ្នកដែលមានចំណេះដឹងខ្ពង់ខ្ពស់" បញ្ចប់ការដកស្រង់ ត្រូវបានយកទៅសម្លាប់ចោល។ ធ្វើម៉េចបានជាលោកដឹងថា មនុស្សប៉ុន្មានប្រភេទអម្បាញ់មិញនេះ ត្រូវបានគេយកទៅសម្លាប់ចោល?

**ឆ៖** បាទ ព្រោះប្រធានវរៈគេហៅពួកមេកងតូច កងតូចប្រជុំ ប្រជុំឲ្យអង្កេត តាមដានមើលថា តើមានពួកបញ្ញវន្ត អ្នកដែលចេះដឹងជ្រៅជ្រះនៅក្នុងកងរបស់លោក ឬអត់ បាទ។ ខ្ញុំដឹងតាមរយៈមេប្រធានវរៈ។

**សៈ** តើលោកចង់មានន័យថាម៉េចដែរ នៅពេលដែលលោកនិយាយបែបនេះនេះ?

**ឆ៖** ខ្ញុំក៏បានឆ្លើយទៅប្រធានវរៈថា កងខ្ញុំបាទមិនមានទេ។ រឿងការចេះដឹងនោះ គឺខ្ញុំមិនដឹងថាគេចេះ ឬក៏មិនចេះទេ។ ឃើញតែធ្វើការសស្រាក់សស្រាំដូចតែពួកខ្ញុំ។ អានេះគេសំដៅបងប្អូនដែលទៅពីភ្នំពេញ ឲ្យពិនិត្យតាមដានអង្កេតមើលថា តើមានពួកបញ្ញវន្តមកដែរឬទេ។ បាទ សូមអរគុណ។

[០៩:៤១:៣៧]

**សៈ** មានសាក្សីមួយចំនួនដែលធ្វើការនៅការដ្ឋានលើកទំនប់នោះដែរ ហើយក៏មានតួនាទីនៅក្នុងកងចល័តដែរ។ ទាំង តាវ៉ាល់, ទាំង តាហ៊ីង្ស គឺថាជាកម្មាភិបាលដែលជាបញ្ញាជនធ្លាប់ធ្វើជាគ្រូបង្រៀនចេញពីភ្នំពេញ ពីកំពង់ចាមជាដើម។ នៅពេលនោះ តើលោកមានបានដឹង ខ្ញុំសួររបៀបផ្សេងវិញ តើលោកដឹងថា តាវ៉ាល់ ជាបញ្ញាជនដែរទេ?

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងទេ មិនដឹងថាគេយ៉ាងម៉េច ចំណេះវិជ្ជាអីគេជ្រៅជ្រះ ឬក៏បញ្ញវន្តអីខ្ញុំអត់ដឹងទេ ដឹងថា តាវ៉ាល់ ៗ ប៉ុណ្ណោះឯង។

**សៈ** ប៉ុន្តែតើលោកធ្លាប់ឮអ្នកណាម្នាក់និយាយអំពីការស្វែងរក ឬក៏ការកំណត់អត្តសញ្ញាណដោយសារថា តើមានអ្នកណាម្នាក់ខិតខំស្វែងយល់ ឬក៏សាកសួរអំពីថា មេដឹកនាំថ្នាក់លើនេះ ក៏ជាបញ្ញវន្តដែរទេ?

**ឆ៖** អត់ទេ ខ្ញុំអត់ដឹងទេរឿងនោះ។

**សៈ** ចុះលោកដែលឮសួរពីកងផ្សេងថា មនុស្សណាត្រូវបានគេកំណត់រកឃើញថា សុំដកស្រង់ជាបញ្ញវន្តដែរទេ នៅកងផ្សេង គេមានរកឃើញមនុស្សណាជាបញ្ញវន្តដែរទេ?

[០៩:៤៣:៣៦]

**ឆ៖** រឿងនោះ អត់ដឹងទេ ព្រោះខ្ញុំនៅកងដាច់ដោយឡែកពីគ្នា ដូច្នេះការដឹង ការឃើញការអីនោះ គឺខ្ញុំអត់ដឹងសោះ បាទ។

**សៈ** ពីរសំណួរចុងក្រោយ អំពីលក្ខខណ្ឌការងារនៅការដ្ឋានលើកទំនប់នៅក្នុង -- លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាថា លោកបានទទួលមុង ដែរ នៅពេលដែលលោកធ្វើការនៅទីនោះ។ តើ

កម្លាំងកងតូចរបស់លោកទាំងអស់ហ្នឹង ឬក៏កម្លាំងកងធំហ្នឹង បានទទួលមុងគ្រប់ៗគ្នា យកមកដេកដែរទេ?

**ឆ៖** ខ្ញុំមិនបាននេះទេ គ្រាន់ថាបានតែទទួលខោអាវ អារឿងមុង អត់បានទេ អត់មានមុង មានអីទេ មានតែខោអាវ ដូចខ្ញុំបានជម្រាបពីម្សិលមិញអ៊ីចឹង។ ហើយនិងការដេកអីនៅនោះ ដូចខ្ញុំបានជម្រាបស្រាប់ហើយ ថាមានបាវមានអីហ្នឹង ធ្វើជាអង្រឹងចងដេក ខ្លះទៅមិនមានបាវ ក៏ពុះឫស្សីធ្វើរនាបដេក។ រឿងការមុង មិនបានទទួលទេ បាទ។ ដូច្នេះប្រហែលជាគាត់សរសេរវាជ្រុល។

**ស៖** បាទ ខ្ញុំសុំបញ្ជាក់ឲ្យច្បាស់ដោយអានសម្រង់របស់លោក គឺ ERN ជាភាសាអង់គ្លេស 00726117, ខ្មែរ 00057737 និងបារាំង 00743247។ សំណួរ៖ "តើលោកមានបំពេញកិច្ចការផ្សេងទៀតទេ?" លោកឆ្លើយថា៖ "អត់ទេ យើងគ្រាន់តែសម្រាកក្រោយពីយើងធ្វើការរួច យើងងូតទឹក ហើយយើងក៏ចងមុងដេកទៅ"។ តើនេះគឺជាចម្លើយរបស់លោកឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ឬមិនមែនជាចម្លើយរបស់លោកទេ?

**ឆ៖** បាទ ការដែលងូតទឹកងូតអីរួច ចងមុងដេក គឺជាមុងយកពីផ្ទះខ្លួនឯងទៅ មិនមែនគេបើកឲ្យទេ។

**ស៖** ដូច្នេះ ចម្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាគឺត្រឹមត្រូវហើយ មែនទេលោក?

**ឆ៖** បាទ។

[០៩:៤៦:៤៩]

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ ថាតើលោកបានដឹងថាមានជនជាតិចាមនៅក្នុងកងរបស់លោក ឬមានជនជាតិចាមនៅក្នុងកងផ្សេងទេ?

**ឆ៖** បាទ អង្កាល់នោះ ខ្ញុំឆ្លើយដែលមានជនជាតិចាមនោះ អាគឺនោះខ្ញុំអត់ទាន់បានចូលនេះទេ គឺនៅក្នុងភូមិ ហៅថាចល័តសហករណ៍។ ដូច្នេះកាលពេលគេយកបាយ យកសម្ល យកអីទៅ គឺខ្ញុំដឹងថាចាមនោះ ដោយសារតែគាត់មិនបានហូបសាច់ជ្រូក។ នេះខ្ញុំសន្និដ្ឋានថា ចាមហើយ បានជាមិនបានហូប ដូច្នេះគាត់ក៏រកអំបិល រកអីហូប បាទ។

**ស៖** ប៉ុន្តែ តើលោកធ្លាប់ឮថា ចាមទាំងនោះត្រូវបានគេបង្ខំឲ្យហូបសាច់ជ្រូក ផ្ទុយទៅនឹងឆន្ទៈ ឬចិត្តមិនហូបរបស់គេទេ?

**ឆ៖** អត់ទេ គេអត់បានបង្ខំទេ។ ការហូបចុកនោះធម្មតា ដូច្នេះឃើញថាគាត់នោះ ពេលដែលគេ

ដួសសម្ល ដួសអីឲ្យទៅ គាត់អត់បានហូបអត់បានអីទេ។ គ្មានបង្ខំ មានអីទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកស្រីចៅក្រម ក្លូដា ហ្វេនស៍!

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** ខ្ញុំមានសំណួរសួរបន្តពីមេធាវីការពារក្តី ខ្ញុំសង្ឃឹមថាគាត់សួរសំណួរនេះទៅហើយ គាត់អត់បានសួរ។ អ៊ីចឹងខ្ញុំសូមសួរបន្ត។ ពីម្សិលមិញលោកបានឆ្លើយថា លោកមិនបានឃើញការសម្លាប់ដោយផ្ទាល់ភ្នែកទេ ដោយសារតែលោកធុំក្លិន និងឃើញទំនប់ហ្នឹងវាប្រេះ។ ហើយមេធាវីការពារក្តីគឺថាលោកលើកឡើងថា លោកបានឃើញគេនាំមនុស្សមួយក្រុមយកទៅសម្លាប់ចោល នេះខ្ញុំ -- ហើយលោកឆ្លើយទៀតថា លោករក្សាឆ្លើយនៅក្នុងតុលាការនេះ។ ខ្ញុំសុំសួរអ៊ីចេះ ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោក តើលោកបានឆ្លើយអ៊ីចឹងទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកស្រីចៅក្រម គឺទម្រង់សុំតាំងខ្លួននៅក្នុងសំណុំរឿង០០៤ ទេ។

[០៩:៤៩:៥៤]

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** លោកមេធាវីការពារក្តីជួយកែតម្រូវខ្ញុំហើយ។ ថាលោកដែលប្រាប់ទៅអ្នកដែលបំពេញទម្រង់ពាក្យសុំជាតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីថា លោកបានឃើញគេនាំមនុស្សយកទៅសម្លាប់ចោលទេ? លោកចាំទេថា លោកបាននិយាយថាអ៊ីចឹងមែនទេ ឬក៏លោកចាំថា លោកមិនបានឆ្លើយដូច្នេះទេ?

**ឆ៖** បាទ ខ្ញុំមិនបានឆ្លើយដូច្នេះទេ ខ្ញុំគ្រាន់តែ -- ដែលខ្ញុំ-- និយាយទៅវាដូចថាដដែលៗមកវិញ។ គឺខ្ញុំទៅបត់ជើង ឃើញរណ្តៅៗសាកសព ហើយហើមប្រេះ ដែលធុំក្លិនស្អុយ ដែលខ្ញុំសន្និដ្ឋានជាខ្មោចចល័ត។

**ស៖** លោកសាក្សី សូមអធ្យាស្រ័យដែលកាត់ផ្តាច់លោក។ ខ្ញុំយល់ហើយចម្លើយរបស់លោក

នៅក្នុងថ្ងៃនេះ គ្រាន់តែបញ្ជាក់ច្បាស់ថា នៅពេលគេបំពេញសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឲ្យលោក លោកមិនដែលបាននិយាយថា បានឃើញគេនាំមនុស្សយកទៅសម្លាប់ចោលដោយផ្ទាល់ភ្នែកទេពិតទេ? លោកពិតជាមិនបានឆ្លើយអ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំមិនបានឆ្លើយអ៊ីចឹងទេ។ វាយូរឆ្នាំ មិនដឹងជាឆ្លើយ ឬក៏យ៉ាងម៉េច ប៉ុន្តែខ្ញុំសន្និដ្ឋានខ្លួនឯងថា ខ្ញុំអត់បានឆ្លើយ ខ្ញុំអត់បានឃើញ។

[០៩:៥១:២៥]

**ស៖** ខ្ញុំយល់ហើយ។ ឥឡូវនិយាយពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកឡើងវិញ នៅក្នុងពាក្យនេះ គឺថាមេធាវីបាននិយាយថាលោកបានផ្តិតមេដៃ។ មុនពេលលោកផ្តិតមេដៃ តើលោកបានអានទម្រង់នេះទេ ឬគេមានអានអំពីទម្រង់ពាក្យសុំនេះឲ្យលោកស្តាប់ទេ ឬលោកចេះតែផ្តិតមេដៃតែម្តង?

**ឆ៖** បាទ ដូច្នេះគឺមុននឹងឆ្លើយ -- មុននឹងគេឲ្យផ្តិតមេដៃ គេអានឲ្យយើងស្តាប់ ក៏ប៉ុន្តែខ្ញុំសូមជម្រាបថា វាយូរឆ្នាំណាស់ទៅហើយ គឺខ្លាចលោះខ្ញុំភ្លេច។ មិនដឹងជាថា ឃើញមែន ឬក៏អត់ត្រង់ណោះ។ សូមបញ្ជាក់។

**ចៅក្រម ក្លូឌា ហ្វេនស័៖**

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សី។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរលោក តក់ ប៊ុយ ខ្ញុំមានសំណួរខ្លីទេ ដើម្បីឲ្យលោកបញ្ជាក់ទាក់ទងទៅនឹងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ លោកបានបញ្ជាក់មួយចំនួនហើយទាក់ទងនឹងការងាររបស់លោក ដែលលោកបានធ្វើការនៅទំនប់ត្រពាំងថ្ម ហើយនិងនៅចម្ការកប្បាសជាដើម ហើយក៏មាន

លោកបានធ្វើការនៅក្នុងកងចល័តភូមិផងដែរ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់នៅរយៈពេលជាក់លាក់ថា ក្នុងទីតាំងមួយដែលលោកធ្វើការ លោកស្ថិតនៅក្នុងទីតាំងនោះរយៈពេលប៉ុន្មាន ឬក៏អាចថាចាប់ពីពេលណាដល់ពេលណា លោកអាចបញ្ជាក់បានទេ?

**លោក តក់ ប៊ុយ៖**

**ឆ៖** បាទ វាយូរឆ្នាំណាស់ទៅហើយ ខ្ញុំចាំអត់បានទេ មិនដឹងថាក្នុងរយៈពេលប៉ុន្មានៗទេ។ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹងឯង វាចាំមិនបាន វាយូរឆ្នាំទៅហើយ មិនដឹងប៉ុន្មានខែ ប៉ុន្មានអី។

[០៩:៥៤:០២]

**ស៖** បាទ សូមអរគុណ។ លោកអាចត្រឡប់ទៅពីពេលកាលបរិច្ឆេទដំបូងបន្ទាប់ពីថ្ងៃ១៧ មេសា ១៩៧៥ លោកនៅហ្នឹងចល័តភូមិ។ លោកអាចបញ្ជាក់ថា លោកធ្វើនៅក្នុងកងចល័តភូមិហ្នឹងប៉ុន្មានរយៈពេលប៉ុន្មាន? បើលោកមិនចាំកាលបរិច្ឆេទជាក់លាក់ លោកអាចបង្ហាញពីចំណុចប្រហាក់ប្រហែលបានទេ?

**ឆ៖** បាទ គឺចល័តនៅក្នុងភូមិ គឺខ្ញុំប្រហាក់ប្រហែលជាថាមួយឆ្នាំចុះ។

**ស៖** បាទ ខ្ញុំចង់បញ្ជាក់បន្ថែម គឺចល័តក្នុងភូមិដែលលោកមានប្រសាសន៍ហ្នឹង គឺនៅក្នុងឃុំប៉ោយចារ ដែលជាស្រុកកំណើតរបស់លោក ភូមិដែលជាស្រុកកំណើតរបស់លោក ឬក៏ភូមិអីដែលលោកអាចបញ្ជាក់ឲ្យច្បាស់បានទេ?

**ឆ៖** បាទ គឺចល័តក្នុងភូមិ ក្នុងឃុំរបស់ខ្ញុំបាទ គឺឃុំប៉ោយចារ។

**ស៖** បាទ សូមអរគុណ ហើយបន្ទាប់ចេញពីប៉ោយចារហ្នឹងមក លោកមកធ្វើការនៅទំនប់ត្រពាំងថ្មហ្នឹងតែម្តង ឬក៏មានចេញទៅកន្លែងណាផ្សេងទៀត?

**ឆ៖** បាទ គឺចេញពីក្នុងភូមិ គឺទៅចល័តនៅគោករំចេក ដកពីគោករំចេកអានោះបានចូលទៅអាងត្រពាំងថ្ម។

[០៩:៥៦:០៩]

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេថា ចល័តនៅគោករំចេកហ្នឹង ជាទីតាំងអ្វីដែរ ជាចល័តស្រុក ភូមិ ឃុំ ហើយមានចម្ងាយប៉ុន្មានពីឃុំប៉ោយចាររបស់លោកនោះ?

**ឆ៖** បាទ អាហ្នឹងចល័តៗក្នុងឃុំ ដកទៅជួយស្ទូងនៅគោករំចេក ចម្ងាយប្រហែលជា២០គីឡូនេះការប៉ាន់ស្មាន ប្រហែលជា២០គីឡូ ចល័តស្រុក។

**សៈ** បាទ សូមអរគុណ។ តើគោករំចេកហ្នឹង ស្ថិតនៅក្នុងស្រុកភ្នំស្រុកដែរទេ?

**ឆៈ** បាទ នៅក្នុងទឹកដីស្រុកភ្នំស្រុក។

**សៈ** លោកនៅក្នុងគោករំចេកហ្នឹង ធ្វើការនៅហ្នឹងបានរយៈពេលប៉ុន្មាន?

**ឆៈ** អានេះការប្រហែលរបស់ខ្ញុំ ប្រហែលជាមួយខែ គោករំចេក។

**សៈ** អ៊ីចឹងបានន័យថា ជារយៈពេលខ្លីទេ ហើយលោកក៏មកធ្វើការនៅទំនប់ត្រពាំងថ្មតែម្តង។ តើអ៊ីចឹងទេ?

**ឆៈ** បាទ។

**សៈ** លោកអាចចាំពេលវេលាជាក់លាក់ ឬក៏កាលៈទេសៈនៅពេលដែលលោកធ្វើការពីចាប់ផ្តើមដំបូងនៃការធ្វើការនៅទំនប់ត្រពាំងថ្ម រហូតដល់ពេលបញ្ចប់ហ្នឹង រយៈពេលប៉ុន្មាន ឬក៏មានកាលៈទេសៈអីដែលអាចឱ្យលោកចាំបាននៅពេលដែលលោកមកធ្វើការដំបូងនៅទំនប់ត្រពាំងថ្ម?

[០៩:៥៨:៣៨]

**ឆៈ** បាទ វាយូរហើយ ខ្ញុំចាំអត់បានទេ។ ខ្ញុំប្រហែលជា គឺនៅឆ្នាំ៧៧ ដែលខ្ញុំមកធ្វើនៅត្រពាំងថ្ម។

**សៈ** បាទ សូមអរគុណ។ បាទ ដោយសារខ្ញុំកំពុងគិតពីពេលវេលាដែលលោកធ្វើការក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោកបានបញ្ជាក់ថា លោកនៅចល័តភូមិរយៈពេលតែមួយឆ្នាំ ប្រហែលមួយឆ្នាំ។ បើអ៊ីចឹង បើពី៧៥ មកដល់៧៦ វាអាចមួយឆ្នាំ ពាក់កណ្តាលឆ្នាំ វាមួយឆ្នាំ ពាក់កណ្តាល៧៦ ហើយលោកទៅគោករំចេកតែមួយខែ អ៊ីចឹងបានន័យថានៅក្នុង៧៦ ដដែល។ បើអ៊ីចឹង តើវាអាចទេ តើលោកធ្វើការនៅក្នុងភូមិនោះ ក្នុងភូមិប៉ោយចាររបស់លោកហ្នឹងរយៈពេលលើសពីមួយឆ្នាំ វាអាចពីរឆ្នាំអីអ៊ីចឹងទៅ លោកអាចគិតសាជាថ្មីបានទេ?

**លោក ត្រាវីស ហ្វារៈ**

លោកប្រធាន ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ។ ខ្ញុំគិតថាការសួរនេះ គឺធ្វើឱ្យសាក្សីភាន់ច្រឡំ។ ដំបូងសួរអំពីកាលបរិច្ឆេទ ហើយបន្ទាប់មកសួរជាចំណុចផ្សេងៗ។ អ៊ីចឹង គាត់ពិបាកនឹងឆ្លើយណាស់។ យើងសួរគាត់ថា គាត់នៅត្រពាំងថ្មណា ហើយគាត់ឆ្លើយថានៅឆ្នាំ៧៧។ ដូច្នេះ សូមមេត្តាកាត់សំណួរឱ្យបានខ្លីៗ ហើយការឱ្យសួរសាក្សី អ៊ីចឹងគាត់ឆ្លើយប៉ាន់ប្រមាណទៅ គឺវាមិនអាចទុកជឿកជាក់បានទេ។ ដូច្នេះ របៀបសួររបស់គាត់នេះ គឺថាមិនត្រឹមត្រូវទេ។ ធ្វើឱ្យសាក្សីហ្នឹង គាត់ពិបាកនឹងការឆ្លើយ

ណាស់។

[១០:០០:៣៦]

**លោក គង់ សំអុន៖**

លោកប្រធាន ខ្ញុំគិតថាការជំទាស់នេះ មិនសមហេតុផលទេ។ ដោយសារតែខ្ញុំកំពុងតែសួរបញ្ជាក់ពីការងារជាក់លាក់ ទីតាំង និងពេលវេលា ដែលសាក្សីបានធ្វើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយអម្បាញ់មិញ ខ្ញុំសួរបញ្ជាក់ចុងក្រោយនេះ ដោយសារតែពេលវេលាដែលសាក្សីផ្តល់ឱ្យនោះ វាមានភាពមិនច្បាស់លាស់។ គាត់និយាយថាគាត់ធ្វើការរយៈពេលមួយឆ្នាំ ប៉ុន្តែគាត់មកធ្វើការនៅក្នុងទំនប់ អាងទំនប់ត្រពាំងថ្មហ្នឹង ឆ្នាំ៧៧។ ដូច្នេះ វាពីរឆ្នាំលើស បាទ។ អ៊ីចឹងបានខ្ញុំចង់ឱ្យសាក្សីបញ្ជាក់សាជាថ្មី បើសិនជាសាក្សីអាច បាទ។

[១០:០១:២១]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:០១:៥១]

**ប្រធានអង្គជំនុំ៖**

បាទ ហើយការជំទាស់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិមានលក្ខណៈសមស្របហើយសំណួរនេះគាត់ឆ្លើយរួចហើយ។ ហើយសមស្រប ឬមិនសមស្រប អង្គជំនុំជម្រះនឹងពិចារណាបញ្ហានេះ។ ហើយរឿង៤០ឆ្នាំជាងកន្លងមកនេះ ហើយមកឱ្យគណនាឱ្យបានជាក់លាក់ សូម្បីតែមីនុតឬក៏ថ្ងៃនោះ ទំនងជាមិនទាន់មានបុគ្គលណាមួយមានសមត្ថភាពធ្វើដល់កម្រិតហ្នឹងបានទេ។

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរចុងក្រោយនេះទេ!

**សួរដោយលោក គង់ សំអុន៖**

**ឆ៖** បាទ ខ្ញុំសូមសួរបន្ត។ ចុះខ្ញុំចង់ឱ្យលោកបញ្ជាក់ថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យលោកធ្វើការស្ថិតនៅក្នុងស្រុក នៅក្នុងភូមិ តំបន់របស់លោកភាគច្រើន។ តើអ៊ីចឹងត្រឹមត្រូវទេ?

**លោក តក់ ប៉ិយ៖**

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** បាទ សំណួរចុងក្រោយ។ តើលោកដែលទៅធ្វើការក្រៅតំបន់ ឬក៏ក្រៅខេត្តរបស់លោកទេ? សូមបញ្ជាក់ឱ្យច្បាស់ គឺក្នុងរបបកម្ពុជាប្រជាធិបតេយ្យដដែល បាទ។

**ឆ៖** បាទ ខ្ញុំបាទមិនដែលមិនបានទៅក្រៅខេត្តទេ គឺតែក្នុង និយាយទៅ នៅក្នុងតំបន់៥តែម្តង។ បើឆ្ងាយពីភូមិ គឺមានតែនៅស៊ីសុផុន ដាំកប្បាស ដកពីអាងត្រពាំងថ្មនោះឯង។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ ហើយដំណើរការសវនាការស្តាប់សក្ខីកម្មសាក្សី តក់ ប៊ុយ បានដល់ទីបញ្ចប់ហើយ អង្គជំនុំជម្រះសូមអរគុណលោក តក់ ប៊ុយ ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សីក្នុងរយៈពេលពីរថ្ងៃកន្លងមកនេះ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនៃរឿងក្តីនេះបាន។ ហើយលោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ សូមលោកជួបតែសំណាងល្អមានសេចក្តីសុខ សេចក្តីចម្រើននៅក្នុងឆាកជីវិតរបស់លោក និងគ្រួសារ។ ហើយរដ្ឋមន្ត្រីបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក តក់ ប៊ុយ វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់ចង់ទៅបានហើយ។

បាទ ហើយសវនាការជាបន្តនៅព្រឹកនេះ គឺអង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-841 ប៉ុន្តែឥឡូវនេះ ដល់ពេលសមស្របសម្រាកហើយ អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់ម្ភៃប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:០៥ នាទី ដល់ម៉ោង ១០:២៥ នាទី)*

[១០:២៦:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ។

មន្ត្រីរដ្ឋបាលតុលាការកោះអញ្ជើញសាក្សី 2-TCW-841 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅ

ចំពោះមុខអង្គអង្គជំនុំជម្រះក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកស្រីសាក្សី! តើលោកស្រីឈ្មោះអី?

**លោកស្រី យី ឡៃសួរ៖**

**ឆ៖** ចាស នាងខ្ញុំឈ្មោះ យី ឡៃសួរ។

**ស៖** នៅក្នុងកំណត់ហេតុលើកមុន លោកស្រីដាក់ថា យីង ឡៃសួរ ឥឡូវនេះ លោកស្រីថា យី ឡៃសួរ។ វាម៉េចបានជាមានបញ្ហានេះកើតឡើង?

**ឆ៖** មិនដឹងថាគេវ៉ៃយ៉ាងណាទេ ស្រាប់តែឃើញអ៊ីចឹងមក ឃើញខុសថា យីង ពីដើមមក ខ្ញុំឈ្មោះ យី។ នៅក្នុងសៀវភៅនុកូលដ្ឋានឈ្មោះ យី។

**ស៖** អ៊ីចឹងលោកស្រី សម្រេចចិត្តថា លោកស្រីប្រើប្រាស់ត្រកូលរបស់លោកស្រីនៅចំពោះមុខអង្គជំនុំជម្រះនេះ គឺ យី ឡៃសួរ អ៊ីចឹងមែនទេ? យី ជាត្រកូល ហើយ ឡៃសួរ ជាឈ្មោះរបស់លោកស្រីអ៊ីចឹងទេ?

**ឆ៖** ចាស។

**ស៖** បាទ មិនអីទេ អរគុណលោកស្រី យី ឡៃសួរ។ តើលោកស្រីកើតនៅថ្ងៃខែឆ្នាំណា លោកស្រីចាំទេ?

**ឆ៖** ខ្ញុំមិនបានជាចាំ។

**ស៖** នៅក្នុងសៀវភៅគ្រួសាររបស់លោកស្រី ក៏ដូចជាអត្តសញ្ញាណប័ណ្ណជាតិខ្មែរ ដាក់ថា លោកស្រីកើតនៅឆ្នាំ១៩៥៨ ត្រឹមត្រូវដែរឬទេ?

**ឆ៖** ចាស។

**ស៖** លោកស្រីមានទីកន្លែងកំណើតនៅទីកន្លែងណា?

**ឆ៖** នៅភូមិប៉ោយស្នួល ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបាត់ដំបង។

**ស៖** អរគុណ ចុះទីលំនៅបច្ចុប្បន្នរបស់លោកស្រី លោកស្រីរស់នៅទីកន្លែងណា?

[១០:៣០:០០]

**ផ៖** នៅភូមិប៉ោយស្នួល ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។

**ស៖** បាទ អរគុណ។ ហើយលោកស្រីប្រកបមុខរបររកស៊ីធ្វើអ្វីដែរសព្វថ្ងៃនេះ?

**ផ៖** ធ្វើស្រែចម្ការ។

**ស៖** អរគុណ។ ហើយឪពុកបង្កើតរបស់លោកស្រីឈ្មោះអី? ម្ដាយបង្កើតរបស់លោកស្រីគាត់ឈ្មោះអី?

**ផ៖** ឪពុកបង្កើតឈ្មោះ យី ឈឿង ម្ដាយឈ្មោះ ភីវ ពិ គាត់បានស្លាប់អស់ហើយ។

**ស៖** បាទ អរគុណ។ ហើយចុះប្ដីរបស់លោកស្រីគាត់ឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ផ៖** ប្ដីខ្ញុំឈ្មោះ លិស លេខ។ ខ្ញុំមានកូនបួននាក់ សុទ្ធតែប្រុស។

**ស៖** អរគុណលោកស្រី យី ឡៃស្រូវ។ ហើយតាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញ ថាតាមសមត្ថភាពដែលលោកស្រីអាចដឹងបាន គឺថាលោកស្រីមិនមានជាប់ញាតិលោហិត ឬញាតិពន្ធជាមួយជនជាប់ចោទទាំងពីររូបគឺ នួន ជា និង ខៀវ សំផន និងបុគ្គលទាំងឡាយត្រូវបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២នេះទេ។ តើពិតមែនដែរឬទេ?

**ផ៖** ចាស ពិតមែន។

**ស៖** ហើយមុនចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ តើលោកស្រីបានស្បថនៅចំពោះមុខអ្នកតាដំបងដែកនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាហើយឬនៅ?

[១០:៣២:០០]

**ផ៖** ចាស ខ្ញុំស្បថរួមហើយ។

**ស៖** ជាបន្តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីកិច្ចដល់លោកស្រី ក្នុងឋានៈលោកស្រីដែលត្រូវឆ្លើយផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះអំពីសិទ្ធិ។ លោកស្រី ឡៃស្រូវ ក្នុងនាមលោកស្រីជាសាក្សីក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកស្រីអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការសុំឱ្យលោកស្រីធ្វើអត្ថាធិប្បាយដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ អំពីករណីយកិច្ច លោកស្រីក្នុងឋានៈជាសាក្សីត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោកស្រី លើកលែងតែសំណួរណា

ដែលឲ្យចម្លើយតប ឬក៏ការធ្វើអត្ថាធិប្បាយតបរបស់លោកស្រីនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯងដូចយើងប្រាប់អំពីសិទ្ធិរួមហើយអម្បាញ់មិញនេះ។ ហើយក្នុងឋានៈជាសាក្សី ត្រូវតែឆ្លើយតែការណ៍ណាដែលពិតដែលបានដឹង បានឮ បានឃើញ បានចាំ បានធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬកហេតុការណ៍ទាំងឡាយដែលកើតមាន ដែលពាក់ព័ន្ធនឹងសំណួរដែលភាគីឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោកស្រី។ ហើយជៀងវាងលោកស្រីឆ្លើយតាមការសន្និដ្ឋាន តាមការយល់ឃើញរបស់ខ្លួន និយាយរួមគឺឃើញយ៉ាងម៉េច ដឹងយ៉ាងម៉េច ឆ្លើយអ៊ីចឹង។ ចំណុចដែលមិនដឹងមិនអាចឆ្លើយតបនឹងសំណួរបានដោយសារមូលហេតុមិនដឹង គឺឆ្លើយថាមិនដឹង នោះក៏ជាចម្លើយតបរបស់សាក្សីផងដែរ។ លោកស្រី យី ឡៃសួរ តើលោកស្រីធ្លាប់បានផ្តល់សក្ខីកម្មនៅចំពោះមុខអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេក្នុងរយៈពេលកន្លងមក? ហើយប្រសិនបើធ្វើៗប៉ុន្មានដង? ធ្វើនៅទីកន្លែងណា នៅពេលណា? លោកស្រីចាំដែរទេ?

[១០:៣៣:៥៧]

ឆ៖ ខ្ញុំអត់ដែលបានឮផង។

ស៖ លោកស្រីដែលត្រូវបានគេសាកសួរទេកន្លងមក រយៈពេលកន្លងមក ដែលបានសួរៗចម្លើយលោកស្រីដែរទេរយៈពេលប៉ុន្មានឆ្នាំកន្លងមក?

ឆ៖ គេសួរខ្ញុំម្តងដែរ ប៉ុន្តែខ្ញុំចាំមិនបាន។

ស៖ លោកស្រីចាំថាគេសួរលោកស្រីនៅទីកន្លែងណា?

ឆ៖ សួរនៅក្រោមផ្ទះកូនប្រធានភូមិ នៅភូមិប៉ោយស្នួល។

ស៖ អរគុណ។ ហើយលោកស្រីចេះអក្សរទេ ចេះអានអក្សរទេ?

[១០:៣៥:០០]

ឆ៖ ខ្ញុំអត់ចេះទេ។

ស៖ ហើយមុននឹងចូលមកផ្តល់សក្ខីកម្មហ្នឹង តើលោកស្រីបានស្តាប់ការអានពីបុគ្គលណាម្នាក់ឲ្យលោកស្រីស្តាប់អំពីអ្វីដែលលោកស្រីបានឆ្លើយផ្តល់ព័ត៌មានដល់អ្នកស៊ើបអង្កេតដែលលោកស្រីបានឆ្លើយថា បានធ្វើនៅកូនផ្ទះប្រធានភូមិនោះដែរឬទេ?

ឆ៖ គាត់បានប្រាប់ដែរ ប៉ុន្តែខ្ញុំចាំមិនបាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយក្នុងការសាកសួរដេញដោលចំពោះសាក្សីរូបនេះអនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ ស្ទួននៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្តី។ សហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរសាក្សីរូបនេះ។

បាទ សូមអញ្ជើញ!

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង លាង៖**

អរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម និងអស់លោក លោកស្រីទាំងអស់ដែលមានវត្តមាននៅក្នុងអង្គសវនាការនាពេលនេះ។ ខ្ញុំបាទឈ្មោះ សេង លាង ជាសហព្រះរាជអាជ្ញារងជាតិនៃការិយាល័យសហព្រះរាជអាជ្ញា។ ថ្ងៃនេះខ្ញុំមានសំណួរមួយចំនួនចង់សួរទៅលោកស្រីសាក្សីឲ្យជួយបំភ្លឺដល់អង្គសវនាការទាំងមូល។

**ស៖** ជម្រាបសួរលោកស្រីជាថ្មីម្តងទៀត។ ហើយសំណួរដំបូងរបស់ខ្ញុំគឺ ខ្ញុំចង់ឲ្យលោកស្រីជួយបញ្ជាក់ថា នៅពេលដែលពួកខ្មែរក្រហមឡើងកាន់អំណាចកាលថ្ងៃ១៧ មេសា ឆ្នាំ៧៥ តើលោកស្រីអាចប្រាប់បានទេលោកស្រីនៅទីណា? ហើយកំពុងធ្វើអ្វី?

**លោកស្រី យី ឡៃស្រូវ៖**

**ឆ៖** ខ្ញុំនៅភូមិប៉ោយស្នួល ឃុំប៉ោយចារ ស្រុកភ្នំស្រុក ហើយកាលសម័យហ្នឹងគេឲ្យខ្ញុំលើកទំនប់ កាប់ចម្ការ រែកដី។

[១០:៣៧:៣៨]

**ស៖** អរគុណលោកស្រី តើលោកស្រីអាចជម្រាបបានទេ លោកស្រីបានមានប្រសាសន៍ថា អត់ច្បាស់ថ្ងៃខែឆ្នាំកំណើត អ៊ីចឹងហើយលោកប្រធានក៏បញ្ជាក់ថាឆ្នាំ៥៨ ។ តើលោកស្រីអាចប្រាប់ទេថា អាយុប៉ុន្មានពេលហ្នឹង?

**ឆ៖** ពេលនោះខ្ញុំប្រហែលអាយុ១៥ ឬក៏ ១៦។

**ស៖** អរគុណលោកស្រី។ លោកស្រីអាចប្រាប់បានទេថា តើពេលហ្នឹងលោកស្រីមានបានទៅធ្វើការនៅក្នុងកងចល័តហើយឬនៅ? ឬក៏យ៉ាងម៉េចដែរ លោកស្រីអាចប្រាប់បានទេ?

**ឆ៖** ទើបចូលបានមុនដំបូង គេប្រើខ្ញុំឲ្យទៅកាប់ចម្ការដាំដំឡូង។

**ស៖** ធ្វើការហ្នឹង ធ្វើការក្នុងលក្ខណៈជាកងអីមួយ ឬក៏យ៉ាងម៉េច លោកស្រីអាចប្រាប់បានទេ?

**ឆ៖** លក្ខណៈជាកងទាំងរយ ទៅកាប់គ្នាជាច្រើន ទៅកាប់ចម្ការ គាស់ចម្ការ ដាំដំឡូង។

**ស៖** តើលោកស្រីអាចប្រាប់បានទេ សមាជិកក្នុងកងលោកស្រីហ្នឹង មានអាយុចាប់ពីប៉ុន្មានទៅដែរ?

**ឆ៖** ចាប់ពីអាយុ ១៤, ១៥ ទៅ ១៦ ឆ្នាំយ៉ាងច្រើន អ្នកតូច អ្នកធំ។ ខ្លះវាតូច ខ្លះវាធំ។

[១០:៤០:០០]

**ស៖** តើកងនោះគេឲ្យឈ្មោះថាកងយ៉ាងម៉េចដែរ កងឈ្មោះវាដូចជាកង -- លោកស្រីមានប្រសាសន៍ថាកងរយអ៊ីចឹង។ តើវាជាឈ្មោះរបស់កងហ្នឹង ឬយ៉ាងម៉េច?

**ឆ៖** ឈ្មោះក្នុងក្រុមគេហៅថា ទាំងមួយក្រុមហ្នឹង គេហៅទាំងមួយកងនោះវាមានរាប់រយមនុស្ស។

**ស៖** អរគុណលោកស្រី។ លោកស្រីអាចប្រាប់បានទេថា តើលោកស្រីធ្លាប់ធ្វើការនៅការដ្ឋានទំនប់អាងត្រពាំងថ្មដែរឬទេនៅក្នុងសម័យខ្មែរក្រហម?

**ឆ៖** ចាស ខ្ញុំធ្លាប់។ ខ្ញុំបានរែកទំនប់អាងនោះចំនួនមួយរដូវប្រាំង។

[១០:៤១:១២]

**ស៖** តើលោកធ្វើការនៅក្នុងកងអីដែរកាលហ្នឹង? កងរយរបស់លោកស្រីហ្នឹង ឬកងថ្មីអីណាមួយទៀត លោកស្រីអាចប្រាប់បានទេ?

**ឆ៖** ខ្ញុំធ្វើការនៅក្នុងកងរយក្នុងឃុំ ក្នុងសង្កាត់ប៉ោយចារ។ គេហៅប្រធានកងរយនៅក្នុងសង្កាត់ក្នុងភូមិឃុំហ្នឹងតែម្ដង។ គេថាចល័តសហករណ៍។

**ស៖** អ៊ីចឹងកងចល័តហ្នឹងលោកស្រីចង់បញ្ជាក់ថា ជាកងរបស់ឃុំដដែល កងរយរបស់លោកស្រីដដែលទេ ឬក៏ម៉េចលោកស្រីអាចបញ្ជាក់ម្ដងទៀតបានទេ ខ្ញុំដូចជាមិនច្បាស់?

**ឆ៖** ក្នុងឃុំៗមួយភូមិប៉ោយស្នូល ឃុំប៉ោយចារនេះ មួយឃុំនេះតែម្ដង។

**ស៖** ចុះលោកស្រីចង់បញ្ជាក់ថា កងចល័តរបស់លោកស្រី គឺជាកងចល័តរបស់ឃុំប៉ោយចារហ្នឹងតែម្ដង មែនទេ?

**ឆ៖** ចាស នៅឃុំប៉ោយចារតែម្ដង។

**ស៖** តើសមាជិកនៅក្នុងឃុំ នៅក្នុងកងឃុំប៉ោយចាររបស់លោកស្រីហ្នឹងមានគ្នាប៉ុន្មានដែរ លោកស្រីអាចប្រាប់បានទេ?

**ឆ៖** មិនដឹងថាប៉ុន្មានទេ ខ្ញុំភ្លាប់អត់បាន។

**ស៖** តើនៅក្នុងកងឃុំប៉ោយចារហ្នឹងមានបែងចែកជាកងតូចៗទៀតដែរឬទេ លោកស្រី?

**ឆ៖** មានៗ កងរយ កង៣០។

**ស៖** តើចែកចេញជាប៉ុន្មានកង ហើយលោកស្រីនៅក្នុងកងមួយណាដែរ?

**ឆ៖** មានបីកង ខ្ញុំនៅកងទី១។

**ស៖** នៅក្នុងកងទី១ លោកស្រីហ្នឹងមានមនុស្សប៉ុន្មាននាក់ដែរ?

**ឆ៖** នៅកងទី១ របស់ខ្ញុំមានមនុស្ស៣៣នាក់។

**ស៖** តើមេកង៣៣ របស់លោកស្រីហ្នឹងជានរណាដែរ?

[១០:៤៥:00]

**ឆ៖** ឈ្មោះមិត្តសោម។

**ស៖** អរគុណលោកស្រី តើលោកស្រីអាចប្រាប់បានទេថា ពេលណាឲ្យពិតប្រាកដដែលលោកស្រីចាប់ផ្តើមទៅធ្វើការនៅការដ្ឋានអាងត្រពាំងថ្មហ្នឹង?

**ឆ៖** ខ្ញុំចាំមិនបានថ្ងៃទីប៉ុន្មាន ខែប៉ុន្មានខ ខ្ញុំចាំមិនបាន។

**ស៖** មុននេះលោកស្រីបានមានប្រសាសន៍ថា នៅក្នុងរដូវប្រាំង តើមែនទេ?

**ឆ៖** ចាស នៅរដូវប្រាំង ខែច្រូតរួច។

**ស៖** តើលោកស្រីអាចប្រាប់បានទេថា លោកស្រីទៅធ្វើការនៅអាងត្រពាំងថ្មហ្នឹងរយៈពេលប៉ុន្មាន ក្រោយពីឆ្នាំជិតសិប -- ១៧ មេសា ឆ្នាំ៧៥ហ្នឹង អាចប្រាប់បានទេ?

**ស៖** ខ្ញុំចាំមិនបាន មិនដឹងថា ប៉ុន្មានខែទេ។

**ស៖** តើលោកស្រីអាចបញ្ជាក់ថានៅក្នុងឆ្នាំភ្លាមបែក ឬក៏រយៈពេលយូរប៉ុន្មាន អាចប៉ាន់បានដែរទេ លោកស្រី?

**ឆ៖** ចាប់ផ្តើមលើកហើយ ដល់ខែធ្លាក់ភ្លៀងមក គឺសម្រាកធ្វើស្រែ។

**ស៖** អរគុណលោកស្រី។ តើលោកស្រី នៅពេលដែលលោកទៅដល់ការដ្ឋានហ្នឹង តើការងារការដ្ឋានហ្នឹងគេចាប់ផ្តើមធ្វើហើយ ឬនៅ?

E1/334.1

**ឆ៖** អត់បានធ្វើទេ ធ្វើជម្រកដោយខ្លួនឯង លីកូនឈើ កាប់ ដូចជាធាងដូង ចំបើងអី លីទៅបាំងខ្លួនឯង នៅខ្លួនឯង។

[១០:៤៧:៥២]

**សៈ** លោកស្រី ប្រហែលជាខ្ញុំសួរសំណួរមិនច្បាស់ទេ។ ខ្ញុំចង់ឲ្យលោកស្រីជួយបញ្ជាក់ថា នៅពេលដែលលោកស្រីទៅដល់ការដ្ឋានអាងត្រពាំងថ្មហ្នឹង តើសកម្មភាពការលើកទំនប់ហ្នឹង ចាប់ផ្ដើមធ្វើហើយ ឬមួយក៏មិនទាន់ធ្វើទេ?

**ឆ៖** អត់ទាន់ធ្វើទេ លើកនឹងកម្លាំងមនុស្សតែម្ដង។

**សៈ** អ៊ីចឹងនៅពេលដែលលោកទៅធ្វើនៅរដូវប្រាំងនោះ លោកស្រីធ្វើបានរយៈពេលប៉ុន្មានបានជាលោកស្រីឈប់ធ្វើការនៅទីនោះវិញ?

**ឆ៖** មិនដឹងរយៈពេលប៉ុន្មានខែទេ ស្រាប់តែធ្លាក់ភ្លៀងមក ឈប់សម្រាក។

**សៈ** តើក្នុងការសាងសង់ទំនប់អាងត្រពាំងថ្មហ្នឹង គេមុននឹងចាប់ផ្ដើម គេមានពិធីសម្ពោធអីណាមួយដែរឬទេ លោកស្រីអាចប្រាប់បានទេ?

**ឆ៖** ប្រឡាយដែលគេលើករួចហើយ គេមានសម្ពោធម្ដង។

**សៈ** លោកស្រីមានប្រសាសន៍ថា សម្ពោធគេធ្វើឡើងនៅពេលលើករួចហើយ មិនមែនពេលចាប់ផ្ដើមដំបូងទេ ឬយ៉ាងម៉េច? អាចបញ្ជាក់បាន?

**ឆ៖** ប្រឡាយដែលលើកហើយ ដែលគេធ្វើរួចហើយ ធ្វើស្ពានហើយ គេសម្ពោធ។

**សៈ** តើលោកស្រីមានបានចូលរួមក្នុងពិធីសម្ពោធនោះដែរឬទេ អ្នកស្រី?

**ឆ៖** ខ្ញុំបាទទៅ បានទៅឃើញគេលេងសិល្បៈឲ្យមើល ហើយខ្ញុំទៅបាន មិនបានដល់ជិតទេ នៅឆ្ងាយ។

[១០:៥០:៥៥]

**សៈ** តើលោកស្រីអាចរៀបរាប់បន្តិចបានទេថា មានអ្វីកើតឡើងខ្លះនៅក្នុងពិធីសម្ពោធនោះក្រៅពីការសម្ដែងសិល្បៈហ្នឹង?

**ឆ៖** ក្រៅពីសម្ដែងសិល្បៈនោះ មានប្រធានឡើងប្ដេជ្ញា ឲ្យប្ដេជ្ញាថា ឲ្យខំលើកទំនប់អាងនេះឲ្យបានសម្រេចជាស្ថាពរ។

**សៈ** លោកស្រីមានប្រសាសន៍ថាប្រធានឲ្យឡើងប្ដេជ្ញា តើប្រធានហ្នឹងគាត់ជានរណាដែរ

លោកស្រី?

**ធ៖** ខ្ញុំមិនបានជាស្គាល់ មិនបានជាចំណាំគាត់ផង។

**ស៖** លោកស្រីអាចបញ្ជាក់បានទេ លោកស្រីនៅចាំបានទេអាពាក្យប្តេជ្ញា គេឲ្យឡើងប្តេជ្ញាហ្នឹង គេឲ្យនិយាយថាម៉េចដែរ លោកស្រី?

**ធ៖** ខ្ញុំចាំមិនបានទេ ខ្ញុំបានភ្លេចអស់ហើយ មិនបានជាញឹកចាំ។

**ស៖** លោកស្រីអាចបញ្ជាក់បានទេ នៅក្នុងពិធីសម្ពោធនុ៎ង តើមានជនជាតិបរទេសចូលរួមដែរឬទេ?

**ធ៖** មិនដឹងតែមាន ឬមិនមាន ព្រោះអីខ្ញុំនៅឆ្ងាយមិនបានចូលដល់ជិត ដែលមនុស្សច្រើនពេក។

**ស៖** ដើម្បីរំឭកការចងចាំរបស់លោកស្រី ខ្ញុំសូមអានឯកសារកិច្ចសម្ភាសន៍របស់លោកស្រីជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/9338, ERN ជាភាសាអង់គ្លេស 00288642, ERN ជាភាសាបារាំង 00339892, ERN ជាភាសាខ្មែរ 00279135។ លោកស្រីបានលើកឡើងថា "ខ្ញុំដឹងថា មានអ្នកធំៗចូលរួម តែខ្ញុំមិនស្គាល់ពួកគេ។ មានពួកចិនមកចូលរួមដែរ ក្នុងចំណោមអ្នកធំៗចូលរួមនោះ មានសម្បុរសបួននាក់ និងសម្បុរខ្មៅពីរនាក់ អ្នកខ្លះធាត់ អ្នកខ្លះស្គម។ ពួកទាំងនោះ មកមើលទំនប់នេះពីរដង គឺនៅពេលចាប់ផ្តើមលើកទំនប់ម្តង និងនៅពេលធ្វើស្ពានម្តង។ ពួកអ្នកដែលមកមើលទំនប់នេះ គឺស្លៀកពាក់ខោអាវពណ៌ខ្មៅ ខ្ញុំឃើញគេដើរត្រួតពិនិត្យទំនប់។" តើអ្វីដែលខ្ញុំអាននេះ អាចឲ្យលោកស្រីចងចាំនូវអ្វីដែលលោកស្រីធ្លាប់ផ្តល់កិច្ចសម្ភាសន៍ពីមុនដែរទេ?

[១០:៥៤:២៤]

**ធ៖** ចាស ពិតមែន ព្រោះអីខ្ញុំភ្លេច។

**ស៖** អរគុណលោកស្រី។ តើលោកស្រីមានដឹងទេ តើនរណាគេជាអ្នកទទួលខុសត្រូវក្នុងការដ្ឋានអាងត្រពាំងថ្មហ្នឹង?

**ធ៖** ទទួលខុសត្រូវអាងត្រពាំងថ្មហ្នឹង ខ្ញុំឮថា ឈ្មោះ តាវ៉ាល់ៗៗ។

**ស៖** តើលោកស្រីមានដឹងថា អ្នកណាគេធំជាង តាវ៉ាល់ ហ្នឹង ទៀតដែរឬទេ មានស្គាល់ដែរ?

**ធ៖** ខ្ញុំអត់ស្គាល់ផង។

**ស៖** នៅពេលធ្វើការអាងត្រពាំងថ្មហ្នឹង តើលោកស្រីមានធ្លាប់ឮឈ្មោះ តាញឹម ដែរឬទេ?

**ធ៖** ធ្លាប់ឮតែឈ្មោះ អត់ដែលឃើញ។

**ស៖** តើលោកស្រីបានឮអ្វីខ្លះពីគាត់ អាចបញ្ជាក់បានដែរទេ?

[១០:៥៦:១០]

**ឆ៖** អត់ដែលឮថាអី គ្រាន់តែឮថាឈ្មោះ តាញ៉ឹមៗ កងខ្លាំងតែប៉ុណ្ណោះ។

**ស៖** តើលោកស្រីអាចដឹងទេថា តាវ៉ាល់ នៅពេលដែលមានបញ្ហាគាត់រាយការណ៍ទៅឯណាដែរ?

**ឆ៖** អត់ដឹងទេ។

**ស៖** នៅពេលដែលធ្វើការនៅទំនប់អាងត្រពាំងថ្មហ្នឹង តើលោកស្រីដែលត្រូវថ្នាក់លើរបស់លោកស្រីហៅឲ្យចូលរួមក្នុងកិច្ចប្រជុំការងារនៅកន្លែងនោះដែរឬទេ?

**ឆ៖** មានគេឲ្យប្រជុំកង៣០ និងកងរយ ថាខំឲ្យសម្រុកធ្វើម៉េចឲ្យបានរួច។

**ប្រធានអង្គជំនុំ៖**

បើកៗ បើកក្បាលមីក្រូហ្វូន!

[១០:៥៧:៣៩]

**សួរដោយលោក សេង លាង៖**

**ស៖** ខ្ញុំនៅមានតែពីរបីសំណួរទៀតទេ ដោយសារតែបញ្ហាពេលវេលា។ អ៊ីចឹង តើលោកស្រីអាច -- អម្បាញ់មិញ លោកស្រីបានមានប្រសាសន៍អំពីកិច្ចប្រជុំដែលលោកស្រីបានចូលរួមប្រជុំកង៣០ និងកងរយនោះ។ តើលោកស្រីអាចរៀបរាប់បានបន្តិចទេ អំពីកិច្ចប្រជុំហ្នឹង គេប្រជុំពីអីខ្លះ ហើយតើលោកស្រីមានដែលឡើងមានយោបល់អី ក្នុងកិច្ចប្រជុំហ្នឹងដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប សាក្សី ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការសិន។

ឈប់អាល កុំអាលឆ្លើយ!

[១០:៥៨:១៨]

**លោកស្រី យី ឡៃសួរ៖**

**ឆ៖** ខ្ញុំគ្រាន់តែចូលរួមជាមួយគេ ខ្ញុំមិនដែលបានឡើងទេ។ គ្រាន់តែស្តាប់ៗ។

**សួរដោយលោក សេង លាង៖**

**ស៖** តើលោកស្រីអាចប្រាប់បានទេ ថានៅក្នុងកិច្ចប្រជុំហ្នឹង គេពិភាក្សាពីបញ្ហាអីខ្លះ?

**ឆ៖** គេពិភាក្សាថា ឲ្យយើងសាមគ្គីគ្នា ធ្វើម៉េចលើកទំនប់នេះឲ្យរួច ឆាប់ៗ។

**លោក សេង លាង៖**

អរគុណលោកប្រធាន ខ្ញុំសូមបញ្ចប់សំណួរប៉ុណ្ណេះ ទុកឲ្យសហការីខ្ញុំ គាត់សួរបន្តទៀត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ចូសេហ្វ អេនត្រូ ប៊ិយលី៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម មេធាវីការពារក្តី សហការី។

**សួរដោយលោក ចូសេហ្វ អេនត្រូ ប៊ិយលី៖**

**ស៖** ជម្រាបសួរលោកសាក្សីដែលបានអញ្ជើញមកថ្ងៃនេះ។ ខ្ញុំសូមសួរបន្តពីសហការីជាតិរបស់ខ្ញុំ។ លោកទើបតែលើកឡើងថា នៅក្នុងអង្គប្រជុំទាំងនោះ លោកនិយាយអំពីការវាយសម្រុក។ សូមលោកពន្យល់បន្ថែមបន្តិចមើល៍ ថាលោកចង់និយាយថាម៉េចពាក្យថា “វាយសម្រុក” នេះ?

[១១:00:00]

**លោកស្រី យី ឡៃស្រូវ៖**

**ឆ៖** ពាក្យថា “វាយសម្រុកនេះ” ឲ្យយើងខំ ខំព្រួតដៃគ្នា ខំឲ្យបានលឿន។

**ស៖** តើគេធ្លាប់ប្រាប់លោកស្រីថា ការងារហ្នឹងត្រូវបញ្ចប់នៅថ្ងៃណាៗទេ ឬក៏គ្រាន់តែថា ការងារនេះត្រូវតែបញ្ចប់ឲ្យបានលឿន?

**ឆ៖** គេអត់បានប្រាប់ថាថ្ងៃណាៗទេ គ្រាន់តែប្រាប់ថា ឲ្យខំ ឲ្យឆាប់បានលឿនកុំឲ្យភ្លៀងមកទាន់។

**ស៖** តើអ្នកណាដែលជាអ្នកឡើងនិយាយនៅក្នុងអង្គប្រជុំនោះ?

**ឆ៖** ប្រធានកង ប្រធានកងវរយ គាត់អ្នកធ្វើការប្រជុំឲ្យគ្រប់ប្រជាជនយើងខំទាំងអស់គ្នា ព្រួតដៃគ្នាខំធ្វើឲ្យបានលឿន កុំទស្សនៈកម្លាំងគ្នា។

**ស៖** ហើយថាតើមេកងវរយនោះ ឈ្មោះ សោម ដែលលោកស្រីបាននិយាយពីឈ្មោះនេះ ពីខាងដើមហ្នឹង ឬក៏យ៉ាងណា?

**ឆ៖** ឈ្មោះ សោម នោះប្រធានកង៣០។ ប្រធានកងវរយនោះ ឈ្មោះ រឿង។

**ស៖** ហើយតើ រឿង នេះ ធ្លាប់ដែលនិយាយប្រាប់ថា គាត់បានព័ត៌មានពីណាមកទេ មុននឹងគាត់

យកព័ត៌មាននោះ យកមកនិយាយប្រាប់ក្នុងអង្គប្រជុំ?

**ឆ៖** គាត់អត់បានប្រាប់ទេថា យកមកពីណាទេ។ គាត់និយាយប្រាប់ក្នុងក្រុមនោះ ក្នុងកងនោះទាំងអស់ថា ឲ្យខំទាំងអស់គ្នា។

[១១:០២:៣០]

**ស៖** តើអង្គប្រជុំបែបនេះ គេធ្វើឡើងញឹកញាប់ទេ?

**ឆ៖** ប្រហែលមួយខែពីរដង។

**ស៖** នៅពេលដែលលោកស្រី និងកងលោកស្រីគេបញ្ជូនទៅឲ្យលើកទំនប់នៅការដ្ឋានទំនប់ត្រពាំងថ្ម លោកស្រីមានជំរើសបដិសេធមិនទៅធ្វើការនៅទំនប់ត្រពាំងថ្មនោះ បានដែរឬទេ?

**ឆ៖** អត់បាន គេត្រូវតែឲ្យទៅ នៅផ្ទះ យើងជិះជាន់កម្លាំងពលកម្មគេ ឲ្យទៅលើកទាំងអស់គ្នា។

**ស៖** ចុះបើសិនជាគេរកឃើញថា លោកស្រីនេះ ជាមនុស្សដែលកេងកម្លាំងគេ ខ្ជិលមិនទៅធ្វើការអ៊ីចឹង បើរកឃើញថាអ៊ីចឹង តើលោកស្រីមានការព្រួយបារម្ភទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

សូមអញ្ជើញលោកមេធាវី គង់សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ ពីព្រោះវាជាសំណួរដែលធ្វើឲ្យសាក្សីឆ្លើយស្មានៗ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ ការជំទាស់របស់មេធាវី គង់ សំអុន ចំពោះការតាំងសំណួរបែបនេះគឺត្រឹមត្រូវហើយ។ មិនគប្បីប្រើសំណួរប្រភេទឧបមានវិធី ឧបមា បើសិនអ៊ីចេះ បើសិនអ៊ីចុះទេ។ សូមសួរនូវអង្គហេតុជាក់លាក់ដែលវាអាចកើត ដែលវាកើតមានហើយសាក្សីដឹង។ មិនអាចឧបមាថាអ៊ីចេះ ឬប្រសិនបើអ៊ីចេះ បើអ៊ីចុះ មិនគប្បីសួរសំណួរបែបនេះទេ សាក្សីកុំឆ្លើយ -- មិនបាច់ឆ្លើយតបនឹងសំណួរនេះទេ។

តទៅមុខទៀត សហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

**ស៖** តើលោកស្រីអាចប៉ាន់ប្រមាណចំនួនមនុស្សសរុបទាំងអស់នៅធ្វើការនៅការដ្ឋានហ្នឹង មានចំនួនប្រហែលជាប៉ុន្មាននាក់ដែរ?

**លោកស្រី យី ឡែស្ងួរ៖**

**ឆ៖** មិនដឹងជាប៉ុន្មានទេ ច្រើនណាស់ ខ្ញុំស្មានមិនត្រូវ។

**ស៖** តើអាចនិយាយថារាប់រយនាក់ រាប់ពាន់នាក់ រាប់ម៉ឺននាក់ គឺរាប់រយពាន់ម៉ឺននាក់បានទេ?

**ឆ៖** រាប់រយពាន់ម៉ឺននាក់ណាស់។ មិនមែនរាប់រយទេ រាប់ពាន់រាប់លានមនុស្ស។

**ស៖** លោកស្រីមានបានឃើញថាមានក្មេងៗ មានកុមារៗធ្វើការនៅការដ្ឋាននោះដែរទេ?

**ឆ៖** មានខ្លះ កន្លែងចល័ត តាវ៉ាល់ មានកុមាររាប់រយដែរ។

**ស៖** លោកស្រីដឹងទេថាកុមារទាំងនោះមានអាយុប៉ុន្មានឆ្នាំដែរ?

**ឆ៖** ប្រហែលអាយុ១៥-១៦។

**ស៖** ហើយតើកុមារទាំងនោះធ្វើការប្រភេទណាដែរ?

**ឆ៖** កុមារទាំងនោះរែកដីដូចតែពួកខ្ញុំ។

**ស៖** តើគេអនុញ្ញាតឲ្យលោកស្រីជ្រើសរើសប្រភេទការងារនៅឯការដ្ឋានហ្នឹងបានដែរឬទេ? លោកស្រី តើគេមានឲ្យជម្រើសលោកស្រីធ្វើការងារនេះ ធ្វើការងារនោះបានទេ?

**ឆ៖** អត់បានទេ។ កន្លែងទៅលើកទំនប់អាង គឺតែអ្នកលើកទំនប់អាងគឺលើក។

[១១:០៧:៤១]

**ស៖** លោកស្រីបានឆ្លើយម្ដងហើយ ប៉ុន្តែខ្ញុំសួរឲ្យចំតែម្ដងថា តើគេចាត់តាំងឲ្យលោកស្រីធ្វើការងារអ្វី?

**ឆ៖** រែកដី។

**ស៖** មានផែនការកំណត់ថាមួយថ្ងៃលោកស្រីត្រូវរែកដីហ្នឹងឲ្យបានប៉ុន្មានដែរទេ?

**ឆ៖** ក្នុងមួយក្រុមខ្ញុំ១០នាក់ គេឲ្យ១០ម៉ែត្រ ទៅ១៥ម៉ែត្រគូប។

**ស៖** លោកស្រីសាក្សី ខ្ញុំសូមអានចម្លើយរបស់លោក ជូនលោកស្រីស្ដាប់ គឺឯកសារE3/9338

ERN ជាភាសាអង់គ្លេស 00288640, ខ្មែរ 0079134, បារាំង 00339890។ សូមដកស្រង់៖ "នៅកន្លែងលើកទំនប់ត្រពាំងថ្ម គេឲ្យយើងរែក៣០ម៉ែត្រគូបក្នុងមនុស្សបីនាក់ ហើយក្រុមខ្លះមិនអាចបញ្ចប់ត្រូវធ្វើការរហូតដល់ពេលយប់ ក្រុមខ្លះទៀតធ្វើមិនហើយត្រូវបានក្រុមដទៃទៀតជួយ"។ សូមលោកស្រីបញ្ជាក់មើលថាតើក្រុមលោកស្រីដែលមានគ្នា១០នាក់ហ្នឹងពិតជាត្រូវគេកំណត់ផែនការឲ្យរែកឲ្យបាន៣០ម៉ែត្រគូបមែនទេ?

**ឆ៖** ចាស ពិតមែន។

**ស៖** ហើយថាតើក្រុមលោកស្រីដែលមានគ្នា១០នាក់ហ្នឹងធ្លាប់ដែលមានពេលណារែកដីមិនហើយ៣០ម៉ែត្រគូបហ្នឹងទេ?

**ឆ៖** មានខ្លះ។ បើរែកមិនហើយពីថ្ងៃ គេឲ្យរែកយប់ទៀត។

[១១:១០:០០]

**ស៖** ហើយលោកស្រីធ្លាប់ដែលរែកមិនហើយរហូតក្រុមលោកស្រីហ្នឹងបន្តរែកនៅពេលយប់ទៀត ដើម្បីធ្វើម៉េចឲ្យសម្រេចផែនការហ្នឹង? ធ្លាប់ដែរទេ?

**ឆ៖** មាន ជួនកាលមាន ខ្ញុំរែកទាំងយប់បានរួច ហើយព្រឹកឡើយវាស់បន្តទៀត។

**ស៖** តើមានពេលណាមួយ សូម្បីតែលោកស្រីបន្តធ្វើការនៅពេលយប់ ហើយនៅតែមិនអាចសម្រេចផែនការហ្នឹងបានទៀត? ធ្លាប់ដែរទេ?

**ឆ៖** ធ្វើដល់យប់មិនហើយ ៗថ្ងៃឡើងគេវាស់បន្ថែមទៀត នាំគ្នាខំឲ្យរួច។

**ស៖** តើមេកងលោកស្រីដែលប្រាប់ទៅលោកស្រីថា បើសិនណាជាធ្វើការមិនបានសម្រេចតាមផែនការទេ នឹងត្រូវគេដាក់ទណ្ឌកម្ម? មេកងលោកស្រីដែលប្រាប់លោកស្រីថាអ៊ីចឹងទេ?

**ឆ៖** ចាស ប្រាប់ ឲ្យខំធ្វើម៉េចឲ្យហើយ បើមិនហើយប្រយ័ត្នថ្ងៃក្រោយមិត្តឯង។

**ស៖** តើមេកងលោកស្រីឬដែលប្រាប់លោកស្រីអំពីថាការបើធ្វើមិនហើយប្រយ័ត្នមានបញ្ហានុ៎ង?

**ឆ៖** ចាស មេកងខ្ញុំ។

[១១:១២:២៤]

**ស៖** ហើយថាតើមេកងលោកស្រីមានប្រាប់លោកស្រីលម្អិតជាងនេះទៀតទេថា បើសិនណាសម្រេចផែនការមិនហើយ វាមានបញ្ហាហ្នឹង ប៉ុន្តែមានប្រាប់បញ្ហាហ្នឹងលម្អិតជាងហ្នឹងទៀតទេ?

**ឆ៖** អត់ទេ គេប្រាប់តែប៉ុណ្ណោះឯង។

**ស៖** លោកស្រីអាចជម្រាបជូនអង្គជំនុំជម្រះបានទេ នៅឯការដ្ឋានលើកទំនប់ហ្នឹងគេឲ្យធ្វើប៉ុន្មានម៉ោងក្នុងមួយថ្ងៃ?

**ឆ៖** ចាប់ពីម៉ោងប្រាំមួយ ដល់ម៉ោងដប់មួយឡើងសម្រាកហូបបាយ ចាប់ពីម៉ោងមួយ ដល់ម៉ោងប្រាំល្ងាច។ ពីម៉ោងប្រាំមួយល្ងាចដល់ម៉ោងដប់យប់។

**ស៖** ចំនួនពេលម៉ោងដែលលោកស្រីទើបជម្រាបអម្បាញ់ហ្នឹង គឺជាពេលម៉ោងរៀងរាល់ថ្ងៃឬយ៉ាងណា?

**ឆ៖** រៀងរាល់ថ្ងៃ។

**ស៖** តើមានថ្ងៃណាមួយនោះ ដែលលោកស្រីធ្លាប់ធ្វើការរហូតដល់ហួសម៉ោងដប់យប់ដែរទេ? ឬក៏ថា សឹមក្រោកពីព្រលឹមស្អែកធ្វើការបន្ត?

**ឆ៖** មិនមានហួសពីម៉ោងដប់ទេ មានតែត្រឹមម៉ោងប្រាំបួន ទៅម៉ោងដប់យប់។

**ស៖** នៅពេលលោកធ្វើការនៅការដ្ឋានលើកទំនប់នោះ លោកស្រីដែលឮសូរថាមានមនុស្សស្លាប់ដោយសារតែពលកម្មបាក់កម្លាំង ឬក៏ដោយសារតែអត់ឃ្លានទេ?

**ឆ៖** គ្រាន់តែឮមិនបានឃើញ។

**ស៖** សូមលោកស្រីប្រាប់បន្តិចមក លោកស្រីឮអ្វីដែរ?

[១១:១៥:០០]

**ឆ៖** ឮថាហូបបាយមិនគ្រប់រែកដីដួលស្លាប់។ ហូបបាយមិនគ្រប់រែកដីទៅសោដួលស្លាប់ទៅ។

**ស៖** តើលោកស្រីធ្លាប់ដែលធ្លាក់ខ្លួនឈឺ ឬក៏ថាទ្រុឌទ្រោមកម្លាំងមែនទែននៅថ្ងៃណាមួយដែរទេ?

**ឆ៖** ខ្ញុំឈឺគ្រុនចាញ់ចំនួនមួយខែកន្លះ ហើយគេបង្អត់បាយខ្ញុំៗរត់មកផ្ទះ។ ឲ្យខ្ញុំមកដេកពេទ្យខ្ញុំខ្លាច ខ្ញុំរត់មកផ្ទះ គេបង្អត់បាយ បានម៉ែខ្ញុំគាត់ឲ្យហូបចែករបបម្នាក់ពាក់កណ្ដាល។

**ស៖** លោកស្រីកើតជំងឺគ្រុនចាញ់នៅឯការដ្ឋានទំនប់ត្រពាំងថ្មហ្នឹង ឬក៏កើតនៅក្នុងអំឡុងពេលផ្សេង?

**ឆ៖** ខ្ញុំគ្រុននៅកន្លែងអាងត្រពាំងថ្មៗ ខ្ញុំលើកទំនប់អាងត្រពាំងថ្ម ខ្ញុំគ្រុនគេបញ្ជូនមកដេកពេទ្យឃុំប៉ោយចារ។

**ស៖** លោកស្រីបានឆ្លើយថា គេបានដកហូតរបបអាហារលោកស្រីនៅពេលលោកស្រីកើតជំងឺ

គ្រុនចាញ់។ លោកស្រីសូមពន្យល់តិចមើល៍ ម៉េចបានជាគេកាត់របបអាហារលោកស្រី?

**ផ៖** ថា ខ្ញុំរត់ចោលកន្លែងការដ្ឋាន ហើយគេអត់ឲ្យរបបខ្ញុំហូបទេ ដល់ខ្ញុំមកនៅ -- ឲ្យខ្ញុំមកដេកពេទ្យ ខ្ញុំអត់នៅ ខ្ញុំរត់មកផ្ទះ ទៅគេអត់ឲ្យហូប អត់ឲ្យរបបហូប។

**ស៖** អ្នកណាបញ្ជូនលោកស្រីពីការដ្ឋានលើកទំនប់ហ្នឹងទៅមន្ទីរពេទ្យហ្នឹង?

**ផ៖** ប្រធានកងរយ។

**ស៖** ហើយថាតើលោកស្រីកើតជំងឺគ្រុនចាញ់នេះអស់រយៈពេលប៉ុន្មានដែរទើបគេបញ្ជូនលោកស្រីទៅមន្ទីរពេទ្យ?

**ផ៖** ខ្ញុំគ្រុនញាក់ចំនួនមួយអាទិត្យគេបញ្ជូនខ្ញុំមកមន្ទីរពេទ្យ ខ្ញុំដេកពេទ្យបានបីថ្ងៃ ខ្ញុំរត់ទៅផ្ទះ។

**ស៖** ហើយនៅពេលដែលលោកស្រីកើតជំងឺគ្រុនចាញ់ ជំងឺគ្រុនញាក់ហ្នឹង ពេលហ្នឹងគឺថាលោកស្រីកើតជំងឺគ្រុនញាក់ហ្នឹងធ្ងន់ធ្ងរ ឬក៏យ៉ាងម៉េច?

**ផ៖** ចាស គ្រុនញាក់ធ្ងន់ធ្ងរហ្នឹង ខ្ញុំក្រោកដើរអត់រួច។ អត់បានហូបបាយបីពេលបានខ្ញុំរត់ទៅដល់ផ្ទះបានម៉ែខ្ញុំចែករបបបានពាក់កណ្ដាលម្នាក់បានហូបហើយបានមាខ្ញុំគាត់ឲ្យថ្នាំពីរគ្រាប់ទៅលេបទៅបានៗជាចំនួនបីអាទិត្យ ខ្ញុំលេបថ្នាំតែចំនួនបីថ្ងៃ ខ្ញុំជា។ ដែលខ្ញុំឈឺចំនួន តាំងពីខ្ញុំចាប់ផ្ដើមឈឺរហូតទើបខ្ញុំជាប្រហែលជាងមួយខែ។

[១១:១៩:២៤]

**ស៖** សូមសួរបញ្ជាក់ឲ្យលោកស្រីជម្រាបមកខ្ញុំផង ក្រែងលោខ្ញុំយល់ខុស។ លោកស្រីកើតជំងឺគ្រុនញាក់នេះអស់រយៈពេលមួយអាទិត្យនៅការដ្ឋានទំនប់ត្រពាំងថ្មមុនគេបញ្ជូនលោកស្រីទៅមន្ទីរពេទ្យ។ ខ្ញុំចង់ដឹងថា នៅពេលលោកស្រីកើតជំងឺគ្រុនញាក់នេះ លោកស្រីនៅតែធ្វើការដដែលឬមុនគេបញ្ជូនទៅមន្ទីរពេទ្យ?

**ផ៖** ខ្ញុំទើបញាក់ក្នុងមួយថ្ងៃតែមួយដង នោះខ្ញុំទៅធ្វើការបានមួយពេលៗ ដល់ខ្ញុំញាក់មួយថ្ងៃពីរដង ខ្ញុំបានដេកនឹងកន្លែងការដ្ឋាននោះ តែចំនួនបីថ្ងៃទេ គេបញ្ជូនមក។

**ស៖** សូមអរគុណលោកស្រី។ នៅពេលដែលលោកនៅឯការដ្ឋាន លោកស្រីដែលឮសួរគេៗថាមនុស្សណានោះ ជាមនុស្សខ្ជិលច្រអូសអីដែរទេ?

**ផ៖** មានគេថាខ្លះ បើយើងឈឺ គេថាយើងឈឺសតិអារម្មណ៍។ ដូចប្រៀបឧបមាថា គ្រុនឈឺក្បាលវិលមុខបន្តិចបន្តួច ខាងគេលើកឡើងទិតៀនថា យើងឈឺសតិអារម្មណ៍ ជិះជាន់កម្លាំងពលកម្មគេ។

**សៈ** ហើយតើមានអ្វីកើតឡើងចំពោះមនុស្សដែលគេចោទប្រកាន់ថា ឈឺសតិអារម្មណ៍ ឬក៏ខ្ជិលច្រអូសអីហ្នឹង មានអ្វីកើតឡើងចំពោះអ្នកទាំងនោះ?

**ផះ** មានអ្វីកើតឡើងយ៉ាងម៉េច ខ្ញុំស្ដាប់មិនបាន។

**សៈ** យើងកំពុងតែនិយាយគ្នាថា មានការចោទប្រកាន់ទៅលើមនុស្សខ្លះ គេងកម្លាំងពលកម្មគេ ឬឈឺសតិអារម្មណ៍។ អ៊ីចឹងហើយបានខ្ញុំសួរថា តើមានអ្វីកើតឡើងទៅអ្នកដែលគេចោទថា ខ្ជិលច្រអូស ឬមានជំងឺសតិអារម្មណ៍។ តើវាមានបញ្ហាអ្វីកើតឡើងដល់អ្នកដែលគេចោទប្រកាន់ទាំងនោះទេ?

**ផះ** គេគ្រាន់តែធ្វើការកសាងទិតៀនឲ្យយើងដឹងខ្លួនសាជាថ្មី។

[១១:២២:១៧]

**សៈ** លោកស្រីធ្លាប់ដែលគេហៅថា "កងករណី" ធ្លាប់ដែលឮអ៊ីចឹងទេ?

**ផះ** ចាស ឮ។ កងករណី ជិះជាន់កម្លាំងពលកម្មគេ។

**សៈ** ហើយលោកស្រីដឹងថា គេធ្វើយ៉ាងម៉េច ឬក៏គេប្រព្រឹត្តយ៉ាងម៉េច ចំពោះអ្នកស្ថិតនៅក្នុងកងករណីនេះទេ?

**ផះ** មិនដឹងគំនិតគេគិតយ៉ាងណាទេ ខ្ញុំមិនយល់ទេត្រង់នោះ។

**សៈ** តើលោកស្រីមានដឹងថា សមាជិកកងករណីត្រូវបានគេប្រព្រឹត្តដូចគ្នានឹងសមាជិកកងធម្មតាដែរឬទេ ដូចជារបបអាហារ ចំនួនពេលម៉ោងការងារ ជាដើម។ល។

**ផះ** អ្នកខ្ជិលគឺគេចាំឲ្យក្រោយ អ្នកដែលគេកម្លាំងពលកម្មពេញគេឲ្យមុន ប៉ុន្តែឲ្យតិចជាងអ្នកកម្លាំងពលកម្មពេញ។

**សៈ** លោកស្រីដែលឮថាការដ្ឋានទំនប់ត្រពាំងថ្មនេះ ត្រូវបានគេហៅថាជាសមរភូមិក្ដៅដែរទេ?

**ផះ** ចាស ឮ។

**សៈ** ហើយនៅពេលដែលគេនិយាយថាវាជាការដ្ឋានក្ដៅអ៊ីចឹង លោកស្រីយល់ថាម៉េចដែរ ពេលនុ៎ង?

**ផះ** យល់ថា ឲ្យយើងខំ។

**សៈ** ហើយលោកស្រីឮពីអ្នកណា? អ្នកណាជាអ្នកនិយាយថា ការដ្ឋាននេះជាសមរភូមិក្ដៅ?

[១១:២៥:០០]

**ផះ** ប្រធានកងរយដែលគេឲ្យ ដែលគេដឹកនាំ។

**សៈ** លោកស្រីដែលឃើញមានឆ្មាំ ឬក៏ថាកម្មាភិបាលណាស្ពាយកាំភ្លើងនៅឯការដ្ឋាននោះទេ?

**ឆៈ** ខ្ញុំអត់ដែលឃើញទេ។

**សៈ** លោកស្រីដែលឮសួរគេទាត់ធាក់ ឬក៏វាយដំសមាជិក ឬក៏ថាកម្លាំងដែលធ្វើការនៅឯការដ្ឋាននោះដែរឬទេ?

**ឆៈ** ខ្ញុំ អង្គុយឃើញតែ ដែលគេឲ្យខ្ញុំយាមយប់ ឃើញដែលគេចាប់យកទៅមួយខ្សែ ដែលខ្ញុំអង្គុយយាម។ គេយកទៅសម្លាប់ តែមាត់ស្រែកថា “បងអើយ! ខ្ញុំខុសរឿងអី លែងខ្ញុំទៅ កូនខ្ញុំមិនដឹងនៅឯណា”។ មិនដឹងថាឆ្ងាយ ឬជិត ឮតែសំឡេងទេ យប់។

[១១:២៦:២៥]

**សៈ** ប្រហែលជាសំណួរខ្ញុំវាមិនច្បាស់ទេមើលទៅ។ ខ្ញុំចង់ -- ខ្ញុំនឹងសួរព្រឹត្តិការណ៍នេះនៅពេលក្រោយ តែពេលនេះគ្រាន់តែសួរថាតើលោកស្រីធ្លាប់ដែលឃើញ ឬក៏ធ្លាប់ដែលឮថាត្រូវបានសមាជិកនៃកងចល័តណាមួយនោះ ត្រូវបានគេវាយនឹងរំពាត់ ឬក៏ត្រូវបានគេទាត់ធាក់អីដែរទេ?

**ឆៈ** មិនដែលឃើញទេ។ គ្រាន់តែឮ តែខ្ញុំអត់ដែលឃើញផ្ទាល់។

**សៈ** លោកស្រីឮគេថា យើងម៉េចដែរ?

**ឆៈ** ឮគេថា រែកដីមិនរួច គេទាត់ គេធាក់។

**សៈ** តើគេដែលឲ្យលោកស្រីសរសេរប្រវត្តិរូបដែរឬទេ នៅពេលលោកស្រីធ្វើការនៅការដ្ឋានលើកទំនប់នោះ?

**ឆៈ** អត់ដែលទេ ខ្ញុំមិនចេះអក្សរ។

**សៈ** តើលោកស្រីមានបានដឹងពីវិធីសាស្ត្រនានា របៀបនានា ដែលគេយកមកប្រើប្រាស់ដើម្បីស្រង់ប្រវត្តិរូបទេ ដូចជាការសួរដោយផ្ទាល់មាត់ ឬក៏ដោយវិធីណាមួយ?

**ឆៈ** អត់ដែលទេ។ អត់ដែលមានអ្នកណាសួរខ្ញុំទេ។

**សៈ** តើលោកស្រីមានដឹងថា គេមានតាមដានកម្មករ ពលករ ដែលធ្វើការនៅទីនោះ មានមេៗគេតាមដានអ្នកទាំងនោះដែរទេ?

**ឆៈ** មិនដែលដឹងទេ ខ្ញុំកាលនោះ ខ្ញុំនៅស្ទើរដែរ។

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលីៈ**

លោកប្រធាន ប្រហែលជាដល់ម៉ោងឈប់សម្រាកហើយមើលទៅ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។

អរគុណសាក្សី លោកស្រី ឡៃ ស្ងួរ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅរសៀលនេះ វេលាម៉ោងមួយកន្លះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះ នៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:២៩ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:៣៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា រួមទាំងក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយដើម្បីតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ ហើយបញ្ជាក់ថា នៅសល់តែមួយវគ្គសវនាការទៀតទេភាគីទាំងពីរនេះ។

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

*(គ្មានការបកប្រែ)*

**សួរដោយលោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

**ស៖** នៅពេលលោកស្រីធ្វើការនៅទំនប់ត្រពាំងថ្មនោះ លោកស្រីដឹងថាកម្មាភិបាលភូមិភាគនិរតី

មកដល់នៅពេលណាទេ?

**លោកស្រី យី ឡែស្សូរ៖**

**ឆ៖** ខ្ញុំអត់ដឹងទេ។

**ស៖** លោកស្រីមានបានដឹងការផ្លាស់ប្តូរមេដឹកនាំ ថ្នាក់ដឹកនាំនៅទីនោះទេ នៅពេលលោកស្រីនៅការដ្ឋានទំនប់ត្រពាំងថ្ម?

**ឆ៖** ខ្ញុំអត់ដឹងផង។

**ស៖** លោកស្រីមានដឹងអ្នកណាម្នាក់ដែលធ្លាប់ធ្វើការនៅរបបលន់ នល់ ជាទាហាន ឬក៏ជារដ្ឋការធ្វើការនៅឯទំនប់ត្រពាំងថ្មនោះដែរទេ?

**ឆ៖** អត់ទេ ខ្ញុំអត់បានដឹងទេ ព្រោះអីខ្ញុំនៅស្មើរដែរ។

[១៣:៣២:៤៥]

**ស៖** លោកស្រីដឹងថា មានអ្នកណាម្នាក់នៅការដ្ឋានទំនប់ត្រពាំងថ្ម មានជាប់សាច់ញាតិជាវៀតណាម សាច់ឈាមជាវៀតណាមអីដែរទេ?

**ឆ៖** អត់ដឹងទេ។

**ស៖** លោកស្រីដឹងថាមានចាមធ្វើការនៅការដ្ឋាននោះដែរទេ?

**ឆ៖** អត់ដឹងថា ចាមទេ ខ្ញុំដឹងតែខ្មែរៗប៉ុណ្ណោះឯង។

**ស៖** លោកស្រីធ្លាប់ឮថាមានអ្នកណាម្នាក់ធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម ត្រូវបានគេហៅថាជាប្រជាជន ឬប្រជាជន១៧មេសា ទេ?

**ឆ៖** បាន តែឮប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន។

**ស៖** ចុះលោកស្រីយល់ថា ប្រជាជនថ្មី និងប្រជាជនមូលដ្ឋានហ្នឹងមានលក្ខខណៈខុសគ្នាយ៉ាងដូចម្តេចដែរ?

**ឆ៖** ថាប្រជាជនថ្មី គ្រាន់តែថាដឹងតែគេមកពីថាទីក្រុងភ្នំពេញ។ ខ្ញុំដឹងប៉ុណ្ណោះ។

**ស៖** លោកស្រីត្រូវបាន -- តើលោកស្រីជាប្រជាជនថ្មី ឬក៏ជាប្រជាជនមូលដ្ឋាន?

**ឆ៖** ប្រជាជនមូលដ្ឋាន។

**ស៖** តើលោកស្រីដឹងថាប្រជាជនថ្មីនេះ ត្រូវបានគេប្រព្រឹត្តខុសពីប្រជាជនមូលដ្ឋាន ឬយ៉ាងណា?

[១៣:៣៥:២០]

**ធ៖** កាលដែលនៅក្នុងភូមិខ្ញុំ ខ្ញុំដឹងមកដល់ ប៉ុន្តែគ្រាន់តែថា ដូចៗតែគ្នា។

**ស៖** តើមានប្រជាជនថ្មីដែរទេ នៅកងរបស់លោកស្រី?

**ធ៖** មានខ្លះ។

**ស៖** លោកស្រីសាក្សីនៅពេលលោកស្រីនៅឯទំនប់ត្រពាំងថ្មហ្នឹងធ្លាប់ដែលបានឃើញការចាប់ខ្លួនមនុស្សទេ?

**ធ៖** ឃើញក្នុងមួយថ្ងៃនោះ ខ្ញុំនៅយាម ឃើញមនុស្សប្រហែលប្អូនប្រាំដណ្ដប់នាក់ ឬក៏២០នាក់តាមស្មាន មិនបានឃើញជិត ឃើញឆ្ងាយ។

**ស៖** លោកស្រីចង់មានន័យថាម៉េច ថាមានគេឈរយាមលោកស្រី គេយាមដើម្បីអ្វីពេលនោះ?

**ធ៖** ខ្ញុំ គេឲ្យខ្ញុំនៅយាមកន្លែងដែលខ្ញុំនៅ គេឲ្យខ្ញុំយាម បើឃើញអ្នកណាដើរ គេឲ្យខ្ញុំប្រាប់គេ។ ដល់ម្ល៉ោះហើយ ខ្ញុំឃើញអ្នកដែលគេចាប់នោះ មិនដឹងថាអ្នកខាងណាទេ ប៉ុន្តែខ្ញុំយាមយប់ ឃើញ គេដើរចម្ងាយពីខ្ញុំប្រហែល ១០០ម៉ែត្រ ២០០ម៉ែត្រ។

**ស៖** លោកស្រីដឹងថា អ្នកដែលចាប់ខ្លួនគេហ្នឹងជាអ្នកណាដែរ?

**ធ៖** អត់ដឹងទេ។

**ស៖** ចុះលោកស្រីដឹងទេ ស្គាល់ទាំងប្រជាជនដែលគេចាប់ខ្លួន និងអ្នកដែលចាប់ខ្លួនគេហ្នឹងជាអ្នកណាដែរទេ?

**ធ៖** អត់ដឹងទេ។

**ស៖** លោកស្រីអាចជម្រាបអង្គជំនុំជម្រះបានទេ ថាប្រជាជនដែលគេចាប់ហ្នឹង ពេលហ្នឹងមានគេចងៗ ដែរអីទេ?

**ធ៖** តាមខ្ញុំស្មាន ខ្ញុំថាគេចង ព្រោះអីគាត់អត់រត់រួច ឃើញគាត់ដើរទាំងខ្សែទៅ ដើរបណ្ដោយគ្នាទៅ។

[១៣:៣៨:៤៥]

**ស៖** ប្រជាជនដែលគេចាប់ខ្លួនហ្នឹង តើមានទាំងស្រីទាំងប្រុស ឬក៏តែជាប្រុស ឬជាស្រីសុទ្ធ?

**ធ៖** មានប្រុសមានស្រី សំឡេងស្រែក។

**ស៖** លោកស្រីឮសូរគាត់ស្រែកថា ដូចម្ដេចដែរ?

**ឆ៖** គាត់ស្រែកថា "បងអើយខ្ញុំខុសអី លែងខ្ញុំទៅ"។

**ស៖** ក្នុងពេលគេចាប់ខ្លួនហ្នឹង លោកស្រីមានស្ដាប់ឮអ្វីទៀត ក្រៅពីសម្រែកនេះទេ?

**ឆ៖** ឮ តែស្នូរដំបងគេវ៉ៃភូសៗ ស្ងាត់សំឡេងទៅ។

**ស៖** លោកស្រី នៅពេលលោកស្រីស្ដាប់ឮគឺថាគេវាយភូសៗហ្នឹង លោកស្រីមានឃើញទេ ឃើញគេវាយនឹងដំបង ឬអ្វីទេ?

**ឆ៖** អត់ឃើញទេ គ្រាន់តែឮ មិនប៉ានមើល មិនប៉ានស្ដាប់។

**ស៖** ហើយនៅពេលលោកស្រីឮស្នូរសម្រែកពីគេវាយ ហើយស្រែកអ៊ីចឹងហ្នឹង តើសម្រែកនេះសម្រែកបែបម៉េច លោកស្រី?

**ឆ៖** សម្រែកស្រែកថា "អូយជួយខ្ញុំផង! បងអើយខ្ញុំខុសអី?"។

**ស៖** ប្រជាជនដែលគេចាប់ខ្លួនហ្នឹង លោកស្រីឃើញគេចងប្រហែលជាប៉ុន្មាននាក់?

**ឆ៖** តាមដែលខ្ញុំឃើញប្រហែល ១៥ ឬក៏ ២០ នាក់។

**ស៖** ហើយថាតើលោកស្រីធ្លាប់ឃើញគេចាប់មនុស្សពី ១៥ ទៅ ២០ ហ្នឹងប៉ុន្មានដងដែរ?

**ឆ៖** ឃើញម្ដង។

[១៣:៤២:២០]

**ស៖** លោកស្រីសាក្សី ខ្ញុំសូមអានចម្លើយរបស់លោកស្រី គឺឯកសារ E3/9338, ERN អង់គ្លេស 00288641, ខ្មែរ 00279134, បារាំង 00339891។ លោកស្រីបានឆ្លើយនៅក្នុងកំណត់ហេតុរបស់លោកស្រីថា "មិនមានអ្នកណាម្នាក់ក្នុងក្រុមខ្ញុំត្រូវបានគេចាប់ខ្លួនទេ ប៉ុន្តែមានមនុស្សពីក្រុមផ្សេងជាច្រើនត្រូវបានគេចាប់ខ្លួន ចងនាំខ្លួនយកចេញទៅ។ ខ្ញុំដឹងថាមានប្រជាជនជាច្រើននៅក្នុងកង តាវ៉ាល់ ស្លាប់។ ជួនពេលខ្លះ មនុស្សគឺថាដួលស្លាប់នៅពេលលើកទំនប់នោះតែម្ដង។ នៅពេលដែលខ្ញុំយាមនៅពេលយប់ ខ្ញុំឃើញមនុស្សមួយខ្សែគេបណ្ដើរចេញទៅ គេចង ហើយក្នុងមួយខ្សែមានប្រហែលជា១៥ ទៅ ២០នាក់ ទាំងប្រុស ទាំងស្រី។ ខ្ញុំបានឃើញព្រឹត្តិការណ៍បែបនេះ ការចាប់ខ្លួនបែបនេះ បីដង។" តើចំណុចនេះវាជួយរំឭកដល់ការចងចាំរបស់លោកស្រីទេថា លោកស្រីបានឃើញគេបណ្ដើរមនុស្សពីរបីខ្សែក្នុងមួយខ្សែ ១៥ ទៅ ២០ នាក់ មានប្រុស មានស្រី? ហើយព្រឹត្តិការណ៍នៃការចាប់ខ្លួនចងបណ្ដើរបែបនេះ គឺថាលោកស្រីបានឃើញបីលើក។ លោកស្រីចាំទេ?

**ឆ៖** មិនចាំទេ។

**ស៖** នៅពេលដែលលោកស្រីឃើញព្រឹត្តិការណ៍បែបនេះ គឺការចាប់ខ្លួន និងការវាយមនុស្សទាំងប្រុសទាំងស្រីពី ១៥ ទៅ ២០ នាក់យ៉ាងដូច្នេះ តើលោកស្រីធ្លាប់ដែលសួរអ្នកណាម្នាក់ថា ហេតុអីបានជាគេចាប់ខ្លួនយ៉ាងហ្នឹង? ហើយហេតុអីបានគេវាយដំមនុស្សយ៉ាងហ្នឹងទេ?

**ឆ៖** មិនប៉ានសួរទេ។

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប សាក្សី។ សូមអញ្ជើញលោកមេធាវី គង់ សំអុន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមកត់សម្គាល់ ក៏ដូចជាការជំទាស់ផងដែរ ចំពោះការសង្ខេបនូវអង្គហេតុរបស់សហព្រះរាជអាជ្ញា តំណាងសហព្រះរាជអាជ្ញា ដែលថាសាក្សីបានឃើញ និងបានស្តាប់ឮការវាយដំនេះ តែការពិតសាក្សីកន្លងមកបានបញ្ជាក់ថា គាត់បានឮសូរ ប៉ុន្តែមិនបានឃើញទេ ការវាយដំហ្នឹង គ្រាន់តែជាការឮសូរសម្រែក ស្រែកនៅពេលដែលមានការវាយដំ។ ហើយដូចគ្នាផងនៅពេលដែលសហព្រះរាជអាជ្ញារងលើកអំពីការចង គឺគាត់ (សាក្សី) មិនបានថាគាត់ឃើញចងទេ តែជាការសន្និដ្ឋានរបស់សាក្សីប្រហែលជាចងបណ្តើរ។ បាទ ដូច្នេះសុំឲ្យសហព្រះរាជអាជ្ញាកុំធ្វើការសន្និដ្ឋានទៅលើអង្គហេតុដែលនាំឲ្យមានការភ័ន្តច្រឡំ។ សូមអរគុណ។

[១៣:៤៥:៤៧]

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបខ្លីទេ។ ខ្ញុំយល់ស្របថា សាក្សីនិយាយថា គាត់បានឮគេស្រែក ឮគេវាយ ប៉ុន្តែមិនបានឃើញគេនៅក្នុងពេលចាប់ខ្លួននោះទេ។ គាត់បានថាដូច្នេះមែន។ គាត់ឃើញ -- គាត់គ្រាន់ថាគាត់ឃើញគេចងៗពីមួយទៅមួយនោះ។ ដូច្នេះ បើសិនជាអនុញ្ញាតខ្ញុំសូមកែតម្រូវថា គាត់បានឮសូរៗគេវាយដំអ្នកទាំងនោះ ប៉ុន្តែមិនបានឃើញទេ។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញបន្តទៅទៀត។

**សួរដោយលោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

**ស៖** លោកស្រីខ្ញុំសូមរៀបសំណួរឡើងវិញ។ នៅពេលលោកស្រីឃើញការចាប់ខ្លួនប្រជាជនទាំងនេះ ហើយលោកឮសូរសំឡេងវាយដំ តើលោកស្រីមានសួរអ្នកណាម្នាក់ថា ហេតុអ្វីបានជាប្រជា

ជនទាំងនោះត្រូវបានគេចាប់ខ្លួនទេនៅពេលនោះ?

**លោកស្រី យី ឡែស្សូរ៖**

**ឆ៖** ខ្ញុំអត់ប៊ានសួរគេទេ។

**ស៖** លោកស្រី ខ្ញុំសូមអានសម្រង់ខ្លីនៃចម្លើយរបស់លោកស្រី គឺ ERN ដូចគ្នាដែលខ្ញុំបានផ្តល់អម្បាញ់មិញនេះ។ ហើយលោកស្រីបាននិយាយថា សូមដកស្រង់៖ "បន្ទាប់មក ខ្ញុំសួរប្រធានកងរបស់ខ្ញុំ បន្ទាប់មកខ្ញុំសួរមេកងរបស់ខ្ញុំ តែមេកងរបស់ខ្ញុំឆ្លើយថា សូមដកស្រង់៖ "កុំដឹងឮពីរឿងរបស់អ្នកដទៃបើមិនចង់ងាប់ទេ។ ដូច្នេះ យប់នោះគឺថាខ្ញុំដេកអត់លក់ទេ"។ បញ្ចប់ការដកស្រង់។ តើវាជួយរំឭកដល់ការចងចាំរបស់លោកស្រីទេ ដែលថាលោកស្រីបានសួរមេកងថាអ៊ីចឹង ហើយមេកងឆ្លើយថា កុំដឹងឮរឿងអ្នកដទៃបើមិនចង់ងាប់ទេ?

**ឆ៖** ចាស ពិតមែន។

**ស៖** លោកស្រីសាក្សី លោកស្រីដែលឃើញការសម្លាប់មនុស្សម្តងណាទេនៅពេលលោកស្រីធ្វើការទំនប់ការដ្ឋានត្រពាំងថ្មហ្នឹង?

**ឆ៖** អត់ដែលឃើញទេ។

[១៣:៤៨:៥៤]

**ស៖** លោកស្រីខ្ញុំសូមអានសម្រង់ឲ្យលោកស្រីស្តាប់ម្តងទៀត។ ឯកសារ E3/9338, អង់គ្លេស ERN 00288641, ខ្មែរ 00279134, បារាំង 00339891។ នេះជាអ្វីដែលលោកស្រីឆ្លើយ ស្រង់៖ "ថ្ងៃមួយម៉ោងប្រហែលជាប្រាំ ប្រាំមួយល្ងាច នៅពេលខ្ញុំនិងមិត្តភក្តិខ្ញុំទៅងូតទឹក យើងឃើញខ្មែរក្រហមចងនិងវាយដំស្ត្រីពោះធំម្នាក់ទម្លាក់ចូលទៅៗទំនប់ត្រពាំងថ្ម ខ្ញុំអត់ស្គាល់ឃាតករនោះទេ ហើយខ្ញុំក៏ត្រឡប់មកវិញអត់បានងូតទឹកទេ។ ឃាតករស្លៀកពាក់ខោអាវខ្មៅ ហើយមានគ្នាបីនាក់ មានដំបងនៅដៃមិនមានស្ពាយកាំភ្លើងអីទេ។ ខ្ញុំឃើញគេវាយដំស្ត្រីហ្នឹងហើយរុញទម្លាក់ចូលក្នុងរណ្តៅមួយ។ ហើយឃាតករទាំងអស់ហ្នឹងក៏គេចាប់ផ្តើមបោះថ្មគ្របពីលើ"។ បញ្ចប់ការដកស្រង់។ លោកស្រី តើនេះរំឭកដល់ការចង់ចាំរបស់លោកស្រី ថាលោកស្រីបានឃើញការសម្លាប់នៅការដ្ឋានទំនប់ត្រពាំងថ្មដែរទេ?

**ឆ៖** ចាស ឃើញមែន។

**ស៖** សូមលោកស្រីរៀបរាប់ឲ្យបានពេញលេញបន្តិចមក អំពីការសម្លាប់ស្ត្រីនេះ ដែលលោកស្រីបានឃើញដោយផ្ទាល់នេះ?

**ឆ៖** បានឃើញតែគេវាយមួយដំបងទៅទម្លាក់ក្នុងរណ្ដៅ គេជីកស្ពានទី១ខាងលិច។ ដាក់តែមួយភូសទៅ ធ្លាក់តែម្ដង មិនដឹងថាស្លាប់ ឬក៏មិនស្លាប់ តែគេបោះដុំថ្មសង្កត់ពីលើ។ ប៉ុណ្ណោះទៅ ខ្ញុំគ្រាន់តែម៉ាឃើញប៉ុណ្ណោះ ខ្ញុំមកកន្លែងវិញទៅ។

**ស៖** លោកស្រីសាក្សី--

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមធ្វើការកត់សម្គាល់មួយ។ ខ្ញុំមិនមានបញ្ហាអ្វីជាមួយរបៀបសួររបស់តំណាងសហព្រះរាជអាជ្ញាទេក្នុងការសួរហើយ ហើយរំឭកការចង់ចាំរបស់សាក្សី។ ប៉ុន្តែអ្វីដែលខ្ញុំមិនយល់ស្របនោះ គឺថាមានការអាន ឬក៏ផ្ដល់ការពន្យល់ការលម្អិតជាមុនទៅដល់សាក្សី។ ទី១ គាត់ថាគាត់អត់ចាំការសម្លាប់ណាមួយទេ។ ឥឡូវនេះ គាត់ថាគាត់ចាំវិញ ឃើញវិញ។ ដូច្នេះ ខ្ញុំធ្វើការកត់សម្គាល់ និងការស្នើសុំឱ្យតំណាងសហព្រះរាជអាជ្ញា -- ប្រើពាក្យអ៊ីចេះ? សូមមេត្តាកុំផ្ដល់ការពន្យល់លម្អិតច្រើនពេក ក្រោយពីការអានសម្រង់នេះហើយ។ សូមស្រង់ម្ដងមួយដំណាក់កាលៗ។

[១៣:៥២:៤២]

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

លោកប្រធាន ខ្ញុំសូមឆ្លើយដោយសង្ខេបទេ។ ដំបូង ខ្ញុំសួរសំណួរបើកទេ ដើម្បីរំឭកដល់ការចង់ចាំរបស់សាក្សី ហើយសាក្សីរូបនេះ គាត់មានសិទ្ធិដឹងអំពីចម្លើយរបស់គាត់ដែលបានឆ្លើយមុនៗនោះ គឺថាទាំងស្រុងតែម្ដង។ វាមិនពាក់ព័ន្ធរឿងបញ្ហាសីលធម៌អ្វីនោះទេ ប៉ុន្តែគាត់ត្រូវដឹងចំណុចលម្អិតទាំងអស់នៃចម្លើយមុនៗរបស់គាត់។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតបន្តសួរទៅទៀត។

**ប្រធានអង្គជំនុំ៖**

អញ្ជើញបន្ត! តាមយើងយល់ វ៉ិចទ័រ កូប៉េ លោកមិនជំទាស់នឹងការដែលដកស្រង់នូវចម្លើយមុនៗរបស់គាត់ដើម្បីសួរបញ្ជាក់ ដើម្បីការរំឭកការចង់ចាំទេ ក្រោយពីបានសួរសំណួរបើក។ ប៉ុន្តែគាត់ជំទាស់ ហើយនិងសុំឱ្យលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ កុំឱ្យអាបញ្ហាហ្នឹងមកពន្យល់ថែមពន្លាតឱ្យកាន់តែស្មុគស្មាញទៀត គ្រាន់តែដកស្រង់ទៅ តាមខ្លឹមសារដែលវាមាននៅក្នុងកំណត់ហេតុមុនៗមកសួរបញ្ជាក់គាត់ទៅ បានហើយ។ អញ្ជើញតទៀត!

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន ខ្ញុំនឹងអនុវត្តតាម។

**សួរដោយ លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** ខ្ញុំឮតាមរយៈការបកប្រែ ដែលថាយើងប្រើពាក្យថា "ប្រុស"។ លោកស្រីនិយាយថា ស្ត្រីមានផ្ទៃពោះ ប៉ុន្តែជាភាសាអង់គ្លេស គេបកប្រែទៅជា "ប្រុស"។ អ៊ីចឹង សូមលោកស្រីបញ្ជាក់បន្តិចមើល៍ លោកស្រីឃើញហ្នឹង ប្រុស ឬក៏ជាស្ត្រីមានផ្ទៃពោះ?

**លោកស្រី យី ឡៃសួរ៖**

**ឆ៖** ស្ត្រីមានផ្ទៃពោះ។

**ស៖** តើវាមានចម្ងាយប៉ុន្មានដែរពីកន្លែងលោកស្រីទៅស្ត្រីហ្នឹង ពេលលោកស្រីឃើញគេសម្លាប់ហ្នឹង?

**ឆ៖** ចម្ងាយប្រហែល ២០ ទៅ ៣០ម៉ែត្រ។

**ស៖** លោកស្រីបានឆ្លើយថា លោកស្រីបានឃើញគេវាយស្ត្រីនេះជាមួយនឹងដំបង តើអ្នកទាំងបីនេះវាយស្ត្រីជាមួយនឹងដំបងនឹងទាំងបីនាក់ហ្នឹង ឬក៏តែម្នាក់ក្នុងចំណោមបីនាក់នេះ?

[១៣:៥៥:៤៧]

*(មានបញ្ហាបច្ចេកទេស)*

[១៣:៥៨:៤០]

**ប្រធានអង្គជំនុំ៖**

បាទ ចាប់ផ្ដើមបន្តទៅទៀត សហព្រះរាជអាជ្ញារងអន្តរជាតិ សូមតាំងសំណួរសាជាថ្មី។

កុំអាល១ទាន់!

សូមអញ្ជើញលោក វ៉ិចទ័រ -- លោក អាកឡូរ វែកគែន!

**លោក អាកឡូរ វែកគែន៖**

ខ្ញុំសូមធ្វើការជំទាស់ដូចអម្បាញ់មិញដែរ។ គឺថា សហព្រះរាជអាជ្ញាចេះតែបន្តផ្តល់ព័ត៌មានឲ្យសាក្សី គាត់នៅតែបន្តធ្វើដដែល ដែលគាត់បញ្ជាក់ដោយសួរសំណួរថា ខ្ញុំភ្លេចបាត់ទៅហើយអម្បាញ់មិញនេះ ក៏ប៉ុន្តែគាត់បាននិយាយថា គេនិយាយថាឃាតករទាំងបីនាក់ហ្នឹង ជាខ្មែរក្រហម ហើយខ្ញុំ -- ចម្លើយរបស់សាក្សីដូចជាមិនមាននិយាយអ៊ីចឹងទេ។ អ៊ីចឹងសូមឲ្យគាត់ប្រុងប្រយ័ត្នចំពោះពាក្យសម្ដីរបស់គាត់។ សូមកុំហៅបែបនេះ--

**ប្រធានអង្គជំនុំ៖**

បាទ ហើយសូមអញ្ជើញទៅមុខទៀត សហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ចូសេហ្វ អេនត្រូ ប៊ិយលី៖**

នេះគ្រាន់ជាការកត់សម្គាល់ទេ វានៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់គាត់ គាត់ថា "នៅពេលដែលមិត្តខ្ញុំ និង ខ្ញុំទៅងូតទឹក យើងឃើញក្រហមចងវាយស្ត្រីមានផ្ទៃពោះ នឹងដំបងទម្លាក់ចូលក្នុងរណ្ដៅទម្លាក់ថ្មគ្របទីលើ" តែខ្ញុំសូមបន្តទៅទៀត។ លោកស្រីសាក្សីសូមជួយជម្រាបផងថា ជនរងគ្រោះនោះជាអ្នកណា ហើយឃាតករជាអ្នកណា?

**ឆ៖** ខ្ញុំអត់ស្គាល់។

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅ លោក អាកទួរ វែកកែន?

[១៤:០០:៣៣]

**លោក អាកទួរ វែកកែន៖**

ដើម្បីឲ្យមានការកត់ត្រាក្នុងប្រតិចារឹក ក្នុងភាសាបារាំង គឺអត់មាននិយាយអំពីចំណុចហ្នឹងទេ។ នៅក្នុងឯកសារ យើងអត់មានឃើញកន្លែងហ្នឹងទេ។ ហើយទោះបីជាមាននៅកន្លែងផ្សេងក៏ដោយ សហព្រះរាជអាជ្ញា គួរតែប្រយ័ត្នប្រយែងមុននឹងផ្ដល់ព័ត៌មានបញ្ចុកទៅមាត់សាក្សីនោះ។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាអាចសួរបាន។ អញ្ជើញសួរចុះ!

បដិសេធនូវការជំទាស់បែបនេះ។ ប្រសិនបើធ្វើដូច្នេះ ទំនងមេធាវី ក្រុមមេធាវីការពារក្ដីគ្មានសំណួរអីសួរបានទេ បើសួរតាមតែខ្លឹមសារដែលចែងនៅក្នុងហ្នឹង ដកស្រង់មកសួរៗ គ្មានអីអាចសួរបានទេ មិនអាចសួរផ្ទុញបានទេ មិនអាចសួរពាក្យថាដេញដោលបានទេ។

**សួរដោយលោក ចូសេហ្វ អេនត្រូ ប៊ិយលី៖**

**ស៖** លោកស្រីសាក្សី គឺខ្ញុំជិតអស់ពេលទៅហើយ។ លោកស្រីនៅក្នុងរបបខ្មែរក្រហម លោកស្រីមានប្ដីហើយ ឬនៅ?

**លោកស្រី យី ឡៃស្រួ៖**

**ឆ៖** អត់មាន។ មានចុងជិតចប់។

**ស៖** បញ្ចោបកប្រែហើយមើលទៅ។ តើត្រឹមត្រូវទេថា លោកស្រីបានរៀបការនៅចុង ជិតចុងរបបនោះ?

**ឆ៖** បាទ ពិតមែន។ ខ្ញុំប្រាប់ថាជិតចុងបញ្ចប់។

**ស៖** ហើយលោកស្រីជាអ្នកសម្រេចជ្រើសរើសបុរសនោះយកមកធ្វើជាប្ដីលោកស្រី ឬក៏យ៉ាងណា?

**ឆ៖** ខ្ញុំអត់ដឹងខ្លួនថាគេស្នើខ្ញុំទេ ស្រាប់តែប្រធានកងឲ្យខ្ញុំមកផ្ទះ។ ល្ងាចឡើង គេទៅប្រាប់ថា ខ្ញុំត្រូវរៀបការ។ ខ្ញុំអត់ដឹងថារៀបការជាមួយអ្នកណាទេ។

**ស៖** ចុះមុនពេលគេរៀបការឲ្យហ្នឹង លោកស្រីស្គាល់បុរសនោះទេ លោកស្រីស្គាល់ប្ដីរបស់លោកស្រីទេ?

**ឆ៖** អត់ស្គាល់។

**ស៖** តើនៅពេលដែលគេរៀបការឲ្យហ្នឹង លោកស្រីចង់រៀបការជាមួយបុរសនោះទេ?

**ឆ៖** អត់ចង់ទេ ប៉ុន្តែខ្លាចគេ ទៅ។

[១៤:០៣:៤៤]

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

សូមអរគុណលោកស្រីសាក្សី។ លោកប្រធាន ខ្ញុំអស់ពេលហើយ។ អ៊ីចឹងខ្ញុំសូមប្រគល់នាទីជូនសហមេធាវីនាំមុខ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សី។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម ដែលអនុញ្ញាតឲ្យខ្ញុំ -- សូមអរគុណដែលអនុញ្ញាតឲ្យខ្ញុំសួរបន្តពីតំណាងសហព្រះរាជអាជ្ញា។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

**ស៖** សូមជម្រាបសួរលោកស្រី ខ្ញុំបាទឈ្មោះ ពេជ អង្គ ជាមេធាវីជាតិនាំមុខតំណាងដើម

បណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរសួរលោកស្រីនៅក្នុងរយៈពេលប្រហែលកន្លះម៉ោង រហូតដល់កន្លះម៉ោងខាងមុខនេះ។ ខ្ញុំសូមបន្តពីតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធទៅនឹងបញ្ហាការរៀបការដោយ -- បញ្ហារៀបការនេះ ថាតើ -- លោកស្រីបានប្រសាសន៍ថា៖ "ខ្ញុំអត់ដឹងខ្លួន គេស្នើសុំ"។ ខ្ញុំចង់ជម្រាបសួរលោកស្រីថា តើអ្នកណាជាអ្នកស្នើរៀបការជាមួយនឹងលោកស្រី?

**លោកស្រី យី ឡៃសួរ៖**

**ឆ៖** ខ្ញុំអត់ដឹងថាអ្នកណាស្នើពីអ្នកណាមកទេ ស្រាប់តែប្រធានក្រុមខ្ញុំ ខ្ញុំមកដល់ផ្ទះ មានប្រធានកុមារ មកប្រាប់ថា "មិត្តនារី ត្រូវរៀបការយប់នេះ ជាមួយនឹងយុវជនឈ្មោះ រ៉ុម"។

**ស៖** លោកស្រីបានមានប្រសាសន៍អម្បាញ់មិញ "ផ្ទះ" ចង់និយាយថា ផ្ទះនៅឯភូមិ ឬក៏កន្លែងណាផ្សេង?

**ឆ៖** ខ្ញុំនៅឯកងចល័ត ប្រធានក្រុមនៅឯកងចល័តនោះ ប្រាប់ថាឲ្យខ្ញុំមកឯផ្ទះក្នុងភូមិ។ ដល់ខ្ញុំមកដល់ផ្ទះ មានគេមកប្រាប់មានប្រធានកងកុមារនោះមកប្រាប់ថា ឲ្យខ្ញុំទៅរៀបការនៅប៉ោយចារ ឲ្យទៅរៀបការជាមួយបុរសឈ្មោះ រ៉ុម។

[១៤:០៦:០៨]

**ស៖** បាទ សូមអរគុណលោកស្រី។ តើនៅម៉ោងប៉ុន្មាន ឬក៏ពេលថ្ងៃស្មើណាដែលលោកស្រីត្រូវបានគេប្រាប់ឲ្យនៅកន្លែងកងចល័តហ្នឹង លោកស្រីអាចបញ្ជាក់បានទេ?

**ឆ៖** ព្រឹកឡើងគេប្រាប់ខ្ញុំថា ព្រឹកឡើង មិត្តឯងត្រូវទៅរៀបការនៅឯភូមិ។ ម្ល៉ោះហើយគាត់ក៏នាំខ្ញុំមក ល្ងាចថ្ងៃប្រហែលថ្ងៃបែរបន្តិច គេមកប្រាប់ថា ខ្ញុំត្រូវរៀបការយប់នេះ។ ម៉ែខ្ញុំថា អត់ទៅទេ គេថា មិត្តឯងប្រយ័ត្នគេយកទៅវៃចោល។ ម្ល៉ោះហើយ ខ្ញុំខ្លាចគេក៏ខ្ញុំទៅៗ។

**ស៖** ថាតើគ្រាន់តែគេប្រាប់លោកស្រីប៉ុណ្ណឹងលោកស្រីខ្លាច ឬក៏ថាមានមូលហេតុអ្វីដែលលោកស្រីខ្លាច ហើយលោកស្រីធ្វើតាមគេដែរ?

**ឆ៖** គេថា បើខ្ញុំអត់ទៅ ប្រយ័ត្នគេយកទៅវៃចោលទាំងគ្រួសារ។

**ស៖** លោកស្រីមានឃើញអ្នកផ្សេងទៀតដែលគេធ្លាប់បដិសេធដែរឬទេ បដិសេធមិនរៀបការ?

**ឆ៖** អត់ដែលឃើញទេ។

**ស៖** បាទ សូមអរគុណ។ ពាក់ព័ន្ធនឹងបញ្ហារៀបការហ្នឹងដដែល តើលោកស្រីអាចរៀបរាប់បានទេ ថាតើការរៀបការនេះ ត្រូវធ្វើឡើងនៅទីកន្លែងណា? ហើយម៉ោងប៉ុន្មាន?

**ឆ៖** នៅកន្លែងប៉ោយចារ ប៉ុន្តែមិនដឹងថាម៉ោងប៉ុន្មានទេ។ ពេលល្ងាច យប់ មិនដឹងជាម៉ោងប៉ុន្មានទៅម៉ោង ប៉ុន្មានទេ។

**ស៖** តើទីកន្លែងប៉ោយចារហ្នឹង គឺមានជារោង មានជាទីតាំងអីយ៉ាងម៉េចសម្រាប់ការរៀបការហ្នឹងតែម្តង ឬក៏?

**ឆ៖** អត់មានរោងទេ ធ្វើក្នុងចំរេងផ្ទះ កន្លែងចំរេងផ្ទះសហករណ៍ ប្រធានសហករណ៍។

**ស៖** ខ្ញុំអត់យល់ពាក្យហ្នឹង លោកស្រីអាចជម្រាបបានទេ ចំរេងផ្ទះសហករណ៍ ខ្ញុំអត់ដែលឮទេ បាទ សូមលោកស្រីអាចមានពាក្យអីប្រើផ្សេងបានទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់!

**លោកស្រី យី ឡៃស្រូវ៖**

**ឆ៖** សព្វថ្ងៃគេហៅថា ប្រធានផ្ទះ ប្រធាននារី។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ សូមអរគុណលោកស្រី។ តើម៉ោងប៉ុន្មានដែរ ដែលកម្មវិធីរៀបការហ្នឹងចាប់ផ្តើម?

**ឆ៖** អត់ដឹងពីម៉ោងប៉ុន្មានទៅម៉ោងប៉ុន្មានទេ គិតទៅកូនក្មេងដេកស្ងាត់បានចុះ។ ខ្ញុំ ពេលនោះខ្ញុំអត់ចេះនិយាយ ខ្ញុំអត់ដឹងនិយាយពីអី។

**ស៖** បាទ ខ្ញុំសូមសួរបញ្ជាក់លោកស្រីបន្តិច នៅពេលដែលលោកស្រីរៀបការហ្នឹង លោកស្រីអាយុប៉ុន្មានដែរ?

**ឆ៖** អាយុ ១៧ឆ្នាំ។

[១៤:១០:០០]

**ស៖** ប្តីលោកស្រីដែលគេផ្សំផ្គុំឲ្យរៀបការជាមួយនឹងអាយុប៉ុន្មានដែរ លោកស្រីអាចបញ្ជាក់បានទេ?

**ឆ៖** កាលណោះ ខ្ញុំអត់ដឹងថាគេអាយុប៉ុន្មានទេ។

**ស៖** ពេលក្រោយមកទៀតលោកស្រីដឹងទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ។

**ស៖** តើលោកស្រី -- បាទ ខ្ញុំនឹងសួរសំណួរពីបញ្ហាការរស់នៅជាមួយគ្នាពេលក្រោយទៀត។

ក៏ប៉ុន្តែខ្ញុំចង់សួរថា ពេលដែលរៀបការហ្នឹងលោកស្រីអាចមានជម្រាបជូនបានទេ ថាតើមាននរណាខ្លះដែលចូលរួមនៅក្នុងពិធីរៀបការនោះ ហើយអ្នកនោះធ្វើអ្វីខ្លះនៅក្នុងពេលនោះ?

**ផ៖** ខ្ញុំអត់ចាំទេ ភ្លេចអស់ហើយ។

**ស៖** លោកស្រីអម្បាញ់មិញមានប្រសាសន៍ថា ការរៀបការហ្នឹងធ្វើឡើងនៅផ្ទះនារីឃុំ។ អ៊ីចឹងថាតើអាចមាននរណាខ្លះដែលជាអ្នកចូលរួមនៅក្នុងពេលរៀបការហ្នឹង មានៗមុខអ្នកណាខ្លះនៅពេលដែលលោកស្រីរៀបការហ្នឹង? លោកស្រីអាចចាំទេ? ឬមួយក៏មានតែលោកស្រី ហើយនិងគូស្វាមី -- ប្ដីរបស់លោកស្រីដែលគេផ្សំផ្គុំឲ្យពេលនោះ?

**ផ៖** ពេលនេះ ខ្ញុំភ្លេចអស់មិនដឹងជាមួយណាទៅមួយណាទេ។ មានគេជាច្រើន ប៉ុន្តែខ្ញុំភ្លេច។

**ស៖** បាទ លោកស្រីមានប្រសាសន៍ថាមានគេជាច្រើន។ តើនៅក្នុងពេលច្រើនហ្នឹងៗ ថាតើមានប្រហែលជាប៉ុន្មាននាក់ លោកស្រីអាចធ្វើការប្រមាណមើលដឹងទេ ថាតើប៉ុន្មាននាក់?

**ផ៖** ទាំងអ្នកស្រុកអ្នកភូមិហ្នឹងផង ប្រហែល៥០-៦០ នាក់។

[១៤:១២:៣៦]

**ស៖** បាទ សូមអរគុណលោកស្រីខ្ញុំសូមបញ្ជាក់ថា ខ្ញុំកំពុងតែសួរអំពីពេលវេលាដែលលោកស្រីកំពុងតែរៀបការហ្នឹង ហើយតើអ្នកដែលរៀបការជាមួយគ្នាក្នុងពេលជាមួយនឹងលោកស្រីហ្នឹងមានប៉ុន្មានគូ?

**ផ៖** មានបីគូ។

**ស៖** លោកស្រីមាននៅចាំឈ្មោះអ្នកដែលជាគូស្រករជាមួយលោកស្រីដែរទេ មានស្គាល់ទេ?

**ផ៖** អត់ស្គាល់គេទេ។

**ស៖** តើមានកម្មាភិបាល ឬក៏អ្នកណាផ្សេងដែលជាអ្នកដឹកនាំក្នុងការរៀបការហ្នឹងទេ? ក្នុងពិធីរៀបការហ្នឹងមានអ្នកដឹកនាំទេ? អ្នកធ្វើរៀបចំពិធីហ្នឹង?

**ផ៖** មានប៉ុន្តែខ្ញុំអត់ស្គាល់គេ។

**ស៖** ខ្ញុំសុំទោស ខ្ញុំសុំសួរលម្អិតបន្ថែមទៀត។ នៅក្នុងពេលរៀបការហ្នឹង តើលោកស្រីមានបានចាំទេ ថាតើដំណើរការនៃការរៀបការហ្នឹងគេបានធ្វើអ្វីខ្លះក្នុងពេលដែលលោកស្រីរៀបការហ្នឹង? ដែលលោកស្រីឃើញផ្ទាល់ ឬក៏ឆ្លងកាត់ផ្ទាល់ក្នុងពេលនោះ?

**ផ៖** គេធ្វើការឲ្យយើងប្ដេជ្ញាយកគ្នាមួយនឹងមួយអស់មួយជីវិត។

**ស៖** អ្នកណាជាអ្នកឲ្យលោកស្រីប្ដេជ្ញានៅក្នុងការយកគ្នាហ្នឹង? អ្នកណាជាអ្នកប្រាប់ឲ្យលោកស្រីនិយាយអំពីពាក្យហ្នឹង?

**ឆ៖** ខ្ញុំអត់ស្គាល់ទេ។

**ស៖** តើនារីឃុំគាត់មានបានចូលរួមនៅក្នុងពេលរៀបការហ្នឹងដែរឬទេ?

**ឆ៖** អត់ឃើញគាត់ទេ។

**ស៖** បាទ សូមអរគុណលោកស្រី។ លោកស្រីអាចបញ្ជាក់បានទេថាតើមានសាច់ញាតិរបស់លោកស្រីបានចូលរួមនៅក្នុងពិធីរៀបការនោះឬទេ?

**ឆ៖** បងប្អូនខ្ញុំអត់ទៅជិតទេ។

[១៤:១៥:៣៧]

**ស៖** តើលោកស្រីមានអារម្មណ៍យ៉ាងដូចម្ដេចដែរ នៅពេលដែលបងប្អូនលោកស្រីមិនអាចចូលរួមនៅក្នុងពេលលោកស្រីរៀបការនុ៎ង?

**ឆ៖** មានអារម្មណ៍ថាតូចចិត្តខ្លួនឯង ព្រោះអីគេមិនឲ្យឪពុកម្ដាយទៅជិត។

**ស៖** ចុះប្រសិន (សុំទោស) តើលោកស្រីមានបានគិតអំពីជម្រើសផ្សេងថា នឹងមិនរៀបការដែរឬទេ ក្នុងករណីដែលលោកស្រីមានជម្រើស?

**ឆ៖** គិតថាមិនរៀបការខ្លាចលគេវ៉ៃចោល។

**ស៖** ក្នុងពេលនោះថាតើមានពិធីសាសនា ឬក៏ពិធីប្រពៃណី ត្រូវបានគេរៀបចំឡើងដែរទេនៅពេលដែលលោកស្រីរៀបការនុ៎ង?

**ឆ៖** អត់មានទេ។

**ស៖** បាទ ខ្ញុំសួរទៅលើបញ្ហាដែលបន្ទាប់ពីពេលរៀបការហ្នឹង បន្ទាប់ពីលោកស្រីរៀបការហើយ តើលោកស្រីទៅរស់នៅកន្លែងណា នៅថ្ងៃបន្ទាប់ៗពីថ្ងៃរៀបការហើយនុ៎ង?

**ឆ៖** រៀបការហើយខ្ញុំគេឲ្យទៅកន្លែងចល័តច្រូតស្រូវវិញ គ្រួសារគេទៅផ្នែកខាងការងារគេវិញ។

**ស៖** សុំទោសលោកស្រី គ្រួសាររបស់លោកស្រី គាត់ធ្វើការអីដែរពេលនុ៎ង?

**ឆ៖** គាត់ដឹងនាំកុមារ។

**ស៖** លោកស្រីមានបានដឹងទេថា គ្រួសាររបស់លោកស្រីហ្នឹង មានបានប្រាប់លោកស្រីទេថា

គាត់ស្ម័គ្រចិត្តរៀបការជាមួយលោកស្រី ឬក៏គាត់ជាអ្នកស្នើដើម្បីរៀបការជាមួយលោកស្រី? ហើយគាត់ស្គាល់លោកស្រីទេ មុនពេលរៀបការហ្នឹង?

**ឆ៖** ខ្ញុំអត់បានសួរគាត់ៗអត់បានប្រាប់ខ្ញុំដែរ។

**ស៖** តើលោកស្រីរួមរស់ជាមួយគ្នារយៈពេលប៉ុន្មានដែរ? ហើយក្រោយរបបខ្មែរក្រហម មានបានរស់ជាមួយគ្នាតទៀតទេ?

**ឆ៖** រៀបការបានចំនួនប្រហែលមួយខែ វៀតណាមចូលដល់ បែកគ្នារហូត។

**ស៖** បាទ ខ្ញុំចង់សួរបញ្ជាក់ត្រឡប់មកវិញបន្តិច។ នៅថ្ងៃបន្ទាប់ពីថ្ងៃ ពេលបន្ទាប់ពីរៀបការ ពេលយប់នុំង យប់នៃពេលសម្រាន្ត បន្ទាប់ពីរៀបការហ្នឹងថាតើលោកស្រីទៅសម្រាន្ត ឬក៏ស្នាក់នៅដេកយប់នុំងនៅកន្លែងណា ពេលបន្ទាប់ពីរៀបការហើយភ្លាមនុំង?

**ឆ៖** រៀបការហើយខ្ញុំមកផ្ទះ គេទៅផ្ទះគាត់។

**ស៖** ដូច្នេះមានន័យថា លោកស្រីមានបានសម្រាន្តជាមួយប្តីលោកស្រីទេ បន្ទាប់ពីមានពិធីរៀបការហើយ។ តើខ្ញុំសន្និដ្ឋានអ៊ីចឹងត្រូវដែរឬទេ?

**ឆ៖** ចាស។

[១៤:២០:០០]

**ស៖** តើពេលណាបានលោកស្រីមានឱកាសក្នុងការជួបប្តីលោកស្រីទៀតក្នុងរយៈពេលមួយខែមុនវៀតណាមចូល។ តើលោកស្រីមានឱកាសជួបគ្នាទៀតទេ?

**ឆ៖** ទៅជួបគ្នានៅកន្លែងការដ្ឋានដែលខ្ញុំនៅច្រូតនៅវាលស្រែ។

**ស៖** តើលោកស្រីជួបហ្នឹងគឺជួបដោយស្ម័គ្រចិត្ត ឬក៏ដោយមានកម្មវិធីគេរៀបចំឲ្យជួបគ្នា?

**ឆ៖** ជួបដោយគេស្ម័គ្រចិត្តមករួមរក្សជាមួយខ្ញុំ។

**ស៖** នៅពេល -- បាទ នៅក្រោយពេលដែលរៀបការហើយ តើលោកស្រីមានត្រូវបានគេប្រាប់ ឬក៏លោកស្រីដឹងខ្លួនឯងទេថា លោកស្រីមានសិទ្ធិនៅក្នុងការលែងលះ ឬក៏មិនរស់នៅជាមួយគ្នា ប្រសិនបើលោកស្រីមិនពេញចិត្ត ឬក៏មិនចុះសម្រុងនឹងប្តីរបស់លោកស្រី តើមានទេ?

**ឆ៖** អារឿងលែងលះគ្មានសម្រេចក្នុងចិត្តខ្ញុំ។

**ស៖** ខ្ញុំចង់និយាយនៅក្នុងពេលមួយខែ ដែលបន្ទាប់ពីរៀបការហើយហ្នឹងថា តើលោកស្រីយល់ពីសិទ្ធិនៅក្នុងការលែងលះទេ? លោកស្រីយល់ថាខ្លួនឯងមានសិទ្ធិនៅក្នុងលែងលះពីប្តីហ្នឹងទេ ក្នុងរយៈ

ពេលមួយខែដែលមុននឹងមានការរំដោះនេះ?

**ផ៖** ខ្ញុំគិតក្នុងចិត្តថា បើចេះមានប្រែប្រួលយ៉ាងម៉េច ខ្ញុំគិតពីរឿងលែង ខ្ញុំគិតថាអត់យក។

**ស៖** អ៊ីចឹងលោកស្រីអត់មានខ្លាចថានឹងអ្វីមានកើតឡើងទេប្រសិនបើលោកស្រីលែងលះ អ៊ីចឹងមែនទេលោកស្រី?

**ផ៖** ចាស។

**ស៖** ខ្ញុំសួរសំណួរចុងក្រោយពាក់ព័ន្ធនឹងបញ្ហារៀបការនេះ ជាសំណួរមានលក្ខណៈទូទៅ។ លោកស្រីមានយល់ទេថា សម័យនោះដែលគេឲ្យលោកស្រីរៀបការហ្នឹង គេឲ្យគេរៀបការក្នុងគោលបំណងអ្វីដែរ?

**ផ៖** ខ្ញុំអត់យល់ត្រង់នោះ។

**ស៖** នៅក្រោយពេលរំដោះ៧៩ លោកស្រីមានរស់រានមានជីវិតជាមួយ -- រួមរស់ជាមួយប្ដីលោកស្រីតទៀតទេ បន្ទាប់ពីមានរបបថ្មីមកដល់?

**ផ៖** អត់មានទេ។

[១៤:២៣:២១]

**ស៖** លោកស្រីអាចពន្យល់ហេតុអ្វីបានជាលោកស្រីអត់មានរួមរស់ជាមួយប្ដីតទៅទៀត?

**ផ៖** ខ្ញុំអត់ពេញចិត្ត។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចូលដល់ប្រធានបទផ្សេងដើម្បីសួរបញ្ជាក់ទៅលើអ្វីដែលខាងតំណាងសហព្រះរាជអាជ្ញាបានសួរហើយ ក៏ប៉ុន្តែខ្ញុំចង់បញ្ជាក់។ នៅពេលដែលលោកស្រីត្រូវគេតម្រូវឲ្យរែកដី ហើយមេកងគេថា ឲ្យខំធ្វើម្ដេចឲ្យហើយ បើមិនហើយប្រយ័ត្នមិត្តឯង។ នេះគឺជាអ្វីដែលខ្ញុំកត់ពីលោកស្រីបានលើកពីព្រឹកមិញនេះ។ តើលោកស្រីយល់ ឬក៏មានអារម្មណ៍យ៉ាងណាដែរនៅពេលដែលគេប្រើពាក្យបែបនេះនឹងលោកស្រី?

**ផ៖** ខ្ញុំយល់ថាភ័យខ្លាច គេថាប្រយ័ត្នគេយកខ្ញុំទៅវ៉ៃចោល។

**ស៖** បាទ ខ្ញុំសូមវិលមកអំពីបញ្ហានៃការរស់នៅវិញ។ លោកស្រីអាចមានប្រសាសន៍បានទេថានៅពេលដែលលោកស្រីរស់នៅទំនប់ត្រពាំងថ្ម តើលោកស្រីបានចំណីអាហារបរិភោគបានគ្រប់គ្រាន់ដែរឬទេ?

**ផ៖** មិនសូវបានគ្រប់គ្រាន់ទេ។

**ស៖** លោកស្រីអាចបញ្ជាក់បន្ថែមទេ ថាតើបានមួយថ្ងៃប៉ុន្មាន? ប៉ុន្មានចាន ហើយបាយពិសាមួយថ្ងៃប៉ុន្មានពេល លោកស្រីអាចបញ្ជាក់បានទេ?

[១៤:២៥:៥៨]

**ឆ៖** មួយពេលមួយកូនចានចង្កឹះ មួយថ្ងៃពីរពេល។

**ស៖** តើវាជាបាយ ឬក៏ជាអ្វីផ្សេង? ហើយមានម្ហូបសម្រាប់ពិសាជាមួយគ្នាដែរឬទេ?

**ឆ៖** មានជាបាយស្ងោរទឹកប្របហុកដាក់ម្ជូរសណ្ដាន់ឲ្យហូប។

**ស៖** តើម្ហូបបែបនេះ លោកស្រីបានទទួល បានពិសាបែបនេះ គ្រប់ពេលចាប់ផ្ដើមពីពេលដែលលោកស្រីធ្វើការនៅទំនប់ត្រពាំងថ្ម រហូតដល់ពេលបញ្ចប់ដែលលោកស្រីឈប់ធ្វើការទៅទីនោះ ឬក៏មានការប្រែប្រួលពីពេលមួយទៅពេលមួយទៀត។ លោកស្រីអាចបញ្ជាក់បានទេ?

**ឆ៖** ប្រៀបពេលនោះ មានទឹកប្រហុក ក្នុងមួយអាទិត្យមានទឹកប្រហុក រហូត៦ថ្ងៃមានជាសាច់ត្រីមួយថ្ងៃ។

**ស៖** លោកស្រីស្ថិតនៅក្នុងកងអ្វីដែរ? គេហៅកងអីដែរ កងលោកស្រីហ្នឹង?

**ឆ៖** ហៅថា "សហករណ៍" – ចល័តសហករណ៍។

**ស៖** តើមានប្រភេទចល័តផ្សេងៗគ្នាដែរទេ? មានប្រភេទកងចល័តផ្សេងៗគ្នាដែរឬទេ លោកស្រីអាចបញ្ជាក់បានទេ ដែលលោកស្រីមានប្រភេទ -- អ្នកដែលកងចល័តដែលនៅជិតៗលោកស្រីហ្នឹងគេមានប្រភេទដូចលោកស្រី ឬក៏ថាខុសពីលោកស្រី?

**ឆ៖** ខ្ញុំមិនដែលបានដើរ បានឃើញអ្វីផង។

**ស៖** នៅក្នុងកងចល័តសហករណ៍របស់លោកស្រី អ្នកដែលធ្វើការជាមួយលោកស្រីហ្នឹងគេមានអាយុប៉ុន្មានដែរ? ទាបបំផុតប៉ុន្មាន ហើយអាយុច្រើនបំផុតប៉ុន្មាន លោកស្រីអាចបញ្ជាក់បានទេ?

[១៤:២៨:២១]

**ឆ៖** ទាបបំផុតត្រឹមអាយុ១៥ ឬ១៦។ ខ្ពស់បំផុត ត្រឹម៣៥ ឬក៏៤០។

**ស៖** ខ្ញុំសូមបញ្ជាក់ថា តើលោកស្រីនៅក្នុងកងកុមារ ឬក៏មិនមែនទេ?

**ឆ៖** ខ្ញុំនៅកុមារវ័យជំទង់។

**ស៖** ខ្ញុំមិនសួរពីលោកស្រីទេ។ ខ្ញុំសួរថា តើលោកស្រីស្ថិតនៅក្នុងកងកុមារ ឬក៏មិនមែន? កងហ្នឹងជាកងរបស់កុមារ ឬក៏មិនមែន?

**ឆ៖** នៅក្នុងកងនារី។

**ស៖** មួយថ្ងៃ លោកស្រី -- បាទ ខ្ញុំដកសំណួរនេះ ដោយសារវាជាន់នឹងអ្វីដែលសហព្រះរាជអាជ្ញាបានសួររួចហើយ។ ពាក់ព័ន្ធការរស់នៅ ថាតើលោកស្រីមានសម្ភារៈអ្វីផ្សេងៗសម្រាប់រស់នៅ ដូចជា មុង ភួយ អីដែរទេ?

**ឆ៖** មានតែភួយ អត់មានមុង។

**ស៖** តើគេមានផ្តល់ជាសម្ភារៈជូនលោកស្រីដែរឬទេ?

**ឆ៖** មានតែសំពត់ខ្មៅឲ្យស្លៀក។

**ស៖** អ៊ីចឹងភួយដែលលោកស្រីមានថា តើជាភួយដែលលោកស្រី ដែលគេបើកជូនលោកស្រី ឬក៏លោកស្រីបានពីកន្លែងផ្សេង ហើយក្រៅពីភួយហ្នឹង លោកស្រីមានអ្វីផ្សេងទេ ដូចជា ខ្នើយ គ្រែ ជាដើមថា តើលោកស្រីមានដែរឬទេ?

[១៤:៣០:៣១]

**ឆ៖** អត់ខ្នើយ អត់មានគ្រែទេ មានតែភួយផ្ទាល់ខ្លួនឯង។

**ស៖** បាទ ក្នុងនាមជាមនុស្សស្រីនៅពេលដែលលោកស្រីទៅបត់ដៃបត់ជើង ថាតើលោកស្រីទៅរកកន្លែងបត់ដៃបត់ជើងនៅកន្លែងណាដែរ លោកស្រីអាចបញ្ជាក់បានទេ នៅសម័យ -- នៅពេលដែលលោកស្រីធ្វើការនៅត្រពាំងថ្ម?

**ឆ៖** មានជីករណ្តៅ ហើយយកបាវបានហ៊ុម។

**ស៖** តើវាសមស្របសម្រាប់លក្ខណៈជាមនុស្សរបស់លោកស្រីដែរឬទេ ដែលលោកស្រីទៅបត់ដៃបត់ជើងនៅកន្លែងនុំង?

**ឆ៖** វាមិនសមទេ ប៉ុន្តែវាមិនដឹងធ្វើដូចម្តេច។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកស្រី ដែលបានឆ្លើយសំណួរនឹងខ្ញុំ។

សូមអរគុណលោកប្រធាន ខ្ញុំនៅ -- សហការីរបស់ខ្ញុំត្រូវការរយៈពេល៥នាទី សូមលោកប្រធានអនុញ្ញាត ដើម្បីឲ្យលោកស្រី ម៉ារី ហ្គីរ៉ូដ៍ អាចសួរសំណួររយៈពេល៥នាទី។ សូមលោប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរភាគីទាំងអស់។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី។ ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍ ខ្ញុំជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរខ្លីៗមួយចំនួនតូចដើម្បីសួរលោកស្រី។ អម្បាញ់មិញនេះ លោកស្រីបានឆ្លើយជូនការិយាល័យសហព្រះរាជអាជ្ញាថា លោកស្រីស្នាក់នៅមន្ទីរពេទ្យ ដោយសារតែលោកស្រីមានជំងឺគ្រុនចាញ់។ ខ្ញុំចង់ដឹងថា តើមានអ្នកណាផ្សេងទៀតនៅក្នុងកងរបស់លោកស្រីកើតជំងឺគ្រុនចាញ់ហ្នឹងទេ នៅពេលដែលលោកស្រីធ្វើការនៅទំនប់ត្រពាំងថ្មនោះ?

**លោកស្រី យី ឡៃស្រួ៖**

**ឆ៖** អត់មានអ្នកណាគ្រុនចាញ់ទេ គ្រុនតែខ្ញុំ។

[១៤:៣២:៥៦]

**ស៖** លោកស្រីបានឆ្លើយថា លោកស្រីសម្រាកពេទ្យ។ លោកចាំអំពីមន្ទីរពេទ្យហ្នឹងបានទេ លោកស្រីអាចរៀបរាប់ជូនតុលាការបន្តិចបានទេ អំពីមន្ទីរពេទ្យនេះ?

**ឆ៖** ខ្ញុំចាំមិនបាន។

**ស៖** លោកស្រីបានឆ្លើយថា លោកស្រីបានរត់ចេញពីពេទ្យ ពីព្រោះថាលោកស្រីខ្លាច ហើយចង់ទៅជួបម្តាយរបស់លោកស្រី។ តើលោកស្រីពិតជាបានឆ្លើយអ៊ីចឹងមែនទេ កាលពីព្រឹកមិញនេះ?

**ឆ៖** ចាស ខ្ញុំឆ្លើយមែន។

**ស៖** នៅសម័យនោះ តើលោកស្រីមានសិទ្ធិទៅសួរសុខទុកឪពុកម្តាយរបស់លោកស្រីបានទេ?

**ឆ៖** គេអត់ឲ្យទៅសួរទេ។

**ស៖** ចុះចំពោះអ្នកផ្សេងទៀត នៅក្នុងកងរបស់លោកស្រី គេហាមមិនឲ្យពួកគាត់ហ្នឹងមិនឲ្យទៅសួរសុខទុក្ខគ្រួសារដូចលោកស្រីអ៊ីចឹងដែរមែនទេ?

**ឆ៖** ចាស។

[១៤:៣៤:៣២]

**ស៖** គេមានបានពន្យល់ប្រាប់លោកស្រីទេថា ហេតុអីបានជាគេមិនឲ្យទាក់ទងជាមួយគ្រួសារហ្នឹង?

**ឆ៖** គេអត់ប្រាប់ទេ។

**ស៖** ក្នុងពេលប្រជុំ ដូចដែលលោកស្រីបាននិយាយកាលពីព្រឹកមិញនេះ គេមានបានពន្យល់ប្រាប់ថា តើឪពុកម្ដាយមានតួនាទីអ្វីទេ? អង្គការមានប្រាប់ទេថា តើតួនាទីឪពុកម្ដាយយ៉ាងម៉េចដែរគេមានពន្យល់ទេ?

**ឆ៖** អត់ពន្យល់ទេ។

**ស៖** មុននេះបន្តិចលោកស្រីបានឆ្លើយប្រាប់មេធាវីជាតិថា លោកស្រីមិនអាចមានសិទ្ធិដើរហើរដោយសេរីបានទេ។ ខ្ញុំចង់ដឹងថា លោកស្រីចង់និយាយថា លោកស្រីមិនអាចដើរពេញទាំងការដ្ឋានហ្នឹងតែម្ដង ឬក៏មិនអាចដើរឆ្លងពីកងទៅកងមួយ។ តើអាចពន្យល់ឲ្យបានច្បាស់បន្តិចបានទេ?

**ឆ៖** គេអត់ឲ្យដើរពីកងមួយទៅកងមួយ អត់ដើររកគ្នាទេ។

**ស៖** តើលោកស្រីដឹងថា ប្រសិនបើ -- នៅពេលដែលអ្នកណាម្នាក់ដើរហើរដោយសេរីអ៊ីចឹងដោយមិនមានការអនុញ្ញាតិហ្នឹង តើគេធ្វើយ៉ាងម៉េចចំពោះអ្នកហ្នឹង?

[១៤:៣៦:២១]

**ឆ៖** អត់ដែលមានអ្នកណាគេដែលដើរហើរសេរីទេ គេខ្លាច។

**ស៖** ខ្លាចអីដែរលោកស្រី?

**ឆ៖** គេខ្លាច គេយកទៅវៃ។

**ស៖** ខ្ញុំមានសំណួរចុងក្រោយពាក់ព័ន្ធនឹងស្ថានភាពវេជ្ជសាស្ត្រនៅកន្លែងរបស់លោកស្រី។ លោកស្រីបានឆ្លើយថា លោកស្រីកើតជំងឺគ្រុនចាញ់។ អ៊ីចឹងខ្ញុំចង់ដឹងថា តើមានអ្នកណាផ្សេងទៀតឈឺទេ នៅពេលដែលលោកស្រីធ្វើការនៅត្រពាំងថ្មនោះ មានសមាជិកកងផ្សេងទៀតឈឺទេ?

**ឆ៖** បើកងគេឈឺ ក៏ខ្ញុំមិនដឹងដែរ គេនៅឆ្ងាយៗគ្នា។

**ស៖** ចុះក្នុងកងរបស់លោកស្រីផ្ទាល់ហ្នឹង មានអ្នកណាផ្សេងទៀតឈឺទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ ហើយដោយសារវាជាសំណួរច្រំដែល។ សាក្សីបានឆ្លើយបញ្ជាក់ហើយថា មានតែគាត់ម្នាក់ទេដែលឈឺជំងឺគ្រុនចាញ់នេះ។ បាទ សូមអរគុណ។

[១៤:៣៨:១៩]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សំណួររបស់ខ្ញុំ គឺខ្ញុំផ្តោតទៅលើជំងឺផ្សេងទៀត មិនមែនតែជំងឺគ្រុនចាញ់ទេ។ ខ្ញុំគិតថា មិនមែនជាសំណួរច្រំដែលទេ។ ខ្ញុំសូមអនុញ្ញាតលោកប្រធាន សួរសំណួរចុងក្រោយរបស់ខ្ញុំ។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ខ្ញុំចង់ដឹងថាតើនៅក្នុងកងរបស់លោកស្រីហ្នឹងមានអ្នកណាផ្សេងទៀតឈឺជំងឺអីផ្សេងទៀត ក្រៅពីជំងឺគ្រុនចាញ់ទេ?

**លោកស្រី យី ឡៃសួរ៖**

**ឆ៖** មានរាករូសបន្តិចបន្តួច។ មានពេទ្យគេឲ្យលេបថ្នាំអាចម៍ទន្សាយហ្នឹងទៅ ជាទៅ អាខ្លះណាផឹកថ្នាំខ្មែរទៅ ជាទៅ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកស្រីសាក្សី។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៩ នាទី ដល់ម៉ោង ១៤:៥៩ នាទី)*

[១៤:៥៩:២៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

សូមអញ្ជើញលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍!

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** ខ្ញុំមានតែមួយសំណួរទេលោកស្រីសាក្សី។ ខ្ញុំបានស្តាប់ឮលោកឆ្លើយពីព្រឹកមិញតាមរយៈការបកប្រែមកជាភាសាអង់គ្លេសថា លោកស្រីមានបញ្ហាក្នុងការចងចាំ។ តើការភ្លេចភ្លាំង ការចងចាំនេះដែលពាក់ព័ន្ធទៅនឹងការងារនៅពេលនោះ ឬក៏ថាលោកស្រីបាត់បង់ការចងចាំនេះ វាជាបញ្ហាទូទៅទេ?

**លោកស្រី យី ឡៃស្រួ៖**

**ឆ៖** បញ្ហាដែលខ្ញុំគិតវាមិនឃើញខ្លួនឯងហ្នឹង។

**ស៖** តើលោកស្រីចង់មានន័យថា ខ្ញុំនឹកមិនឃើញទេ ដោយសារវាយូរពេក ឬក៏ថាដោយសារដោយស្រីមានជំងឺក៏វាធ្វើឲ្យមានបញ្ហាចំពោះការចងចាំជាទូទៅនេះ?

**ឆ៖** ចាស។

**ស៖** ខ្ញុំសួរឲ្យលោកស្រីជម្រើសពីរលោកស្រីឆ្លើយថា ចាស។ តើលោកស្រីមានបញ្ហាបាត់ការចងចាំនេះដោយសារតែហេតុផលតាំងពីយូរណាស់នោះមកហើយ ឬក៏ដោយជំងឺជាទូទៅ?

[១៥:០១:១៧]

**ឆ៖** មិនមានជាបាត់យូរទេ ដែលខ្ញុំគិតច្រើន គឺខ្ញុំក្រអត់មានអី គិតច្រើន រកនឹកអត់ឃើញ។

**ស៖** លោកស្រីមានជំងឺប្រចាំកាយ ឬក៏ដោយសារថារឿងរ៉ាវខ្លះនោះវាកើតយូរយារណាស់មកហើយ? លោកស្រី តើការចងចាំរបស់លោកស្រីនៅតែចងចាំប្រហាក់ប្រហែលគ្នាទៅនឹងអ្នកដែលមានវ័យស្របាលលោកស្រីទេ លោកស្រីមានអាយុ៥៧ហើយ?

**ឆ៖** មិនដឹងជាសួរយ៉ាងណាទេ ស្តាប់មិនបាន។

**ស៖** ចុះបើលោកស្រីនិយាយលែងជាមួយស្ត្រីដែលមានអាយុ៥៧ឆ្នាំអ៊ីចឹងដែរ។ តើលោកស្រីមានចំណាប់អារម្មណ៍ទេថា ការចងចាំរបស់លោកស្រីហ្នឹងវាអន់ជាងអ្នកដែល -- មនុស្សដែលលោកស្រីនិយាយលេងជាមួយមនុស្សអាយុ៥៧ដែរហ្នឹង ឬក៏យ៉ាងណា? ឬក៏លោកវាចាំហ្នឹងវាអន់ជាងគេពេក ឬក៏ប្រហាក់ប្រហែលគ្នាទេ?

**ឆ៖** ខ្ញុំចាំមិនដល់គេទេ។

**ស៖** តើបញ្ហានេះវាជាប់ពាក់ព័ន្ធទៅនឹងអំឡុងពេលពីឆ្នាំ១៩៧៥ ដល់១៩៧៩ ឬក៏ថាការបាត់បង់ការចងចាំនេះ វាជាបញ្ហាធម្មតាទូទៅទេ?

**ឆ៖** ជាបញ្ហាទូទៅ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីថៅក្រម។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី។ ដំបូងនេះ ផ្តល់ទៅក្រុមមេធាវីការពារលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

[១៥:០៤:០៣]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី។ ខ្ញុំមានសំណួរតិចតួចទេ ព្យាយាមធ្វើម៉េចឲ្យចប់នៅរសៀលនេះ។ ខ្ញុំចាំថា នេះនៅរសៀលមុនឈប់សម្រាកនេះ លោកស្រីឆ្លើយទៅនឹងសំណួរមួយចំនួន ឆ្លើយថា លោកស្រីទទួល មានជំងឺគ្រុនចាញ់ ជំងឺញាក់ គេបញ្ជូនទៅមន្ទីរពេទ្យ រត់ចេញពីមន្ទីរពេទ្យទៅជួបម្តាយ។ លោកស្រីចាំទេថា លោកស្រីបានឆ្លើយយ៉ាងដូច្នេះ?

**លោកស្រី យី ឡៃស្រួ៖**

**ឆ៖** ខ្ញុំចាំបានតែខ្ញុំរត់ចេញពីមន្ទីរពេទ្យទៅជួបម្តាយខ្ញុំ។

**ស៖** តាមដែលខ្ញុំយល់ គឺបញ្ហានេះ វាពាក់ព័ន្ធទៅនឹងពេលវេលា លោកស្រីធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម។ ប៉ុន្តែនៅពេលដែលខ្ញុំអានចម្លើយរបស់លោកស្រី ដែលលោកស្រីឆ្លើយជូនមន្ត្រីស៊ើបអង្កេតនោះ គឺថាលោកស្រីមានជំងឺគ្រុនចាញ់នេះ ហើយត្រូវគេបញ្ជូនទៅមន្ទីរពេទ្យ ហើយក៏លោកស្រីរត់ទៅជួបម្តាយរបស់លោកស្រីកំពង់ធំ មិនមែននៅភូមិភាគពាយ័ព្យ នៅឯការដ្ឋានទំនប់ត្រពាំងថ្មទេ។ ខ្ញុំសូមអាននូវអ្វីដែលលោកស្រីបានឆ្លើយ ដើម្បីបញ្ជាក់ចំណុចនេះឲ្យបានច្បាស់បន្តិច។ នៅក្នុងចម្លើយរបស់លោកស្រី កថាខណ្ឌទី២ “កាលនោះ ខ្ញុំមានអាយុ១៥ ទៅ១៦ឆ្នាំ គេបញ្ជូនខ្ញុំឲ្យទៅធ្វើស្រែ មានរួមទាំងស្ទូងនិងច្រូតស្រូវផងដែរ នៅកំពង់ធំ។ ខ្ញុំមានជំងឺគ្រុនចាញ់ពីកន្លែងហ្នឹងមក ហើយគេក៏បញ្ជូនខ្ញុំ

ទៅមន្ទីរពេទ្យ។ នៅពេលនោះ ខ្ញុំខ្លាចខ្មោច ហើយខ្ញុំក៏រត់ទៅផ្ទះ ទាំងមានជំងឺគ្រុនចាញ់នេះ។ នៅពេលដែលខ្ញុំទៅដល់ផ្ទះ គេអត់ឲ្យបាយខ្ញុំហូបទេ គេថាខ្ញុំរត់ចេញពីកង។"

ខ្ញុំពិនិត្យផ្ទៀងផ្ទាត់ជាមួយនឹងអត្ថបទជាភាសាខ្មែរ ដោយសារតែជាភាសាដើម លោកស្រីបានឆ្លើយថា លោកស្រីពិតជាបានទទួល -- ពិតជាមានជំងឺគ្រុនចាញ់ ហើយក៏បានទៅពេទ្យ ហើយរត់ចេញពីមន្ទីរពេទ្យ ទៅជួបម្ដាយនៅកំពង់ធំទេ។ តើត្រឹមត្រូវដែរទេ?

**ឆ៖** នៅជួបម្ដាយនៅឯផ្ទះ។

**ស៖** ខ្ញុំយល់ចំណុចនេះហើយ ក៏ប៉ុន្តែនៅក្នុងចម្លើយរបស់អ្នកស្រីឆ្លើយទៅអ្នកស៊ើបអង្កេត។ លោកស្រីឆ្លើយថា៖ "គេបញ្ជូនខ្ញុំទៅឲ្យដកស្ទូងស្រូវនៅកំពង់ធំ ហើយខ្ញុំក៏មានជំងឺគ្រុនចាញ់នៅកន្លែងនោះ"។ អ៊ីចឹងកន្លែងនោះ មានន័យ ខ្ញុំគិតថាកំពង់ធំ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** កាលពីមុននៅកំពង់ធំមែន ប៉ុន្តែដល់ខ្ញុំមកនៅលើកទំនប់ បានខ្ញុំឈឺកាន់តែខ្លាំង គេបញ្ជូនមកមន្ទីរពេទ្យ។

[១៥:០៧:៥២]

**ស៖** តើវាអាចទេដែរថា មកដល់សព្វថ្ងៃនេះ លោកស្រីកំពុងតែច្រឡូកច្របល់ពីពេលវេលានេះ។ គឺលោកស្រីមានជំងឺគ្រុនចាញ់ មិនមែននៅការដ្ឋានលើកទំនប់ទេ គឺនៅកំពង់ធំ ហើយលោកស្រីទៅមន្ទីរពេទ្យហ្នឹង គឺមន្ទីរពេទ្យនៅកំពង់ធំដែរ។ តើអ៊ីចឹង ឬក៏មិនមែនទេ?

**ឆ៖** មន្ទីរពេទ្យនៅប៉ោយចារ។

**ស៖** តើប៉ោយចារហ្នឹង នៅឯណាទៅ?

**ឆ៖** នៅឯជើងប៉ោយស្នួល គេហៅថា ឃុំប៉ោយចារ សព្វថ្ងៃនេះ។ នៅជិតត្រពាំងថ្មហ្នឹងឯងនៅខាងត្បូង។

**ស៖** តាមដែលខ្ញុំយល់នោះ គឺថាចម្លើយរបស់លោកស្រី ហាក់បញ្ជាក់ថា លោកស្រីកើតជំងឺគ្រុនចាញ់នៅកំពង់ធំ ហើយទៅមន្ទីរពេទ្យ ហើយក៏រត់ចេញមន្ទីរពេទ្យ គឺនៅកំពង់ធំហ្នឹងឯង។ ត្រឹមត្រូវដែរទេ?

**ឆ៖** ចាស។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅនិយាយពីព្រឹត្តិការណ៍មួយដែលលោកស្រីទើបតែរៀបរាប់ ថាស្ត្រីម្នាក់ត្រូវបានគេសម្លាប់ចោល។ ក្រៅពីការបាត់ចង់ចាំជាទូទៅនោះ លោកស្រីអាចពន្យល់បានទេថា

ហេតុអ្វីក៏លោកស្រីមិនចាំអំពីព្រឹត្តិការណ៍ហ្នឹង ព្រឹត្តិការណ៍សម្លាប់ស្ត្រីហ្នឹង ហើយក្រោយមកក៏ទៅជាចាំវិញ?

**ឆ៖** បើគាត់ឆ្លើយប្រាប់ខ្ញុំថា ត្រង់នោះទៅ ខ្ញុំក៏នឹកឃើញកន្លែងនោះបន្តិចទៅ។

**ស៖** បាទ មិនថ្វីទេ។ ខ្ញុំសូមសួរថា តើព្រឹត្តិការណ៍ហ្នឹងកើតឡើងនៅឯណា?

**ឆ៖** ព្រឹត្តិការណ៍ដែលវ៉ៃមនុស្សស្រីពោះធំនោះនៅត្រចៀកស្ពានទី១ ខាងលិច។

**ស៖** តើស្ពាននេះ គេមានដាក់លេខវាទេ?

**ឆ៖** អត់មានទេ។

**ស៖** ចម្លើយរបស់លោកស្រី លោកស្រីហៅថា ស្ពានទី១។ តើលោកស្រីនឹកឃើញទេ?

**ឆ៖** ស្ពានទី១ នោះឯងគេហៅទូទៅថា ស្ពានទី១ ប៉ុន្តែមិនដែលឃើញមានបង់លេខ។

**ស៖** តើលោកស្រីអាចរៀបរាប់បុរសម្នាក់ដែលពាក់ព័ន្ធក្នុងការវាយសម្លាប់ស្ត្រីហ្នឹងទេ?

**ឆ៖** អត់ដឹងទេ អត់ស្គាល់។

**ស៖** តើលោកស្រីរៀបរាប់បន្តិចមើល៍ បុរសហ្នឹងស្លៀកពាក់ខោអាវយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំគ្រាន់ឃើញតែមួយភ្លែតថា ស្លៀកពាក់ខោអាវខ្មៅ។

[១៥:១២:៣៤]

**ស៖** ហើយតើអ្នកដែលនាំស្ត្រីនោះទៅសម្លាប់ហ្នឹងទាំងអស់មានគ្នាប៉ុន្មាននាក់?

**ឆ៖** មានគ្នាបីនាក់។

**ស៖** តើការ -- តើព្រឹត្តិការណ៍ហ្នឹង កើតឡើងនៅម៉ោងប៉ុន្មាន?

**ឆ៖** មិនដឹងថាម៉ោងប៉ុន្មានទេ ថ្ងៃល្ងាច ខ្ញុំនាំមិត្តខ្ញុំទៅងូតទឹកទៅ ទទួលជួប ខ្ញុំបកមកក្រោយវិញមក។

**ស៖** តើលោកស្រីនៅចាំទេថា មិត្តភក្តិរបស់លោកស្រីដែលទៅជាមួយហ្នឹង បានឃើញព្រឹត្តិ-ការណ៍ហ្នឹងដែរទេ?

**ឆ៖** ឃើញជាមួយគ្នា។

**ស៖** លោកស្រីនៅចាំឈ្មោះ នឹកឃើញឈ្មោះនារីដែលជាមិត្តភក្តិលោកស្រីដែលបានឃើញព្រឹត្តិការណ៍នុ៎ងទេ?

**ឆ៖** ចាំបាន ប៉ុន្តែស្លាប់បាត់ហើយ។

**ស៖** ប្រហែលជាខ្ញុំស្តាប់ការបកប្រែមិនបានពេញលេញច្បាស់លាស់។ លោកស្រីបានឆ្លើយថា យើងបានឃើញព្រឹត្តិការណ៍នោះ។ ខ្ញុំ និងមិត្តភក្តិខ្ញុំ តើជាភាសាខ្មែរកាលណាប្រើពាក្យ "យើង" មិត្តភក្តិហ្នឹងតែម្នាក់ទេ ឬក៏ច្រើននាក់?

**ឆ៖** តែម្នាក់ មិត្តភក្តិ។

**ស៖** លោកស្រី តើលោកស្រីបានឃើញតែមួយភ្លែតទេ? តើលោកស្រីបានឃើញថា ស្ត្រីនោះត្រូវបានគេសម្លាប់ដោយរបៀបណាទេ?

**ឆ៖** គ្រាន់តែឃើញតែ គេវ៉ៃមួយភ្ញួសធ្លាក់ហើយ ខ្ញុំក៏គេចចេញមក។

[១៥:១៥:០០]

**ស៖** ហើយក្រោយគេវាយទម្លាក់ទៅក្នុងរណ្តៅហ្នឹងទៅ មានអ្វីកើតឡើងទៀត?

**ឆ៖** ខ្ញុំមិនដឹងថាមានអ្វីកើតឡើងទេ គ្រាន់តែឃើញ បែរទៅ ឃើញតែគេទម្លាក់ដំថ្មពីលើ ខ្ញុំក៏រត់គេចផុតមក អត់ដឹងថាគេធ្វើម៉េចទៀតទេ?

**ស៖** តើលោកស្រីធ្លាប់បានឃើញបុរសម្នាក់នោះជាថ្មីទៀតទេ? ខ្ញុំដឹងថា លោកស្រីមិនបានឃើញច្បាស់ទេ ប៉ុន្តែក្រោយមក តើបុរសនោះមាននៅចុះឡើងៗការដ្ឋានលើកទំនប់ហ្នឹងដែរទេ ឬក៏លោកស្រីអត់ឃើញទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតប! អំមិញសាក្សីមិនទាន់ឆ្លើយទេ សាក្សីឆ្លើយអំមិញ វាក្បាលមីក្រូហ្វូនអត់ប្រតិបត្តិការទេណេះ។ ចាប់ក្បាលមីក្រូហ្វូនប្រតិបត្តិការ សឹមឆ្លើយតប។

**លោកស្រី យី ឡៃស្រួ៖**

**ឆ៖** ថាអត់ឃើញទេ។

[១៥:១៦:៥៨]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ក្រោយមក តើលោកស្រីធ្លាប់ តើលោកស្រីបានឮ ដូចជាពីមេកងថា តើបុរសទាំងបីនាក់នេះជាកម្មាភិបាលដែលធ្វើការនៅឯការដ្ឋាននោះ ឬក៏យ៉ាងណា?

**ឆ៖** អត់ដឹង។

**ស៖** អ៊ីចឹងមានន័យថា លោកស្រីមិនដែលឮរឿងនេះទេ។

**ធ៖** អត់ដែលឮ។

**ស៖** តើលោកស្រីបានឮតាមរយៈអ្នកដទៃណាម្នាក់ថា ហេតុអ្វីបានជាស្ត្រីនេះត្រូវបានគេវាយ និងសម្លាប់ចោលទេ?

**ធ៖** អត់ដែលបានឮទេ។

**ស៖** តើលោកស្រីធ្លាប់បានឮថា តាវ៉ាល់ ជាអ្នកទទួលខុសត្រូវក្នុងការសម្លាប់នេះទេ?

**ធ៖** អត់ដែលឮទេ។

[១៥:១៨:៣៥]

**ស៖** ខ្ញុំនិយាយអំពីព្រឹត្តិការណ៍សម្លាប់នេះដដែល តើធ្វើម៉េចបានជាលោកស្រីបានសន្និដ្ឋានថា ស្ត្រីហ្នឹងមានផ្ទៃពោះ?

**ធ៖** ខ្ញុំឃើញគេបណ្តើរទៅ ឃើញគាត់ពោះធំ។

**ស៖** តើលោកស្រីឃើញបុរសបីនាក់ហ្នឹងមានស្ពាយកាំភ្លើងដែរទេ?

**ធ៖** អត់។

**ស៖** សូមអរគុណលោកស្រីសាក្សី។ ឥឡូវនេះ ខ្ញុំសូមចូលនិយាយពីឈ្មោះ តាវ៉ាល់។ ក្នុងចម្លើយរបស់លោកស្រី លោកស្រីឆ្លើយថា៖ "យើងទាំងអស់គ្នាមិនចង់ចូលរួមជាមួយកងចល័ត តាវ៉ាល់ទេពីព្រោះកងចល័ត តាវ៉ាល់ ហ្នឹងគឺជាកងដែលតឹងតែង ធ្វើការពិបាកណាស់"។ តើចំណុចនេះ លោកស្រីបានឮសួរថា តឹងតែងស្អីអ៊ីចឹង ឮតាំងពីមុនទៅការដ្ឋានទំនប់នោះ ឬយ៉ាងណា?

**ធ៖** ឮតាំងពីមុន បានតែឮ ប៉ុន្តែមិនដែលឃើញពីមុន។

**ស៖** ខ្ញុំខ្លាចក្រែងលោខ្ញុំយល់មិនបានច្បាស់។ ពេលធ្វើការនៅការដ្ឋាននោះ គឺថាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ តាវ៉ាល់។ សំណួររបស់ខ្ញុំនេះ អ្នកណាជាអ្នកប្រាប់លោកស្រីថា -- ប្រាប់តាំងពីមុននោះថាកងចល័តរបស់ តាវ៉ាល់ បើករង់ក្រចក (គឺជាកងដែលតឹងតែងពិបាកណាស់)។ អ៊ីចឹងអ្នកណាជាអ្នកប្រាប់លោកស្រីតាំងពីមុនទៅហ្នឹង?

**ធ៖** ឮតៗគ្នាទៅ គេចេះតែថាទៅ។

**ស៖** ហើយក្រោយមកតើពាក្យចចាមអារាមហ្នឹង តើវាជាការពិតទេ តឹងតែងអ៊ីចឹងមែន ឬក៏យ៉ាងម៉េច?

**ធ៖** ដល់ខ្ញុំឃើញផ្ទាល់ កន្លែងលើក គឺតឹងតែងដូចមាត់គេថាមែន។

**ស៖** ខ្ញុំមានសំណួរតែពីរ បីចុងក្រោយ។ លោកស្រីបានឆ្លើយថា គឺថាលោកស្រីមិនអាចទៅសួរសុខទុក្ខគ្រួសារបានទេ បើសិនណាជាមានចិត្តចង់ទៅសួរសុខទុក្ខគ្រួសារ។ តើត្រឹមត្រូវទេ ថាលោកស្រីត្រូវសុំច្បាប់ពីមេកងសិន ទើបបានទៅសួរសុខទុក្ខគ្រួសារ?

**ឆ៖** ចាស បើចង់ទៅទាល់តែសុំមេកង មេក្រុម គេអនុញ្ញាតឲ្យទៅបានទៅបាន។

**ស៖** លោកស្រីនៅចាំទេ លោកស្រីបានសុំច្បាប់ទៅលេងគ្រួសារប៉ុន្មានដងដែរ?

**ឆ៖** ខ្ញុំចាំមិនបានទេ។

[១៥:២៣:១៥]

**ស៖** ពេលលោកស្រីសុំច្បាប់ទៅលេងផ្ទះ ទៅលេងគ្រួសារ តើគេមានដែលបដិសេធទេ?

**ឆ៖** បដិសេធខ្លះ។

**ស៖** ចុះបើបដិសេធខ្លះអ៊ីចឹង លោកៗស្រីដឹងទេថាពេលដែលគេបដិសេធខ្លះអ៊ីចឹង មូលហេតុអីបានគេបដិសេធ?

**ឆ៖** គេឲ្យធ្វើការកុំឲ្យខាន។

**ស៖** បាទ ខ្ញុំយល់ហើយ។ លោកស្រីសាក្សី ពីមុននោះ ពីមុននេះមានសំណួរសួរទៅលោកស្រីថា លោកស្រីធ្វើការប៉ុន្មានខែ ប៉ុន្មានឆ្នាំនៅការដ្ឋាន លោកស្រីឆ្លើយថា លោកស្រីមិនចាំទេ មិនដឹងទេ។ សាក្សីមួយចំនួន និងឯកសារមួយចំនួនដែលយើងមាននៅក្នុងដៃ គឺថាបញ្ជាក់ថាទំនប់នេះចាប់ផ្ដើមលើកនៅពាក់កណ្ដាលខែកុម្ភៈ ហើយរួចរាល់នៅក្នុងខែមេសា។ អ៊ីចឹងទំនប់នេះ ចំណាយពេលតែពីរ ទៅបីខែទេ។ នៅពេលលោកស្រីចាប់ផ្ដើមធ្វើការនៅទីនោះ ហើយចាកចេញពីទំនប់នោះ នៅពេលឈប់ធ្វើការនៅទំនប់នោះ តើទំនប់នោះហើយស្ទើរទាំងស្រុង ឬក៏ហើយទាំងស្រុងហើយ?

**ឆ៖** កាលពីខ្ញុំឈប់ អត់ទាន់ហើយទាំងស្រុងទេ។

**ស៖** បើខ្ញុំយល់មិនច្រឡំទេ លោកស្រីបានឆ្លើយថា លោកស្រីឈប់ធ្វើការនៅទីនោះនៅពេលដែលផុតរដូវវស្សាទៅ។ អ៊ីចឹងអាចនិយាយបានថា លោកស្រីចាកចេញពីទំនប់ ហ្នឹងគឺនៅខែឧសភា ឆ្នាំ ១៩៧៧។ អាចថាអ៊ីចឹងត្រូវទេ?

**លោក ចូសេហ្វ អេនគ្រូ បិយលើ៖**

ខ្ញុំសូមជំទាស់ ពីព្រោះសាក្សីបានឆ្លើយថា មិនចាំកាលបរិច្ឆេទអ្វីទាំងអស់នៅពេលធ្វើការនៅឯទំនប់ហ្នឹង គឺគ្រាន់តែដឹងថា ចាកចេញគឺនៅរដូវប្រាំង។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមដកសំណួរនេះចេញវិញបើយ៉ាងដូច្នេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីសាក្សី តើលោកស្រីនៅចាំពេលវេលា គឺពេលវេលាដែលលោកស្រីឃើញគេសម្លាប់ស្ត្រីមានផ្ទៃពោះហ្នឹង តើពេលនោះលោកបានឃើញនៅពេលលោកស្រីចាប់ផ្តើមទៅធ្វើការដំបូង ឬក៏ឃើញនៅពេលដែលជិតដល់ពេលលោកស្រីជិតឈប់ធ្វើការនៅទីនោះហើយ?

**លោកស្រី យី ឡែស្រូវ៖**

**ឆ៖** មិនដឹងជាជិតឈប់ មិនដឹងជាពាក់កណ្តាល ខ្ញុំទើបតែនៅទេ ខ្ញុំមិនបានជាចាំ។

[១៥:២៦:៥៥]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណ លោកស្រីសាក្សី។ សូមអរគុណលោកប្រធានខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តផ្តល់វេទិកា ជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

**លោក អាកទូរ វែកគែន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី ខ្ញុំឈ្មោះ អាកទូរ វែកគែន ខ្ញុំជាមេធាវីការពារក្តីឲ្យលោក ខៀវ សំផន។ ខ្ញុំមានសំណួរមួយចំនួនតូចដើម្បីសួរលោកស្រី ខ្ញុំសួរខ្លីៗទេ។ សំណួរទី១ របស់ខ្ញុំពាក់ព័ន្ធនឹងរបៀបនៃការព្យាបាលជំងឺគ្រុនចាញ់ នៅពេលដែលខ្ញុំអានកំណត់ហេតុរបស់លោកស្រី កាលពីឆ្នាំ២០០៩ ហើយនិងនៅពេលដែលខ្ញុំស្តាប់លោកស្រី ខ្ញុំឃើញថា លោកស្រីធ្លាក់ខ្លួនឈឺក្នុងអស់រយៈពេលបីថ្ងៃ ហើយបីថ្ងៃ ក្រោយមកគេបញ្ជូនលោកស្រីទៅមន្ទីរពេទ្យ លោកស្រីដេកនៅមន្ទីរពេទ្យបីថ្ងៃ។ បន្ទាប់មកទៀតលោកស្រីទៅសម្រាកមួយសប្តាហ៍នៅផ្ទះរបស់ម្តាយលោកស្រី មុនពេលដែលឪពុកមាជាពេទ្យខ្មែរក្រហមមកសួរសុខទុក្ខម្តាយរបស់លោកស្រី ហើយផ្តល់ថ្នាំឲ្យលោកស្រី។ លោកស្រីបានឆ្លើយទៀតថា "បីថ្ងៃក្រោយមកលោកស្រីបានជាសះស្បើយពីជំងឺគ្រុនចាញ់"។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់លោកថា តើខ្ញុំរៀបរាប់អ៊ីចឹងត្រឹមត្រូវទេលោកស្រី?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** តើឪពុកមារបស់លោកស្រីផ្តល់ថ្នាំប្រភេទអ្វីដែរ ថ្នាំបុរាណខ្មែរឬក៏ថ្នាំពេទ្យសម័យយើងនេះទេ?

**ឆ៖** មិនដឹងថាថ្នាំនោះគាត់មកពី ចេញពីកាលណាទេ ថ្នាំនោះគ្រាប់ពណ៌លឿងៗហើយល្វីងឱ្យខ្ញុំលេបទៅបានបាត់គ្រុនទៅ។

**ស៖** អ៊ីចឹងមិនមែនជាថ្នាំអាចម៍ទន្សាយមែនទេ គឺថ្នាំផ្សេងពីថ្នាំអាចម៍ទន្សាយ មែនទេ?

**ឆ៖** ចាស ថ្នាំផ្សេងពីអាចម៍ទន្សាយ។

[១៥:៣០:០០]

**ស៖** នៅសម័យនោះ តើឪពុកមារបស់លោកស្រីមានមុខងារអ្វីដែរ ពេលដែលគាត់ផ្តល់ថ្នាំឱ្យលោកស្រីហ្នឹងគាត់មានមុខងារអ្វីដែរជាក់លាក់នោះ?

**ឆ៖** គាត់ធ្វើពេទ្យ។

**ស៖** លោកស្រីដឹងថាគាត់ធ្វើពេទ្យនៅទីណាទេ?

**ឆ៖** ខ្ញុំអត់ដឹងថាគាត់ធ្វើពេទ្យនៅទីណាទេ ពេលនោះគាត់រត់ខ្លាចមក គេដេញចាប់គាត់ទៅគាត់មកដល់ខ្ញុំ ឱ្យថ្នាំ គាត់ទៅវិញ។ គេសម្លាប់គាត់ចោល អត់ដឹងថាសម្លាប់នៅឯណាទេ។

**ស៖** ពេលដែលគាត់ធ្វើពេទ្យហ្នឹង គាត់ជាពេទ្យខ្មែរក្រហម ឬក៏ពេទ្យអី? ពីព្រោះថាក្នុងកំណត់ហេតុរបស់លោកស្រីៗ បញ្ជាក់ថា ឪពុកមារបស់លោកស្រីជាពេទ្យខ្មែរក្រហម។ ដូច្នេះមុនពេលដែលគេចាប់ខ្លួនគាត់ តើគាត់ធ្វើការឱ្យកម្ពុជាប្រជាធិបតេយ្យ មែនទេ?

[១៥:៣១:២៩]

**ឆ៖** គាត់ធ្វើការឱ្យពួកខ្មែរក្រហម។ ខ្ញុំអត់ដឹងថាគាត់នៅឯណា។

**ស៖** ខ្ញុំចង់សួរលម្អិតពាក់ព័ន្ធនឹងឃ្លាមួយនៅក្នុងកំណត់ហេតុរបស់លោកស្រីកាលពីឆ្នាំ២០០៩។ លោកស្រីបានឆ្លើយថា លោកស្រីបានរត់គេចពីមន្ទីរពេទ្យព្រោះថា លោកស្រីខ្លាចខ្មោច។ លោកស្រីអាចពន្យល់បានទេលោកស្រីខ្លាចខ្មោចហ្នឹង លោកស្រីចង់មានន័យថាម៉េចដែរ?

**ឆ៖** គេចខ្លាចនោះឯង ខ្លាចមិននៅ ព្រោះអីគេឱ្យតែថ្នាំទន្សាយខ្ញុំលេប ខ្លាចលោងាប់ដូចគេ។

**ស៖** ដូច្នេះលោកស្រីនិយាយថា ខ្មោចហ្នឹងគឺលោកស្រីសំដៅទៅលើព្រលឹងដែលមកយកលោកស្រីនៅពេលដែលលោកស្រីស្លាប់ហ្នឹងមែនទេ?

**ឆ៖** ចាស ខ្ញុំភ័យខ្លាចអ៊ីចឹងឯង។

**ស៖** សូមអរគុណ ខ្ញុំចូលទៅប្រធានបទផ្សេង។ ឥឡូវនេះ ខ្ញុំនិយាយអំពីការងារនៅពេលយប់។ កាលពីព្រឹកមិញនេះ នៅពេលដែលគេសួរលោកស្រីអំពីម៉ោងធ្វើការនៅទំនប់ លោកស្រីបានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់៖ "ជួនកាលខ្ញុំត្រូវបានគេឲ្យធ្វើការនៅពេលយប់"។ លោកស្រីឆ្លើយថាលោកស្រីធ្លាប់ធ្វើការពេលយប់ ហើយប្រាំនាទីក្រោយទៀតលោកស្រីបានបញ្ជាក់ថា ខ្ញុំសូមដកស្រង់៖ "ជួនកាលធ្វើការដល់ម៉ោងដប់មួយ ដប់ពីរយប់ឯណោះ"។ ដូច្នេះ ខ្ញុំចង់សួរលោកស្រីថា ការងារពេលយប់នុំុង មិនមែនថាធ្វើជារៀងរាល់ថ្ងៃទេ គឺគ្រាន់តែម្តងម្កាលទេ មែនទេ?

[១៥:៣៤:១៧]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញសហមេធាវី --តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។ តាមដែលខ្ញុំចាំនោះ ការចងចាំរបស់សាក្សីពាក់ព័ន្ធទៅនឹងពេលវេលា គឺថារៀងរាល់ថ្ងៃ គឺធ្វើការពីម៉ោងប្រាំមួយព្រឹករហូតដល់ម៉ោងដប់មួយ ហើយមកម៉ោងមួយដល់ម៉ោងប្រាំមួយ ហើយជួនកាលត្រូវធ្វើការនៅពេលយប់--

**លោក អាកទួរ វែកគែន៖**

ត្រឹមត្រូវហើយ ខ្ញុំកត់ទុកកាលព្រឹកមិញហើយ សូមឲ្យសាក្សីគាត់ឆ្លើយទៅ បើមិនត្រឹមត្រូវគាត់ឆ្លើយថា មិនត្រឹមត្រូវទៅ។ លោក មិនបាច់លោកឆ្លើយជំនួសទេ។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** លោកស្រីសាក្សី សូមលោកស្រីឆ្លើយទៅនឹងសំណួរខ្ញុំថា ការធ្វើការពេលយប់ហ្នឹង ធ្វើការជារៀងរាល់ថ្ងៃតែម្តង ឬក៏ម្តងម្កាលទេ ឬក៏យូរៗម្តងទេ ដូចដែលលោកស្រីបានឆ្លើយកាលពីព្រឹកមិញនេះ? សូមអរគុណ។

[១៥:៣៥:២៥]

**លោកស្រី យី ឡែស្សូវ៖**

**ឆ៖** ធ្វើការរាល់យប់។

**ស៖** សូមអរគុណលោកសហព្រះរាជអាជ្ញាអម្បាញ់មិញនេះដែលបានឆ្លើយ។ ឥឡូវនេះ ខ្ញុំ

និយាយអំពីបញ្ហារបបអាហារ។ នៅក្នុងកំណត់ហេតុ ហើយកាលពីព្រឹកមិញនេះ លោកស្រីបានឆ្លើយថា ហូបបាយពីរដងក្នុងមួយថ្ងៃ ហើយនិងសម្លត្រីម្តងក្នុងមួយសប្តាហ៍។ នៅក្នុងកំណត់ហេតុរបស់លោកស្រី ខ្ញុំសូមដកស្រង់៖ "គេឲ្យបាយពីរដងក្នុងមួយថ្ងៃ ដោយមានសម្ល សម្លត្រី និងសម្លម្ជូរដែលមានដាក់ស្លឹកអំពិល ហើយខ្ញុំមិនបានហូបឆ្អែតទេ។ គេវាស់បាយចែកឲ្យ ម្នាក់មួយកូនចាន"។ សូមបញ្ចប់ការដកស្រង់។ ដូច្នេះ ខ្ញុំចង់សួរលោកស្រីដូចតទៅ៖ សម្លប្រហុក ហើយនិងសម្លម្ជូរក្បាលត្រីហ្នឹង គឺថាលោកស្រីហូបជារៀងរាល់ថ្ងៃតែម្តង ឬក៏មិនរៀងរាល់ថ្ងៃទេ?

**ឆ៖** រៀងរាល់ថ្ងៃ។

**លោក អាកទួរ វែកគែន៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

[១៥:៣៧:២០]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោកស្រីសាក្សី ខ្ញុំមានសំណួរខ្លីទេដើម្បីសួរបញ្ជាក់លោកស្រី។ ទាក់ទងទៅនឹងការឃើញគេចងមនុស្ស១៥នាក់ទៅ២០នាក់។ អ្នកស្រីបានឆ្លើយថា ជាដំបូងនៅពេលដែលសហព្រះរាជអាជ្ញាលោកស្រីថា ឃើញម្តង ប៉ុន្តែក្រោយមកថា ឃើញបីដង បើតាមការអះអាងពីមុន។ អ៊ីចឹង ខ្ញុំសួរបន្ថែមទៅលើកាលៈទេសៈដែលអ្នកស្រីបានឃើញ ព្រោះក្នុងពេលអ្នកស្រីឃើញលើកទី១ ដែលម្តងអ្នកស្រីបញ្ជាក់ប្រាប់នោះ គឺនៅពេលអ្នកស្រីយាមនៅពេលយប់ ហើយមានចម្ងាយពី១០០ ទៅ២០០ម៉ែត្រ។ អ៊ីចឹង ខ្ញុំចង់ឲ្យអ្នកស្រីបញ្ជាក់ថា មានឱកាសពីរទៀតហ្នឹងជាពេលវេលាណាដែរ? ជាពេលថ្ងៃ ឬក៏ពេលយប់ ដែលអ្នកស្រីឃើញពីរដងផ្សេងទៀត?

**លោកស្រី យី ឡែស្រួវ៖**

**ឆ៖** ឃើញតែពេលយប់។

[១៥:៣៨:៣៦]

**សះ** នៅពេលពីរដងទៀតហ្នឹង អ្នកស្រីធ្វើអីដែរ បានជាឃើញគេបណ្ដើរហ្នឹង?

**ផះ** គេឲ្យខ្ញុំយាមកន្លែងចង្ក្រានបាយ។

**សះ** ខ្ញុំចង់បញ្ជាក់សាឡើងវិញ ក្រែងខ្ញុំស្ដាប់លោកស្រីមិនច្បាស់។ លោកស្រីឃើញការបណ្ដើរហ្នឹង តែម្ដងទេ មែនទេ អង្កាល់ចាប់មនុស្ស១៥នាក់ទៅ២០នាក់?

**ផះ** ចាស ខ្ញុំឃើញតែម្ដង។

**សះ** បាទ សូមអរគុណ។ ក្នុងពេលយប់នោះ មានភ្លើងអ្វីបំភ្លឺទេ នៅកន្លែងអ្នកស្រីយាម?

**ផះ** អត់មានទេ។

**សះ** បាទ សូមអរគុណ ហើយកន្លែងហ្នឹងជាព្រៃ ឬមួយក៏ជាវាលស្រឡះ?

**ផះ** វាលដើមឈើមួយដើមៗ។

**សះ** បាទ សូមអរគុណ។ អ្នកស្រីអាចបញ្ជាក់បានទេថា នៅពេលដែលអ្នកស្រីឃើញអ្នកស្រីគិតថា មនុស្ស១៥នាក់ ទៅ២០នាក់ហ្នឹង អ្នកស្រីដឹងដោយរបៀបណា?

**ផះ** ខ្ញុំដឹងដោយសារឮមាត់ស្រែ ហើយឮមាត់យំ ខ្ញុំឱនមើលទៅឃើញ។

**សះ** អ្នកស្រែ អ្នកយំហ្នឹងប៉ុន្មាននាក់? សំឡេងប៉ុន្មានដែលខុសៗគ្នា។

**ផះ** ឮសំឡេងជាច្រើន យំរំពងដើរទៅ។

**សះ** ពេលដែលអ្នកស្រីមើលឃើញហ្នឹង មើលឃើញច្បាស់ ឬក៏មើលឃើញក្នុងលក្ខណៈជាព្រាលៗទេ?

**ផះ** អត់មានព្រាលទេ មើលទៅឃើញច្បាស់ ប៉ុន្តែមិនដឹងថា ស្រីប៉ុន្មាន ប្រុសប៉ុន្មាន។

[១៥:៤១:៤២]

**សះ** អ្នកស្រីអាចបញ្ជាក់បានទេថា នៅពេលដែលអ្នកស្រីយាមយប់ហ្នឹងម៉ោងប្រហែលជាប៉ុន្មានដែរ អ្នកស្រីមើលឃើញនុ៎ង?

**ផះ** អត់ដែលមានម៉ោងមើលទេ។ ខ្ញុំវេន មិនដឹងវេនទីប៉ុន្មានទេ ភ្លេចហើយ។

**សះ** អ្នកស្រីអាចបញ្ជាក់ថា ម៉ោងប្រាំបី ប្រាំបួន ពីម៉ោងដប់ពីរចុះក្រោម ឬមុនម៉ោងដប់ពីរយប់ឡើងទៅលើ? អាចបញ្ជាក់ពីពេលវេលាហ្នឹងបានទេ?

**ផះ** ប្រហែលពីម៉ោងដប់ពីរយប់ឡើងទៅលើ។

**សះ** បាទ សូមអរគុណ ហើយមានពន្លឺអីអាចឲ្យអ្នកស្រីមើលឃើញទេ?

**ឆ៖** មានតែពន្លឺលោកខែ។

**ស៖** អ៊ីចឹងបានន័យថាមានខែរះ ហើយអ្នកស្រីចាំខែរះនៅត្រង់ណា ដល់ត្រឹមកម្ពស់ណានៅលើមេឃដែរ?

**ឆ៖** ខែប្រហែលថ្ងៃ ប្រហែលម៉ោងបី។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការសម្ពោធ នៅពេលព្រឹកមិញនេះ ម៉ោងប្រហែលជា ១០:៥០នាទី អ្នកស្រីបានឆ្លើយសំណួររបស់តំណាងសហព្រះរាជអាជ្ញា ទាក់ទងទៅនឹងការសម្ពោធទំនប់ ប៉ុន្តែចម្លើយរបស់អ្នកស្រីមិនបានឆ្លើយទៅលើទំនប់ទេ អ្នកស្រីឆ្លើយអំពីប្រឡាយបាទ។ ខ្ញុំចង់បញ្ជាក់ថា ចង់សួរបញ្ជាក់ថា តើមានការសម្ពោធផ្សេងគ្នារវាងការសម្ពោធទំនប់ ឬ/ហើយនិងការសម្ពោធប្រឡាយ ឬមួយក៏តែមួយទេ?

**ឆ៖** ចាស តែមួយ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ ខ្ញុំអស់សំណួរហើយលោកប្រធាន។

[១៥:៤៤:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ សវនាការនៅថ្ងៃនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី២៤ ខែសីហា ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃចន្ទ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-915 និងមានដើមបណ្តឹងរដ្ឋប្បវេណីបម្រុងមួយរូប ដែលមានរហស្សនាម 2-TCW-269 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

សវនាការស្តាប់សក្ខីកម្មលោកស្រីបានចប់ហើយ លោកស្រី យី ឡៃសួរ ហើយអង្គជំនុំជម្រះអរគុណលោកស្រី ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងរយៈពេលមួយថ្ងៃកន្លងមកនេះ ហើយសក្ខីកម្មរបស់លោកស្រីនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ វត្តមានរបស់លោកស្រីនៅ អ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយ។ លោកស្រីអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ។ សូមលោកស្រីជួបតែសំណាងល្អ មានសេចក្តីសុខ សេចក្តីចម្រើនគ្រប់ពេលវេលា។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកស្រី ឡៃស្ទូវ វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និងខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការនៅថ្ងៃទី -- ថ្ងៃចន្ទ ទី២៤ ខែសីហា ឆ្នាំ២០១៥ ដើមសប្តាហ៍ក្រោយឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៥:៤៦ នាទី)*